# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## បញ្ចកនិបាត

## ភាគ ៤៤

ពុទ្ធសករាជ ២៥៥៧

អធិប្បាយ

ក្នុងបញ្ចកនិបាត មាន ២ បណ្ណាសកៈ

ចែកជា ១០ វគ្គ មាន ១០០ សូត្រ

ព្រះអដ្ឋកថាកែសេចក្តី ៩៦ សូត្រ

# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## បញ្ចកនិបាត

## ភាគ ៤៤

ពុទ្ធសករាជ ២៥៥៧

អធិប្បាយ

ក្នុងបញ្ចកនិបាត មាន ២ បណ្ណាសកៈ

ចែកជា ១០ វគ្គ មាន ១០០ សូត្រ

ព្រះអដ្ឋកថាកែសេចក្តី ៨៦ សូត្រ

# អង្គុត្តរនិកាយ បញ្ចកនិបាត

## រួមមាន

## ២ បណ្ណាសកៈ និង ១០ វគ្គ

## ព្រះអដ្ឋកថាកែសេចក្ដី ៨៦ សូត្រ

### បឋមបណ្ណាសកៈ

| | | | |
|---|---|---|---|
| ១ | សេក្ខពលវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ០៧ សូត្រ |
| ២ | ពលវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ១០ សូត្រ |
| ៣ | បញ្ចង្គិកវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ១០ សូត្រ |
| ៤ | សុមនវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ១០ សូត្រ |
| ៥ | មុណ្ឌរាជវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ០៦ សូត្រ |

### ទុតិយបណ្ណាសកៈ

| | | | |
|---|---|---|---|
| ១ | នីវរណវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ០៩ សូត្រ |
| ២ | សញ្ញាវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ០៧ សូត្រ |
| ៣ | យោធាជីវវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ១០ សូត្រ |
| ៤ | ថេរវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ០៩ សូត្រ |
| ៥ | កកុធវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្ដី ០៨ សូត្រ |

# ស្រៈនិងស្យ័យ

# *Signes et accents:*



# ស្រៈពេញតួ
# Voyelles:

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឪ |
| ឡូប Romain | a | ā | i | ī | u | ū | e | o |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | ไอ |
| លាវ Laotien | ᩋ | ᩋᩣ | ᩍ | ᩎ | ᩏ | ᩐ | ᩑ | ᩒ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ
# *Consonnes:*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| អឺរ៉ុប<br>Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម<br>Siamois | ก | ข | ค | ฆ | ง |
| លាវ<br>Laotien | ກ | ຂ | ຄ | ຆ | ງ |
| សិង្ហ<br>Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា<br>Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| ឡូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| [illegible]<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| ឡូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| សង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

## ពាក្យផ្ដើម

ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖

**សុត្ត** បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។

**គេយ្យ** បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

**វេយ្យាករណ** គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។

**គាថា** គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។

**ឧទាន** គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។

**ឥតិវុត្តក** គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។

**ជាតក** គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។

**អព្ភូតធម៌** គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។

**វេទល្ល** គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបានទូវសេចក្ដី

រីករាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទឹកដីផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្ដែងធម៌មានហេតុផល ដែលអ្នកស្ដាប់អាចពិចារណាឃើញតាមសេចក្ដីពិតបាន ។

៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្តីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និងបុញាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើនទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើនទៅជាភាសាបាលីបុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដកពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ សេចក្តីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់ ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្អាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្ដាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្លាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយ-វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថាសង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះ របស់និកាយដែលពោលមកហើយទាំងនោះឯង ។ម្យ៉ាងទៀត បណ្ដានិកាយទាំង ១៨ នោះបណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្ដេញចេញហើយ បានពួកដទៃទៀត ទើបផ្ដើមតាំងជាគណាចារ្យថ្មី ៗ

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរអដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធាឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍-សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែលសមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានសាធ្យាយមន្តក្នុងគម្ពីរបតញ្ចលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះសាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កាសម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្វះ ( សិរិកុដៈ ) ខ្វះ ( សិរិកូដ្ឋៈ ) ខ្វះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបាន រចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់ ព្រះសង្ឃលង្កាទទួលស្គាល់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា បានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដង ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬ ដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណានីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បី សម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្ដីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គ នេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់ លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរីយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរីយៈ ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋកថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលបញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលទៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

*លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។*

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស
លោកគ្រូធម្មបណ្ឌិត រស់ សុជាត
លោកគ្រូវិនិយាចារ្យ គាំ អ៊ុវ

ឧបាសក ក្អាត ហ៊ាន ឧបាសក ឆាក់ម៉ៅ
ឧបាសក ធុំ ធួន ឧបាសក ហុកសីងហួត
ឧបាសក ជីម ជំនិត ឧបាសក កើត និត្យ
ឧបាសក សន ម៉ារឌី ឧបាសក ហាយ ចំរើន
ឧបាសក អ៊ុម រ៉ៃយ៉ា ឧបាសក សុក្រ ហ៊ត
ឧបាសក សោម រតនៈ ឧបាសក សំ ជាយ
ឧបាសក ម៉ៅ ដុន ឧបាសក ជា ស៊ីថាន
ឧបាសិកា ថាប់ លឿម ឧបាសិកា ហាយ សារ៉ាត់
ឧបាសិកា ប៊ុត សុម៉ាលី ឧបាសិកា យស សម្បត្តិ
ឧបាសិកា ពូ ហ៊ាង ឧបាសិកា ប៊ុត សេដាដួង
ឧបាសិកា ប៉ែន រមណី

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គធិន្នោ | នូវ ប៉ូ | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ជុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ជុត តៅ | ធម្មាចារ្យ |
| ព្រះភិក្ខុតេជធរោ | ធាវ ធាន | ធម្មាចារ្យ |

សាមណេរ កោវិទោ ឡោះសុវៀតសមណសិស្សសាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ហាយ ចំរើន

ឧបាសក ជីម ជំនិត

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់៥.០០០ព្រះវស្សា ។

យើងជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះៈ–

ឧទ្ទិសថ្វាយ និងគោរពជូនៈ

–ព្រះមហាវរក្សត្រ និងមហាវរក្សត្រិយានី

–ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

–សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

–មាតាបិតានៃយើងទាំងអស់គ្នា

–លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

–លោកគ្រូធម្មបណ្ឌិត រស់ សុជាត

–សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

–សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា ។.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

**ឈ្មោះធម៌** **ទំព័រ**

## បញ្ចកនិបាត បឋមបណ្ណាសកៈ

### សេក្ខពលវគ្គ ទី ១


| | | |
|---|---|---|
| អដ្ឋកថា សង្ខិត្តសូត្រ | ទី ១ | ១ |
| អដ្ឋកថា វិត្ថតសូត្រ | ទី ២ | ២ |
| អដ្ឋកថា ទុក្ខសូត្រ | ទី ៣ មិនមានអដ្ឋកថា | ៥ |
| អដ្ឋកថា ភតសូត្រ | ទី ៤ មិនមានអដ្ឋកថា | ៦ |
| អដ្ឋកថា សិក្ខសូត្រ | ទី ៥ មិនមានអដ្ឋកថា | ៧ |
| អដ្ឋកថា សមាបត្តិសូត្រ | ទី ៦ | ៨ |
| អដ្ឋកថា កាមសូត្រ | ទី ៧ | ៩ |
| អដ្ឋកថា ចវនសូត្រ | ទី ៨ | ១១ |
| អដ្ឋកថា បឋមអគារវសូត្រ | ទី ៩ | ១២ |
| អដ្ឋកថា ទុតិយអគារវសូត្រ | ទី ១០ | ១៣ |


### ពលវគ្គ ទី ២


| | | |
|---|---|---|
| អដ្ឋកថា អននុស្សុតសូត្រ | ទី ១ | ១៤ |
| អដ្ឋកថា កូដសូត្រ | ទី ២ | ១៦ |
| អដ្ឋកថា សង្ខិត្តសូត្រ | ទី ៣ | ១៧ |
| អដ្ឋកថា វិត្ថតសូត្រ | ទី ៤ | ១៨ |
| អដ្ឋកថា ទដ្ឋព្វសូត្រ | ទី ៥ | ១៩ |
| អដ្ឋកថា បុនកូដសូត្រ | ទី ៦ | ២២ |
| អដ្ឋកថា បឋមហិតសូត្រ | ទី ៧ | ២៣ |
| អដ្ឋកថា ទុតិយហិតសូត្រ | ទី ៨ | ២៤ |
| អដ្ឋកថា តតិយហិតសូត្រ | ទី ៩ | ២៥ |
| អដ្ឋកថា ចតុត្ថហិតសូត្រ | ទី ១០ | ២៦ |

**បញ្ចង្គិកវគ្គ ទី ៣**

| | | |
|---|---|---|
| អដ្ឋកថា បឋមគារវសូត្រ | ទី ១ | ២៧ |
| អដ្ឋកថា ទុតិយគារវសូត្រ | ទី ២ | ២៨ |
| អដ្ឋកថា ឧបក្កិលេសសូត្រ | ទី ៣ | ២៩ |
| អដ្ឋកថា ទុស្សីលសូត្រ | ទី ៤ | ៣១ |
| អដ្ឋកថា អនុគ្គហសូត្រ | ទី ៥ | ៣២ |
| អដ្ឋកថា វិមុត្តិសូត្រ | ទី ៦ | ៣៤ |
| អដ្ឋកថា សមាធិសូត្រ | ទី ៧ | ៣៦ |
| អដ្ឋកថា អង្គិកសូត្រ | ទី ៨ | ៣៩ |
| អដ្ឋកថា ចង្កមសូត្រ | ទី ៩ | ៤៧ |
| អដ្ឋកថា នាគិតសូត្រ | ទី ១០ | ៤៨ |

**សុមនវគ្គ ទី ៤**

| | | |
|---|---|---|
| អដ្ឋកថា សុមនសូត្រ | ទី ១ | ៥១ |
| អដ្ឋកថា ចុន្ទិសូត្រ | ទី ២ | ៦៣ |
| អដ្ឋកថា ឧគ្គហសូត្រ | ទី ៣ | ៦៥ |
| អដ្ឋកថា សីហសូត្រ | ទី ៤ | ៧២ |
| អដ្ឋកថា ទានានិសង្សសូត្រ | ទី ៥ | ៧៤ |
| អដ្ឋកថា កាលទានសូត្រ | ទី ៦ | ៧៥ |
| អដ្ឋកថា ភោជនទានសូត្រ | ទី ៧ | ៧៧ |
| អដ្ឋកថា សទ្ធានិសង្សសូត្រ | ទី ៨ | ៧៨ |
| អដ្ឋកថា បុត្តសូត្រ | ទី ៩ | ៧៩ |
| អដ្ឋកថា សាលសូត្រ | ទី ១០ | ៨១ |

**មុណ្ឌរាជវគ្គ ទី ៥**

| | | |
|---|---|---|
| អដ្ឋកថា អាទិយសូត្រ | ទី ១ | ៨២ |
| អដ្ឋកថា សប្បុរិសសូត្រ | ទី ២ មិនមានអដ្ឋកថា | ៨៣ |
| អដ្ឋកថា ឥដ្ឋសូត្រ | ទី ៣ | ៨៤ |
| អដ្ឋកថា មនាបទាយីសូត្រ | ទី ៤ | ៨៥ |
| អដ្ឋកថា អភិសន្ទសូត្រ | ទី ៥ មិនមានអដ្ឋកថា | ៨៩ |

អដ្ឋកថា សម្បទាសូត្រ ទី ៦ មិនមានអដ្ឋកថា ៩០
អដ្ឋកថា ធនសូត្រ ទី ៧ មិនមានអដ្ឋកថា ៩១
អដ្ឋកថា ឋានសូត្រ ទី ៨ ៩២
អដ្ឋកថា កោសលសូត្រ ទី ៩ ៩៤
អដ្ឋកថា នារទសូត្រ ទី ១០ ៩៥


## ទុតិយបណ្ណាសកៈ

### នីវរណវគ្គ ទី ១


អដ្ឋកថា អាវរណាសូត្រ ទី ១ ៩៦
អដ្ឋកថា រាសិសូត្រ ទី ២ មិនមានអដ្ឋកថា ៩៩
អដ្ឋកថា អង្គសូត្រ ទី ៣ ១០០
អដ្ឋកថា សមយសូត្រ ទី ៤ ១០៣
អដ្ឋកថា មាតុបុត្តកសូត្រ ទី ៥ ១០៤
អដ្ឋកថា ឧបជ្ឈាយសូត្រ ទី ៦ ១០៦
អដ្ឋកថា ឋានសូត្រ ទី ៧ ១០៨
អដ្ឋកថា កុមារលិច្ឆវីសូត្រ ទី ៨ ១១១
អដ្ឋកថា បឋមទុល្លភសូត្រ ទី ៩ ១១៤
អដ្ឋកថា ទុតិយទុល្លភសូត្រ ទី ១០ ១១៥


### សញ្ញាវគ្គ ទី ២


អដ្ឋកថា បឋមសញ្ញាសូត្រ ទី ១ ១១៦
អដ្ឋកថា ទុតិយសញ្ញាសូត្រ ទី ២ មិនមានអដ្ឋកថា ១១៧
អដ្ឋកថា បឋមវឌ្ឍិសូត្រ ទី ៣ ១១៨
អដ្ឋកថា ទុតិយវឌ្ឍិសូត្រ ទី ៤ មិនមានអដ្ឋកថា ១១៩
អដ្ឋកថា សាកច្ឆាសូត្រ ទី ៥ ១២០
អដ្ឋកថា សាជីវសូត្រ ទី ៦ ១២១
អដ្ឋកថា បឋមឥទ្ធិបាទសូត្រ ទី ៧ ១២២
អដ្ឋកថា ទុតិយឥទ្ធិបាទសូត្រ ទី ៨ ១២៣

| | | |
|---|---|---|
| អដ្ឋកថា និព្វិទាសូត្រ | ទី ៩ | ១២៤ |
| អដ្ឋកថា អាសវក្ខយសូត្រ | ទី ១០ មិនមានអដ្ឋកថា | ១២៥ |

**យោធាជីវវគ្គ ទី ៣**

| | | |
|---|---|---|
| អដ្ឋកថា បឋមចេតោវិមុត្តិសូត្រ | ទី ១ | ១២៦ |
| អដ្ឋកថា ទុតិយចេតោវិមុត្តិសូត្រ | ទី ២ | ១២៩ |
| អដ្ឋកថា បឋមធម្មវិហារិកសូត្រ | ទី ៣ | ១៣០ |
| អដ្ឋកថា ទុតិយធម្មវិហារិកសូត្រ | ទី ៤ | ១៣៤ |
| អដ្ឋកថា បឋមយោធាជីវសូត្រ | ទី ៥ | ១៣៥ |
| អដ្ឋកថា ទុតិយយោធាជីវសូត្រ | ទី ៦ | ១៣៩ |
| អដ្ឋកថា បឋមអនាគតសូត្រ | ទី ៧ | ១៤៣ |
| អដ្ឋកថា ទុតិយអនាគតសូត្រ | ទី ៨ | ១៤៥ |
| អដ្ឋកថា តតិយអនាគតសូត្រ | ទី ៩ | ១៤៦ |
| អដ្ឋកថា ចតុត្ថអនាគតសូត្រ | ទី ១០ | ១៤៩ |

**ថេរវគ្គ ទី ៤**

| | | |
|---|---|---|
| អដ្ឋកថា រជនីយសូត្រ | ទី ១ | ១៥១ |
| អដ្ឋកថា វីតរាគសូត្រ | ទី ២ | ១៥២ |
| អដ្ឋកថា កុហកសូត្រ | ទី ៣ | ១៥៣ |
| អដ្ឋកថា អសទ្ធសូត្រ | ទី ៤ មិនមានអដ្ឋកថា | ១៥៤ |
| អដ្ឋកថា អក្ខមសូត្រ | ទី ៥ | ១៥៥ |
| អដ្ឋកថា បដិសម្ភិទាសូត្រ | ទី ៦ | ១៥៦ |
| អដ្ឋកថា សីលសូត្រ | ទី ៧ | ១៥៧ |
| អដ្ឋកថា ថេរសូត្រ | ទី ៨ | ១៥៨ |
| អដ្ឋកថា បឋមសេក្ខសូត្រ | ទី ៩ | ១៥៩ |
| អដ្ឋកថា ទុតិយសេក្ខសូត្រ | ទី ១០ | ១៦១ |

**កកុធវគ្គ ទី ៥**

| | | |
|---|---|---|
| អដ្ឋកថា បឋមសម្បទាសូត្រ | ទី ១ | ១៦៤ |
| អដ្ឋកថា ទុតិយសម្បទាសូត្រ | ទី ២ | ១៦៥ |

| | | |
|---|---|---|
| អដ្ឋកថា ព្យាករណាសូត្រ | ទី ៣ | ១៦៦ |
| អដ្ឋកថា ជាសុសូត្រ | ទី ៤ | ១៦៧ |
| អដ្ឋកថា អកុប្បសូត្រ | ទី ៥ | ១៦៨ |
| អដ្ឋកថា សុតសូត្រ | ទី ៦ | ១៦៩ |
| អដ្ឋកថា កថាសុតសូត្រ | ទី ៧ មិនមានអដ្ឋកថា | ១៧០ |
| អដ្ឋកថា អរញ្ញសូត្រ | ទី ៨ មិនមានអដ្ឋកថា | ១៧១ |
| អដ្ឋកថា សីហាសូត្រ | ទី ៩ | ១៧២ |
| អដ្ឋកថា កកុធសូត្រ | ទី ១០ | ១៧៤ |

# អង្គុត្តរនិកាយ បញ្ចកនិបាត

# បឋមបណ្ណាសកៈ

## សេក្ខពលវគ្គវណ្ណនាទី ១

## អដ្ឋកថា សង្ខិត្តសូត្រទី ១

### *"កម្លាំងព្រះសេក្ខបុគ្គល ៥"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សង្ខិត្តសូត្រទី ១ ដូចតទៅនេះ ៖*

[១] *សេក្ខពលានិ (កម្លាំងរបស់ព្រះសេក្ខបុគ្គល) គឺ កម្លាំងរបស់ព្រះសេក្ខៈ ៧ ពួក ហេតុនោះ ទើបឈ្មោះថា សេក្ខពលៈ ។ បណ្តាសទ្ធាពលៈ ជាដើម ឈ្មោះ សទ្ធាពលៈ ព្រោះមិនញាប់ញ័រដោយសេចក្តីមិនជឿ ។ ឈ្មោះ ហិរិពលៈ ព្រោះមិនញាប់ញ័រដោយមិនមានសេចក្តីខ្មាស ។ ឈ្មោះ ឱត្តប្បពលៈ ព្រោះមិនញាប់ញ័រដោយការមិនខ្លាច ។ ឈ្មោះ វីរិយពលៈ ព្រោះមិនញាប់ញ័រដោយសេចក្តីខ្ជិលច្រអូស ។ ឈ្មោះ បញ្ញាពលៈ ព្រោះមិនញាប់ញ័រដោយអវិជ្ជា ។ បទថា តស្មា ប្រែថា ព្រោះហេតុដែលពលៈទាំងនេះ ជាពលៈរបស់ព្រះសេក្ខៈទាំងឡាយ ដូច្នោះ ។*

ចប់អដ្ឋកថា សង្ខិត្តសូត្រទី ១

# អដ្ឋកថា វិត្ថតសូត្រទី ២

## "កម្លាំងព្រះសេក្ខបុគ្គល ៥"

*គប្បីជ្រាបវិនិច្ឆ័យក្នុង វិត្ថតសូត្រទី ២ ដូចតទៅនេះ ៖*

*[២] ក្នុងបទថា* ***កាយទុច្ចរិតេន*** *ជាដើម ជាតតិយាវិភត្តិចុះក្នុងអត្ថទុតិយាវិភត្តិ ។ អធិប្បាយថា រមែងខ្មាស រមែងរង្កៀសនូវកាយទុច្ចរិត ជាដើម ដែលគួរខ្មាស ។*

*ក្នុងឱត្តប្បនិទ្ទេស ជាតតិយាវិភត្តិចុះក្នុងអត្ថថា ហេតុ ។*

*អធិប្បាយថា ខ្លាចក្រែង ព្រោះកាយទុច្ចរិតជាដើម ដែលជាហេតុនៃការខ្លាចក្រែង ។ បទថា* ***អារទ្ធវិរិយោ*** *(សេចក្តីព្យាយាម) បានដល់សេចក្តីព្យាយាមទុក ការមានចិត្តមិនរាថយ ។ បទថា* ***បហានាយ*** *ដើម្បីប្រយោជន៍ដល់ការលះ ។*

*បទថា* ***ឧបសម្បទាយ*** *(ដើម្បីញុំាង... ឲ្យដល់ព្រម) បានដល់ដើម្បីប្រយោជន៍ដល់ការបានចំពោះ ។ បទថា* ***ថាមវា*** *(ជាអ្នកមានកម្លាំង) បានដល់ ប្រកបដោយកម្លាំង គឺ សេចក្តីព្យាយាម ។*

*បទថា* ***ទឡ្ហបរក្កមោ*** *(មានសេចក្តីខ្មីឃ្មាតដ៏មាំ) អនិក្ខិត្តធុរោ កុស-*

លេសុ ធម្មេសុ ប្រែថា មិនដាក់ធុរៈចោលក្នុងកុសលធម៌ទាំងឡាយ ។

បទថា **ឧទយត្ថគាមិនិយា** (ដែលអាចកំណត់ដឹងនូវការកើត និង ការរលត់ខន្ធទាំង ៥) ។ បទថា **បញ្ញាយ សមន្នាគតោ** (ប្រកបដោយបញ្ញា) បានដល់ ជាអ្នកប្រើងប្រែង ព្យាយាមដោយវិបស្សនាញាណ និង មគ្គប្បញ្ញា ។ បទថា **អរិយាយ** (ជាអរិយៈ) តាំងនៅឆ្ងាយអំពីកិលេស ទាំងឡាយ ដោយការគ្របសង្កត់ទុក និងដោយការកាត់ផ្តាច់ ឈ្មោះថា បរិសុទ្ធ ។ បទថា **និព្វេធិកាយ** (ជម្រះកិលេស) សេចក្តីថា បញ្ញានោះ លោកហៅថា **និព្វេធិកា** ព្រោះត្រាស់ដឹង និងចាក់ធ្លុះ អធិប្បាយថា ប្រកប ដោយនិព្វេធិកប្បញ្ញានោះ ។ ក្នុងសេចក្តីនោះ មគ្គប្បញ្ញា ឈ្មោះថា **និព្វេធិកា** ព្រោះទម្លាយកងលោភៈ កងទោសៈ កងមោហៈ ដែលនៅមិន ធ្លាប់បានទម្លាយ និងមិនធ្លាប់បានកម្ចាត់ដោយអំណាចសមុច្ឆេទប្បហាន ។ វិបស្សនាញាណ ឈ្មោះថា **និព្វេធិកា** ដោយអំណាចតទង្គប្បហាន ។ ឬន័យម្យ៉ាងទៀត វិបស្សនា គួរនឹងហៅថា **និព្វេធិកា** ព្រោះប្រព្រឹត្តទៅ ដើម្បីបានមគ្គប្បញ្ញា ។ សូម្បីក្នុងបទថា **សម្មាទុក្ខក្ខយគាមិនិយា** (ជាគ្រឿង ឲ្យដល់នូវការអស់ទៅនៃទុក្ខដោយប្រពៃ) នេះ មគ្គប្បញ្ញា ឈ្មោះថា ជា

បញ្ញាអាចញុាំងវដ្ដទុក្ខឲ្យអស់ទៅដោយប្រពៃ ដោយហេតុ ដោយន័យ ។ វិបស្សនាញាណ ឈ្មោះថា (ទុក្ខក្ខយគាមិនី) (ជាគ្រឿងឲ្យអស់ទៅនៃទុក្ខ) ព្រោះអត្ថថា រមែងធ្វើវដ្ដទុក្ខ និងកិលេសទុក្ខឲ្យអស់ទៅ ដោយអំណាចតទង្គប្បហាន ។ ន័យម្យ៉ាងទៀត វិបស្សនាបញ្ញានោះ គប្បីជ្រាបថា ជាគ្រឿងឲ្យដល់ការអស់ទៅនៃទុក្ខ ព្រោះការប្រព្រឹត្តទៅដើម្បីការបានចំពោះនូវមគ្គប្បញ្ញា ដែលជាគ្រឿងឲ្យដល់ការអស់ទៅនៃទុក្ខ ក្នុងសូត្រនេះទ្រង់ត្រាស់ពលៈ ៥ លាយឡំគ្នា ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា វិត្ថតសូត្រទី ២

# អដ្ឋកថា ទុក្ខសូត្រទី ៣

*(ធម៌ ៥ ដែលឲ្យកើតទុក្ខ និងសុខ)*

[៣] *ក្នុងសូត្រទី ៣ នេះ មិនមានអដ្ឋកថាកែសេចក្ដីទេ ។*

ចប់អដ្ឋកថា ទុក្ខសូត្រទី ៣

# អដ្ឋកថា ភតសូត្រទី ៤

*(ធម៌ ៥ ដែលនាំទៅនរក និងសួគ៌)*

[៣] *ក្នុងសូត្រទី ៤ នេះ មិនមានអដ្ឋកថាកែសេចក្តីទេ ។*

ចប់អដ្ឋកថា ភតសូត្រទី ៤

# អដ្ឋកថា សិក្ខសូត្រទី ៥

*(ឋានៈដែលគួរតិះដៀលភិក្ខុ និងភិក្ខុនីលាសិក្ខា)*

[៥] *ក្នុងសូត្រនេះ មិនមានអដ្ឋកថាកែសេចក្ដីទេ ។*

ចប់អដ្ឋកថា សិក្ខសូត្រទី ៥

# អដ្ឋកថា សមាបត្តិសូត្រទី ៦

*(ធម៌ដែលជាបដិបក្ខនឹងគ្នា)*

*គប្បីជ្រាបវិនិច្ឆ័យ សមាបត្តិសូត្រទី ៦ ដូចតទៅនេះ ៖*

[៦] *បទថា **អកុសលស្ស សមាបត្តិ** (ការចូលដល់អកុសល) បានដល់ សេចក្ដីព្រមព្រៀងដោយការចូលដល់អកុសលធម៌ ។ បទថា **បរិយុដ្ឋាយ តិដ្ឋតិ** (គ្របសង្កត់) បានដល់ គ្របសង្កត់ទុកហើយ ។*

ចប់អដ្ឋកថា សមាបត្តិសូត្រទី ៦

# អដ្ឋកថា កាមសូត្រទី ៧

## *(ការអនុគ្រោះបុគ្គលដែលគួរអនុគ្រោះ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កាមសូត្រទី ៧ ដូចតទៅនេះ ៖*

*[៧] បទថា* ***កាមេសុ លឡិតា*** *(ជាប់ចិត្តក្នុងកាម) បានដល់ សេចក្តីត្រេកអរដ៏ក្រៃលែងក្នុងវត្ថុកាម និងកិលេសកាម ។ បទថា* ***អសិតព្យាភង្គី*** *(កណ្តៀវនឹងអម្រែក) បានដល់ ជាប់ដោយបាច់ស្មៅ និងដងរែកស្មៅ ។ បទថា* ***កុលបុត្តោ*** *(កុលបុត្រ) បានដល់ កុលបុត្រដែលមានមារយាទ ។ បទថា* ***ឱហាយ*** *(លះ) បានដល់ លះហើយ ។ បទថា* ***អលំវចនាយ*** *(គួរពោល) បានដល់ គួរនិយាយ ។ បទថា* ***លព្ភា*** *(គួរបាន) បានដល់ បានងាយ គឺ អាចបាន ។ បទថា* ***ហីនា កាមា*** *(កាមថោកទាប) បានដល់ កាមរបស់សត្វដែលមានត្រកូលថោកទាបទាំង ៥ ។ បទថា* ***មជ្ឈិមា កាមា*** *(កាមទាំងឡាយជាកណ្តាល) បានដល់ កាមរបស់សត្វថ្នាក់កណ្តាល ។ បទថា* ***បណីតា កាមា*** *(កាមទាំងឡាយឧត្តម) បានដល់ កាមរបស់ព្រះរាជា និងអាមាត្យរបស់ព្រះរាជា ។ បទថា* ***កាមាត្វេវ សង្ខំ គច្ឆន្តិ*** *(ក៏រាប់ថាជាកាមដូចៗ គ្នា) សេចក្តីថា ការរាប់ថា កាមទាំងនោះ*

ព្រោះអំណាចសេចក្តីប្រាថ្នា និងព្រោះអំណាចអារម្មណ៍ដែលគប្បីប្រាថ្នា ។

បទថា វុឌ្ឍោ ហោតិ (ចម្រើនធំឡើង) បានដល់ មនុស្សចាស់ ។ បទថា អលំបញ្ញោ (មានបញ្ញា) បានដល់ មានបញ្ញាសមគួរហើយ។ បទថា អត្តគុត្តោ (ដែលអាចរក្សាខ្លួនឯងបាន) បានដល់ ការឃុំគ្រងរក្សាដោយខ្លួនឯង ឬអាចឃុំគ្រងរក្សាខ្លួន ។ បទថា នាលំ បមាទាយ (មិនមានសេចក្តីប្រហែសធ្វេស) បានដល់ មិនគួរប្រហែសធ្វេស ។ បទថា សទ្ធាយ អកតំ ហោតិ (មិនធ្វើដោយសទ្ធា) បានដល់ កិច្ចណាដែលគួរធ្វើក្នុងកុសលធម៌ទាំងឡាយដោយសទ្ធា កិច្ចនោះនៅមិនទាន់បានធ្វើ ។ សូម្បីបទដ៏សេសក៏មានន័យនេះដូចគ្នា ។

ដោយបទថា អនបេក្ខោ បនាហំ ភិក្ខវេ តស្មិំ ហោមិ (ម្នាលភិក្ខុទាំងឡាយ តថាគត ក៏មិនសូវគយគន់មើលចំពោះភិក្ខុទាំងឡាយនោះទេ) ព្រះមានព្រះភាគទ្រង់ត្រាស់សំដែងថា តថាគតគយគន់មើលចំពោះបុគ្គលនោះ អ្នកធ្វើកិច្ចដែលគួរធ្វើដោយសទ្ធាជាដើមយ៉ាងនេះ ហើយតាំងនូវក្នុងសោតាបត្តិផល ។ ក្នុងសូត្រនេះ ទ្រង់សំដៅយកសោតាបត្តិមគ្គ ។

ចប់អដ្ឋកថា កាមសូត្រទី ៧

# អដ្ឋកថា ចវនសូត្រទី ៨[១]

*(ធម៌ដែលធ្វើឲ្យតាំងស៊ប់ និងមិនតាំងស៊ប់ក្នុងសាសនា)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចវនសូត្រទី ៨ ដូចតទៅនេះ ៖*

*[៨] បទថា **សទ្ធម្មេ** (ក្នុងព្រះសទ្ធម្ម) បានដល់ ព្រះសទ្ធម្ម ពោល គឺ ពាក្យទូន្មាន ។ បទថា **អស្សទ្ធោ** (អ្នកមិនមានសទ្ធា) បានដល់ អ្នកមិនតាំងនៅស៊ប់ដោយសទ្ធា ២ យ៉ាង គឺ **ឱកប្បនសទ្ធា** (សទ្ធាតាំងស៊ប់) និង **បច្ចក្ខសទ្ធា** (សទ្ធាប្រាកដ) ។ បទថា **ចវតិ នប្បតិដ្ឋាតិ** (រមែងឃ្លាត គឺ មិនតាំងនៅស៊ប) បានដល់ ប្រាសចាកគុណក្នុងសាសនានេះ មិនអាចតាំងនៅយូរបាន ។ ក្នុងសូត្រនេះ ព្រះអង្គទ្រង់ត្រាស់សម្តែងព្រះសូត្រដែលតាំងនៅយូរបាន នឹងតាំងនៅយូរមិនបាន ។*

ចប់អដ្ឋកថា ចវនសូត្រទី ៨

---

*(១) ឋិដក = ចវតិ*

# អដ្ឋកថា បឋមអគារវសូត្រទី ៩

## (ធម៌ដែលធ្វើឲ្យតាំងស៊ប់ និងមិនតាំងស៊ប់ក្នុងសាសនា)

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអគារវសូត្រទី ៩ ដូចតទៅនេះ ៖*

[៩] *អគារវោ (មិនមានការគោរព) ព្រោះបុគ្គលមិនមានសេចក្តីគោរព ។ បទថា អប្បតិស្សោ (មិនមានសេចក្តីកោតក្រែង) ព្រោះគេមិនមានសេចក្តីគោរព ពោលគឺ មិនជាអ្នកជំ (ក្នុងក្រសែភ្នែក) មិនប្រព្រឹត្តបន្ទាបខ្លួន ។ បទដ៏សេសក្នុងសូត្រនេះ ដូចគ្នាជាមួយសូត្រមុននេះឯង ។*

ចប់អដ្ឋកថា បឋមអគារវសូត្រទី ៩

# អដ្ឋកថា ទុតិយអគារវសូត្រទី ១០

*(ធម៌ដែលធ្វើឲ្យចម្រើន និងមិនចម្រើនក្នុងសាសនា)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយអគារវសូត្រទី ១០ ដូចតទៅនេះ ៖*

*[១០] បទថា **អកតញ្ញូ** (ជាអ្នកមិនគួរ) គឺ មិនគួរដល់នូវសេចក្តីចម្រើន ។ បទថា **វុឌ្ឍឹ** បានដល់ សេចក្តីចម្រើន ។ បទថា **វិរូឡ្ហឹ** (លូតលាស់) បានដល់ ភាពជាអ្នកមិនញាប់ញ័រ ព្រោះជាអ្នកលូតលាស់ហើយ ។ បទថា **វេបុល្លំ** (ធំទូលាយ) បានដល់ ភាពជាធំ ។ បទដ៏សេសក្នុងទីទាំងពួង ងាយទាំងអស់ ។*

ចប់អដ្ឋកថា ទុតិយអាគារវសូត្រទី ១០

## ចប់សេក្ខវគ្គវណ្ណនាទី ១

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៧ សូត្រ

# ពលវគ្គវណ្ណនាទី ២

## អដ្ឋកថា អននុស្សុតសូត្រទី ១

### (កម្លាំង ៥ របស់ព្រះតថាគត)

*គប្បីជ្រាបវិនិច្ឆ័យក្នុង អននុស្សុតសូត្រទី ១ ដូចតទៅនេះ ៖*

[១១] *បទថា បុព្វាហំ ភិក្ខវេ អននុស្សុតេសុ ធម្មេសុ (ម្នាលភិក្ខុទាំងឡាយ តថាគតប្ដេជ្ញាថាជាអ្នកដល់នូវព្រះអរហត្ត ជាទីបំផុតនៃអភិញ្ញានិងត្រើយនៃអភិញ្ញា ក្នុងធម៌ដែលមិនធ្លាប់បានឮក្នុងមុន) សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ តថាគតដឹងក្រែងលែងក្នុងធម៌ទាំងឡាយ គឺ សច្ចធម៌ ៤ ដែលតថាគតមិនធ្លាប់បានស្ដាប់មកក្នុងកាលមុន ។ បទថា **អភិញ្ញាវោ-សានបារមិប្បត្តោ** បដិជានាមិ (ចម្រើននូវបារមីដែលជាទីបំផុត ព្រោះដឹងដ៏ក្រៃលែង) ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងដល់គុណ ដែលព្រះអង្គត្រាស់ដឹងនៅត្រង់ពោធិបល្ល័ង្កថា តថាគត ដឹងដ៏ក្រែងលែងក្នុងសច្ចធម៌ ៤ ដោយការធ្វើកិច្ច ១៦ យ៉ាង សម្រេចដោយមគ្គ ៤ ហើយ សម្រេចបារមីជាទីបំផុត គឺ ត្រើយនៃប្រាំង ពោលគឺ ជាអ្នកធ្វើកិច្ចសម្រេចហើយ*

ព្រោះកិច្ចទាំងឡាយ តថាគតបានត្រាស់ដឹងហើយ ទើបប្តេជ្ញា ។ បទថា **តថាគតស្ស** (របស់ព្រះតថាគត) បានដល់ របស់ព្រះតថាគតដែលបានមកដោយអត្ថ ៨ យ៉ាង ។ បទថា **តថាគតពលានិ** (កម្លាំងរបស់តថាគតទាំងឡាយ) បានដល់ កម្លាំងញាណដែលដល់ហើយ គឺ ប្រព្រឹត្តទៅហើយដោយអាការដែលគប្បីដឹងបានដោយកម្លាំងទាំងនោះ ។ បទថា **អាសភណ្ឋានំ** (ឋានៈដែលអាច) គឺ ឋានៈដ៏ប្រសើរបំផុត ។ បទថា **សីហនាទំ** (សីហនាទ) គឺ បន្លឺនូវសីហនាទដ៏ក្លៀវក្លា ។ បទថា **ព្រហ្មចក្កំ** (ញ៉ាំងចក្រ) គឺ ចក្រដ៏ប្រសើរ ។ បទថា **បវត្តេតិ** (ប្រកាស) គឺ ពោល ។

ចប់អដ្ឋកថា អននុស្សុតសូត្រទី ១

# អដ្ឋកថា កូដសូត្រទី ២

## (កម្លាំងព្រះសេក្ខ ៥)

*គប្បីជ្រាបវិនិច្ឆ័យក្នុងកូដសូត្រទី ២ ដូចតទៅនេះ ៖*

[១២] *បទថា **សេក្ខពលានិ** (កម្លាំងរបស់សេក្ខបុគ្គល) បានដល់កម្លាំងញាណរបស់សេក្ខបុគ្គលទាំងឡាយ ។ បទថា **អគ្គំ** (ប្រសើរ) គឺខ្ពង់ខ្ពស់បំផុត ។ បទថា **សង្គាហិកំ** (ជាទីរួមប្រជុំ) ព្រោះអធិប្បាយថា រួមកម្លាំងដ៏សេស ដូចកំពូលផ្ទះ ជាទីរួមនៃឈើបង្កង់ ដូច្នោះ ។ បទថា **សង្ឃាតនិយំ** (ជាទីប្រជុំ) ព្រោះអត្ថថា ធ្វើកម្លាំងទាំងនោះឯង ឲ្យប្រជុំគ្នា ។*

ចប់អដ្ឋកថា កូដសូត្រទី ២

# អដ្ឋកថា សង្ខិត្តសូត្រទី ៣

## (កម្លាំង ៥ )

*គប្បីជ្រាបវិនិច្ឆ័យក្នុង សង្ខិត្តសូត្រទី ៣ ដូចតទៅនេះ ៖*

[១៣] *បទថា **សតិពលំ** (កម្លាំងគឺសតិ) ព្រោះអត្ថថា មិនញាប់ញ័រដោយភាពជាអ្នកមិនមានសតិ ។ បទថា **សមាធិពលំ** (កំលាំងគឺសមាធិ ) ព្រោះអត្ថថា មិនញាប់ញ័រដោយការរាយមាយ ។*

ចប់អដ្ឋកថា សង្ខិត្តសូត្រទី ៣

# អដ្ឋកថា វិត្ថតសូត្រទី ៤

*(កម្លាំង ៥ ប្រការ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វិត្ថតសូត្រទី ៤ ដូចតទៅនេះ ៖*

[១៤] *បទថា* ***សតិនេបក្កេន*** *(ដោយសតិ និងបញ្ញាជាគ្រឿងរក្សាខ្លួន) នេះ បញ្ញា ហៅថា* ***នេបក្កៈ*** *(បញ្ញារក្សាខ្លួន) ទ្រង់កាន់យកបញ្ញានោះ ព្រោះជាឧបការៈដល់សតិ ។*

ចប់អដ្ឋកថា វិត្ថតសូត្រទី ៤

# អដ្ឋកថា ទដ្ឋព្វសូត្រទី ៥

## (ការឃើញកម្លាំង ៥)

គប្បីជ្រាបវិនិច្ឆ័យក្នុង ទដ្ឋព្វសូត្រទី ៥ ដូចតទៅនេះ ៖

[១៥] ព្រះមានព្រះភាគជាម្ចាស់ កាលនឹងត្រាស់លោកុត្តរធម៌ក្នុងទីមិនមែនជាវិស័យ ទើបត្រាស់បទមានជាអាទិ៍ថា **កត្ថ ច ភិក្ខវេ សទ្ធាពលំ ទដ្ឋព្វំ (ម្នាលភិក្ខុទាំងឡាយ ចុះកម្លាំងសទ្ធា គួរឃើញក្នុងទីណា)** ដូចមានសេចក្តីថា កាលសម្លាញ់មានព្រះរាជាជាទី ៥ គឺ បុត្រសេដ្ឋី ៤ នាក់ និងព្រះរាជា ១ អង្គ ដើរតាមផ្លូវ ដោយគិតថា យើងនឹងលេងនក្ខត្តឫក្ស ក្នុងវេលាទៅដល់ផ្ទះរបស់បុត្រសេដ្ឋីទី ១ , ៤ នាក់ ទៀតអង្គុយព្រងើយ ម្ចាស់ផ្ទះប៉ុណ្ណោះពោលថា ពួកលោកចូលឲ្យរបស់ទំពាស៊ី របស់បរិភោគ របស់ក្រអូប ផ្លែឈើ និងគ្រឿងប្រដាប់តែងខ្លួនដល់លោកទាំងនេះ ហើយត្រួតត្រាក្នុងផ្ទះ ។ ក្នុងវេលាទៅផ្ទះរបស់សេដ្ឋីបុត្រទី ២ ទី ៣ ទី ៤ , ៤ នាក់ទៀត អង្គុយព្រងើយ ម្ចាស់របស់ផ្ទះពោលថា ពួកលោកចូលឲ្យរបស់ទំពាស៊ី របស់បរិភោគ គ្រឿងអូប ផ្លែឈើ និងគ្រឿប្រដាប់ដល់លោកទាំងនេះ ដូច្នេះ ហើយត្រួតត្រាក្នុងផ្ទះ ។ លុះតមក ក្នុងវេលាទៅដល់រាជ-

មណ្ឌបរបស់ព្រះរាជា ក្រោយគេបង្អស់ ព្រះរាជាសូម្បីទ្រង់ជាធំលើជនទាំងអស់ក៏ពិត តែក្នុងវេលានោះក៏នៅត្រាស់ថា ពួកលោកចូលឲ្យរបស់ទំពារបស់បរិភោគ គ្រឿងក្រអូប ផ្កាឈើ និងគ្រឿងប្រដាប់ជាដើមដល់លោកទាំងនេះ ដូច្នេះ ហើយទ្រង់ត្រួតត្រាក្នុងព្រះរាជមណ្ឌបរបស់ព្រះអង្គ យ៉ាងណា ឯពលៈដូច្នោះ កាលពលៈ មានសទ្ធាជាទី ៥ សូម្បីកើតឡើងក្នុងអារម្មណ៍តែមួយជាមួយគ្នា ក៏ដូចកាលសម្លាញ់ទាំងនោះ ចេញដើរតាមផ្លូវព្រមគ្នា សម្លាញ់ ៤ នាក់ទៀតអង្គុយព្រងើយក្នុងផ្ទះរបស់សេដ្ឋីទីមួយ សម្លាញ់ដែលជាម្ចាស់នៃផ្ទះ រមែងត្រួតត្រា យ៉ាងណា សទ្ធាពលៈ មានលក្ខណៈបង្អោនចិត្តជឿ ព្រោះលុះសោតាបត្តិយង្គៈហើយ រមែងជាធំ ជាប្រធាន ពលៈដ៏សេស ក៏បណ្តោយតាមសទ្ធាពលៈនោះ ដូច្នោះ ក្នុងផ្ទះរបស់សេដ្ឋីបុត្រទី ២ សម្លាញ់បួននាក់ទៀតក៏អង្គុយព្រងើយ សម្លាញ់ម្ចាស់ផ្ទះជាអ្នកត្រួតត្រា យ៉ាងណា វីរិយពលៈ មានលក្ខណៈផ្គងទុក ព្រោះដល់សម្មប្បធានហើយ រមែងជាធំ រមែងជាប្រធាន ពលៈដ៏សេស ក៏បណ្តោយតាមវីរិយៈពលៈនោះ ។ ក្នុងផ្ទះរបស់សេដ្ឋីបុត្រទីបី សម្លាញ់បួននាក់ទៀតក៏អង្គុយព្រងើយ សម្លាញ់ជាម្ចាស់ផ្ទះជាអ្នកត្រួតត្រា យ៉ាងណា សតិពលៈ

មានលក្ខណៈចូលទៅតាំងទុក ព្រោះដល់កាលសតិប្បដ្ឋានហើយ រមែងជាធំ ជាប្រធាន ពលៈដ៏សេសក៏បណ្តោយតាមសតិពលៈនោះ ។ ក្នុងផ្ទះរបស់សេដ្ឋីបុត្រទីបួន សម្ងាញ់បួនទៀតក៏អន្តុយព្រងើយ សម្ងាញ់ជាម្ចាស់ផ្ទះ រមែងត្រួតត្រា យ៉ាងណា សមាធិពលៈ មានលក្ខណៈមិនរវើរវាយ ព្រោះដល់នូវឈានវិមោក្ខហើយ រមែងជាធំ ជាប្រធាន ពលៈដ៏សេសក៏បណ្តោយតាមសមាធិពលៈនោះឯង ដូច្នោះ ។ តែក្នុងវេលាទៅដល់រាជមណ្ឌលរបស់ព្រះរាជាក្រោយគេបង្អស់ សម្ងាញ់បួននាក់ទៀតក៏អន្តុយព្រងើយ ព្រះរាជាតែមួយព្រះអង្គឯង ទ្រង់ត្រួតត្រាក្នុងព្រះរាជមណ្ឌល យ៉ាងណា បញ្ញាពលៈ មានលក្ខណៈដឹងនូវទៅដល់អរិយសច្ចៈ ៤ ទើបជាធំ ជាប្រធាន ពលៈដ៏សេសក៏បណ្តោយតាមបញ្ញាពលៈនោះ ដូច្នោះដូចគ្នា ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ពលៈ ៥ ក្នុងសូត្រនេះ លាយគ្នាយ៉ាងនេះ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា ឧដ្ឋព្វសូត្រទី ៤

# អដ្ឋកថា បុនក្កូដសូត្រទី ៦

*(កម្លាំងដែលជាកំពូល)*

[១៦] *បុនកូដសូត្រទី ៦ មានសេចក្តីងាយហើយ ។ ទ្រង់ត្រាស់សេក្ខពលៈប៉ុណ្ណោះក្នុង ៨ សូត្រ ទាំងវគ្គមុន និងវគ្គក្រោយ ។ តែព្រះមហាទត្តត្ថេរៈ គង់នៅក្នុងករណ្ឌលោហាវិហារពោលថា ព្រះមានព្រះភាគត្រាស់សេក្ខពលៈក្នុង ៤ សូត្រ ជាសូត្រខាងក្រោម ត្រាស់សេក្ខពលៈក្នុង ៤ សូត្រ ជាសូត្រខាងលើ ។*

ចប់អដ្ឋកថា បុនក្កូដសូត្រទី ៦

# អដ្ឋកថា បឋមហិតសូត្រទី ៧

*(ភិក្ខុបដិបត្តិដើម្បីប្រយោជន៍ខ្លួន)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមហិតសូត្រ ៧ ដូចតទៅនេះ ៖*

[**១៧**] *ក្នុងបឋមហិតសូត្រ ទី ៧ ត្រាស់សីលជាដើមលាយគ្នា ។ បទថា* ***វិមុត្តិ*** *(ការរួចផុត) បានដល់ វិមុត្តិ គឺ អរហត្តផលនោះឯង ។ វិមុត្តិញ្ញាណទស្សនៈ គឺ បច្ចវេក្ខណញ្ញាណ បច្ចវេក្ខណញ្ញាណនោះឯងជាលោកិយៈ ។*

ចប់អដ្ឋកថា បឋមហិតសូត្រទី ៧

# អដ្ឋកថា ទុតិយហិតសូត្រទី ៨

*(ភិក្ខុបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃ)*

[១៨] *ក្នុងទុតិយហិតសូត្រទី ៨ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សម្តែងដល់ភិក្ខុទ្រុស្តសីល តែជាអ្នកមានសុតៈច្រើន ។*

ចប់អដ្ឋកថា ទុតិយហិតសូត្រទី ៨

# អដ្ឋកថា តតិយហិតសូត្រទី ៩

*(ភិក្ខុមិនបដិបត្តិដើម្បីប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ)*

*[១៩] ក្នុងតតិយសូត្រទី ៩ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ដល់ភិក្ខុអ្នកមានសុតៈតិច ទាំងជាអ្នកទ្រុស្តសីល ។*

ចប់អដ្ឋកថា តតិយហិតសូត្រទី ៩

# អដ្ឋកថា ចតុត្ថហិតសូត្រទី ១០

*(អ្នកបដិបត្តិដើម្បីប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ)*

[២០] ក្នុងចតុត្ថសូត្រទី ១០ ព្រះមានព្រះភាគទ្រង់ត្រាស់ដល់ព្រះទីណាស្រេព ដែលមានសុតៈច្រើន ។

ចប់អដ្ឋកថា ចតុត្ថហិតសូត្រទី ១០

## ចប់ពលវគ្គវណ្ណនាទី ២

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# បញ្ចង្គិកវគ្គវណ្ណនាទី ៣

## អដ្ឋកថា បឋមគារវសូត្រទី ១

*(ហេតុ និងមិនមែនហេតុ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមគារវៈសូត្រទី ១ ដូចតទៅនេះ ៖*

[២១] *បទថា **អសភាគវុត្តិកោ** (មិនមានការប្រព្រឹត្តស្មើ) បានដល់ ប្រកបដោយដំណើរជីវិតដែលមិនប្រព្រឹត្តស្មើគ្នា ។ បទថា **អាភិសមាចារិកំ ធម្មំ** (ធម៌ គឺ អភិសមាចារវត្ត) បានដល់ សីលដែលបញ្ញត្តិជាវត្តប្រតិបត្តិ ។ បទថា **សេក្ខំ ធម្មំ** (សេក្ខធម៌) បានដល់ សីលដែលជាវត្តប្រតិបត្តិរបស់ព្រះសេក្ខៈ ។ បទថា **សីលានិ** (សីលទាំងឡាយ) បានដល់ មហាសីល ៤ ។ បទថា **សម្មាទិដ្ឋឹ** (សម្មាទិដ្ឋិ) បានដល់ សម្មាទិដ្ឋិថ្នាក់វិបស្សនា ។ បទថា **សម្មាសមាធឹ** (សម្មាសមាធិ) បានដល់ មគ្គសមាធិ និងផលសមាធិ ។ ក្នុងសូត្រនេះ ទ្រង់ត្រាស់សីលជាដើមលាយគ្នា ។*

ចប់អដ្ឋកថា បឋមគារវសូត្រទី ១

# អដ្ឋកថា ទុតិយគារវសូត្រទី ២

## (បាន: និងមិនមែនបាន:)

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយគារវសូត្រទី ២ ដូចតទៅនេះ ៖*

[២២] *បទថា* ***សីលក្ខន្ធំ (សីលក្ខន្ធ)*** *បានដល់ កងសីល ។ សូម្បីក្នុងពីរបទដ៏សេស ក៏ន័យនេះឯងដូចគ្នា ។ តែត្រាស់ខន្ធសូម្បី ៣ យ៉ាងទាំងនេះលាយគ្នា ។*

ចប់អដ្ឋកថា ទុតិយគារវសូត្រទី ២

# អដ្ឋកថា ឧបក្កិលេសសូត្រទី ៣

## *(ឧបក្កិលេស ៥)*

*គប្បីជ្រាបវិនិច្ឆ័យ ក្នុងឧកិលេសសូត្រទី ៣ ដូចតទៅនេះ ៖*

[២៣] *បទថា **ន ច បភស្សរំ (មិនមានរស្មីផង)** គឺ មិនស្វាងស្វៃ ។ បទថា **បភង្គុ ច (ជារបស់ប្រេះធាផង)** គឺ មានសភាពពុកផុយ ។ បទថា **អយោ (ដែក)** គឺ លោហៈខ្មៅ ។ បទថា **លោហំ (ស្ពាន់)** បានដល់ លោហៈដ៏សេស វៀរលោហៈ ៤ យ៉ាង ដែលត្រាស់ទុកហើយក្នុងទីនេះ ។ បទថា **សជ្ឈំ (ប្រាក់)** បានដល់ ប្រាក់ ។ បទថា **ចិត្តស្ស (របស់ចិត្ត)** បានដល់ កុសលចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ សួរថា ឧបក្កិលេសរមែងមានដល់កុសលចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៣ លើកទុកចុះ នឹងមានដល់លោកុត្តរចិត្ត បានយ៉ាងណា ។ ឆ្លើយថា ដោយមិនឲ្យកុសលចិត្តកើតឡើង ។ ឧបក្កិលេសទាំងឡាយ មិនឲ្យកុសលចិត្តកើតឡើងដោយចំណែកណា ឈ្មោះថា ឧបក្កិលេសទាំងឡាយក៏រមែងមានទាំងលោកិយកុសលចិត្តនឹងលោកុត្តរកុសលចិត្ត ដោយចំណែកនោះឯង ។ បទថា **បភង្គុ ច (ជាចិត្តប្រេះធាផង)** បានដល់ មានសភាពប្រេះបែកខ្ទេចខ្ទីទៅក្នុងអារម្មណ៍ ។*

បទថា *សម្មាសមាធិយតិ អាសវានំ ខយាយ (តម្កល់មាំដើម្បីការអស់ទៅ អាសវៈផង)* បានដល់ រមែងតាំងមាំដោយហេតុការណ៍ គឺ ដើម្បីប្រយោជន៍ដល់ព្រះអរហត្ត ពោលគឺ ការអស់ទៅនៃអាសវៈទាំងឡាយ ។ ដោយហេតុត្រឹមតែប៉ុណ្ណេះ ទ្រង់សម្តែងដល់ព្រះខីណាស្រពដែលជម្រះចិត្តឲ្យហ្មត់ចត់ហើយតាំងនៅក្នុងអរហត្តផល ។ ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងការធ្វើឲ្យជាក់ច្បាស់ ដោយអភិញ្ញារបស់ព្រះខីណាស្រពនោះ ទើបត្រាស់បទជាមានអាទិ៍ថា *យស្ស យស្ស ច (ធម៌ណាៗ)* ដូច្នេះ បទទាំងនោះ មានសេចក្តីងាយយល់ហើយ ។

ចប់អដ្ឋកថា ឧបក្កិលេសសូត្រទី ៣

# អដ្ឋកថា ទុស្សីលសូត្រទី ៤

*(ទោសនៃសេចក្តីទ្រុស្តសីល និងគុណនៃការមានសីល)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុស្សីលសូត្រទី ៤ ដូចតទៅនេះ ៖*

*[២៤] បទថា **ហតូបនិសោ** (ធម៌មានឧបនិស្ស័យដាច់) បានដល់ មានឧបនិស្ស័យ គឺ កម្លាត់ហេតុ ។ បទថា **យថាភូតញាណទស្សនំ** (យថា-ភូតញ្ញាណទស្សនៈ) បានដល់ វិបស្សនាទន់ខ្ចី ចាប់តាំងពីនាមរូបបរិច្ឆេទ-ញាណទៅ ។ បទថា **និព្វិទា វិរាគោ** (កាលបើនិព្វិទាវិរាគៈមិនមាន) បានដល់ និព្វិទា គឺ សេចក្តីនឿយណាយ និងវិរាគៈ គឺ សេចក្តីប្រាសចាក តម្រេក ។ ក្នុងពីរបទនោះ និព្វិទា ជាវិបស្សនាមានកម្លាំង ។ វិរាគៈ ជាមគ្គ ។ បទថា **វិមុត្តិញាណទស្សនំ** (វិមុត្តិញ្ញាណទស្សនៈ) បានដល់ ផលវិមុត្តិ និងបច្ចវេក្ខណញ្ញាណ ។*

ចប់អដ្ឋកថា ទុស្សីលសូត្រទី ៤

# អដ្ឋកថា អនុគ្គហិតសូត្រទី ៥

## (ធម៌ដែលទំនុកបម្រុងសម្មាទិដ្ឋិ)

*គប្បីជ្រាបវិនិច្ឆ័យក្នុង អនុគ្គហិតសូត្រទី ៥ ដូចតទៅនេះ ៖*

*[២៥] បទថា* ***សម្មាទិដ្ឋិ*** *(សម្មាទិដ្ឋិ) បានដល់ សម្មាទិដ្ឋិថ្នាក់វិបស្សនា ។ ក្នុងបទថា* ***ចេតោវិមុត្តិផលា*** *(ធម៌មានចេតោវិមុត្តិជាផល) ជាដើម សមាធិថ្នាក់មគ្គ និងផល ឈ្មោះថា ចេតោវិមុត្តិ ។ ផលញាណ ឈ្មោះថា បញ្ញាវិមុត្តិ ។ បទថា* ***សីលានុគ្គហិតា*** *(សីលជួយទំនុកបម្រុង) បានដល់ សីលដែលអនុគ្រោះហើយ គឺ តាមរក្សាហើយ ។ បទថា* ***សុត្តានុគ្គហិតា*** *(សុតៈជួយទំនុកបម្រុង) បានដល់ ដែលបានដល់ពាហុសច្ចៈទំនុកបម្រុងហើយ ។ បទថា* ***សាកច្ឆានុគ្គហិតា*** *(សាកច្ឆាជួយទំនុកបម្រុង) បានដល់ ធម្មសាកច្ឆាទំនុកបម្រុងហើយ ។ បទថា* ***សមថានុគ្គហិតា*** *(សមថៈជួយទំនុកបម្រុង) បានដល់ ឯកគ្គតាចិត្តទំនុកបម្រុងហើយ ។ តែដើម្បីឲ្យសេចក្តីនេះជាក់ច្បាស់ គប្បីលើកឧបមា ដូចជាបុរសដាំគ្រាប់ស្វាយផ្អែម ដាំទុកដោយជុំវិញស្រែ ស្រោចទឹកតាមកាលវេលាដ៏សមគួរផង ជម្រះស្មៅតាមកាលវេលាដ៏សមគួរផង នាំសត្វចេញទៅតាមកាលវេលាដ៏សមគួរផង*

ទាញសរសៃពីងពាងចេញតាមកាលវេលាដ៏សមគួរផង ហើយមើលថែដើមស្វាយផង ។ សម្មាទិដ្ឋិថ្នាក់វិបស្សនា គប្បីឃើញ ដូចការដាំគ្រាប់ស្វាយផ្អែមរបស់បុរសនោះ សីលដែលឧបត្ថម្ភ គប្បីឃើញដូចការដាំស្វាយជុំវិញស្រែ សុតៈទំនុកបម្រុង ដូចការស្រោចទឹក ការសន្ទនាធម៌ទំនុកបម្រុង ដូចជាការជម្រះស្មៅ ឯសមថៈទំនុបម្រុង ដោយការកម្ចាត់អន្តរាយរបស់ញាណ និងវិបស្សនា ដូចជាការនាំសត្វចេញ ការដែលវិបស្សនាមានកម្លាំងឧបត្ថម្ភ ក៏ដូចជាការទាញសរសៃពីងពាងចេញ ការដែលសម្មាទិដ្ឋិមានមូលពោលគឺ គុណ មានសីលជាដើមទាំងនេះឧបត្ថម្ភហើយ ដោយអំណាចការសម្រេចមគ្គមួយរំពេច ហើយជំនួយដល់ចេតោវិមុត្តិផល និងបញ្ញាវិមុត្តិ-ផល គប្បីឃើញដូចជាដើមឈើ ដែលបុរសថែរក្សាយ៉ាងនេះហើយ រមែងចម្រើនដុះលូតលាស់ហើយ យ៉ាងណា ការឲ្យផលបានធាប់រហ័ស ក៏យ៉ាងនោះដែរ ។

ចប់អដ្ឋកថា អនុគ្គហាតសូត្រទី ៥

# អដ្ឋកថា វិមុត្តិសូត្រទី ៦

## (ហេតុនៃវិមុត្តិ ៥ ប្រការ)

*គប្បីជ្រាបវិនិច្ឆ័យក្នុង វិមុត្តិសូត្រទី ៥ ដូចតទៅនេះ ៖*

*[២៦] បទថា* ***វិមុត្តាយតនានិ (វិមុត្តាយតនៈ)*** *បានដល់ ហេតុនៃការរួចផុត ។ បទថា* ***យត្ថ (ជាហេតុ)*** *បានដល់ ហេតុនៃវិមុត្តិណា ។ បទថា* ***សត្ថា ធម្មំ ទេសេតិ (ព្រះសាស្តា... សំដែងធម៌)*** *បានដល់ ព្រះសាស្តាទ្រង់សម្តែងសច្ចធម៌ ៤ ។ បទថា* ***អត្ថប្បដិសំវេទិនោ (រមែងដឹងច្បាស់នូវអដ្ឋកថា)*** *បានដល់ ដឹងសេចក្តីនៃព្រះបាលី ។ បទថា* ***ធម្មប្បដិសំវេទិនោ (ដឹងច្បាស់នូវធម៌)*** *បានដល់ ដឹងព្រះបាលី ។ បទថា* ***បាមុជ្ជំ (បាមុជ្ជៈ)*** *បានដល់ បីតិទន់ខ្សោយ ។ បទថា* ***បីតិ (បីតិ)*** *បានដល់ បីតិមានកម្លាំងដែលជាអាការត្រេកអរ ។ បទថា* ***កាយោ (កាយ)*** *បានដល់ នាមកាយ ។ បទថា* ***បស្សម្ភតិ (រមែងស្ងប់)*** *បានដល់ រមែងស្ងប់រម្ងាប់ ។ បទថា* ***សុខំ វេទេតិ (សុខវេទនា)*** *បានដល់ រមែងទទួលសេចក្តីសុខ ។ បទថា* ***ចិត្តំ សមាធិយតិ (តែងតម្កល់មាំ)*** *បានដល់ ចិត្តដែលតាំងមាំដោយសមាធិថ្នាក់អរហត្តផល ។ ពិតហើយ ភិក្ខុនេះកាលស្តាប់ធម៌នោះ រមែងសម្រេចឈាន*

វិបស្សនា មគ្គ និងផល ក្នុងកាលដែលឈានជាដើមប្រាកដហើយ កាលភិក្ខុនោះដឹងយ៉ាងនេះ បីតិរមែងកើតឡើង ក្នុងចន្លោះបីតិនោះ ភិក្ខុនោះក៏មិនបានរាយមាយចិត្ត បំពេញឧបចារកម្មដ្ឋាន ចម្រើនវិបស្សនាហើយ រមែងសម្រេចព្រះអរហត្ត ។ ទ្រង់សំដៅដល់ព្រះអរហត្តនោះ ទើបត្រាស់ថា **ចិត្តំ សមាធិយតិ** ដូច្នេះ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ តែនេះជាសេចក្ដីផ្សេងគ្នា ។ បទថា **សមាធិ និមិត្តំ (សមាធិនិមិត្តៈ)** បានដល់សមាធិក្នុងអារម្មណ៍ ៣៨ យ៉ាង ណាមួយ ឈ្មោះថា សមាធិនិមិត្ត ។ សូម្បីក្នុងបទជាដើមថា **សុគ្គហិតំ ហោតិ (រៀនយកដោយល្អ)** សេចក្ដីថា កម្មដ្ឋាន ដែលភិក្ខុរៀនកម្មដ្ឋានក្នុងសម្នាក់អាចារ្យ ជាការរៀនហើយដោយល្អ តម្កល់ចិត្តទុកដោយល្អ ចងចាំទុកដោយល្អ ។ បទថា **សុប្បដិវិទ្ធំ បញ្ញាយ (យល់ច្បាស់ដោយល្អដោយបញ្ញា)** បានដល់ ធ្វើឲ្យប្រច័ក្សដោយបញ្ញា ។ បទថា **តស្មឹ ធម្មេ (ក្នុងធម៌នោះ)** បានដល់ ក្នុងធម៌ គឺ ព្រះបាលីដែលមកហើយនៃកម្មដ្ឋាននោះ ។ ក្នុងសូត្រនេះត្រាស់ហេតុនៃវិមុត្តិ សូម្បីទាំង ៥ ឲ្យដល់អរហត្ត ដោយប្រការដូច្នេះឯង ។

ចប់អដ្ឋកថា វិមុត្តិសូត្រទី ៦

# អដ្ឋកថា សមាធិសូត្រទី ៧

## (ញាណ ៥ យ៉ាង)

*គប្បីជ្រាបវិនិច្ឆ័យក្នុង សមាធិសូត្រទី ៥ ដូចតទៅនេះ ៖*

[២៧] បទថា **អប្បមាណំ (រកប្រមាណមិនបាន)** បានដល់ លោកុត្តរសមាធិ ដែលវៀរចាកធម៌ដែលកំណត់ប្រមាណបាន ។ បទថា **និបកា បតិស្សតា (មានបញ្ញារក្សាខ្លួន មានសតិតាំងមាំ)** បានដល់ ជាអ្នកប្រកបហើយដោយបញ្ញារក្សាខ្លួន និងសតិ ។ បទថា **បញ្ច ញាណានិ (ញាណ ៥ យ៉ាង)** បានដល់ បច្ចវេក្ខណញាណ ៥ ។ បទថា **បច្ចត្តញ្ញេវ ឧប្បជ្ជន្តិ (រមែងកើតឡើងចំពោះខ្លួន)** បានដល់ រមែងកើតឡើងក្នុងខ្លួនឯងប៉ុណ្ណោះ ។ ក្នុងបទជាដើមថា **អយំ សមាធិ បច្ចុប្បន្នសុខោ ចេវ (សមាធិនេះឯងមានសុខក្នុងបច្ចុប្បន្ន)** លោកប្រាថ្នាយកអរហត្តផលសមាធិ ។ អាចារ្យពួកខ្លះពោលថា **មគ្គសមាធិ** ដូច្នេះក៏មាន ។ ពិតណាស់ សមាធិនោះឈ្មោះថា ជាសុខក្នុងបច្ចុប្បន្ន ព្រោះជាសុខក្នុងខណៈដែលចិត្តនៃបនិត្យក្នុងអារម្មណ៍ ។ សមាធិមុន ៗ មានសុខជាវិបាកក្នុងអនាគត ព្រោះជាបច្ច័យដល់សមាធិសុខក្រោយៗ ដូច្នេះឯង ។ សមាធិ ឈ្មោះថា **អរិយោ (ជាអរិយៈ)** ព្រោះឆ្ងាយ

ចាកកិលេសទាំងឡាយ ។ ឈ្មោះថា **និរាមិសោ** (ព្រោះប្រាសចាកអាមិសៈ) បានដល់ មិនមានចំណែកនៃកាម ចំណែកនៃវដ្ដៈ ចំណែកនៃលោក ។ បទថា **អកាបុរិសសេវិតោ** (បុរសល្អតែងសេពគប់) ព្រោះជាសមាធិដែលមហាបុរស មានព្រះពុទ្ធជាដើមសេពហើយ ។ បទថា **សន្តោ** (ស្ងប់) ព្រោះស្ងប់អវយវៈ ពោលគឺ កាយ ស្ងប់ក្នុងអារម្មណ៍ និងប្រាសចាកសេចក្ដីខ្វល់ខ្វាយដោយអំណាចសរ គឺ កិលេស ។ ឈ្មោះថា **បណីតោ** (ល្អិតម៉ដ្ឋចត់) ព្រោះអត្ថថា មិនក្ដៅក្រហាយ ។ បទថា **បដិប្បស្សទ្ធិលទ្ធោ** (បានសេចក្ដីស្ងប់រម្ងាប់) ព្រោះបានស្ងប់កិលេស ឬបានដល់នូវសេចក្ដីស្ងប់រម្ងាប់កិលេស ពាក្យថា ស្ងប់រម្ងាប់ហើយ និងសេចក្ដីស្ងប់រម្ងាប់នេះ មានសេចក្ដីដូចគ្នា ។ម្យ៉ាងវិញទៀត ឈ្មោះថា បានសេចក្ដីស្ងប់រម្ងាប់ ព្រោះជាអ្នកមានកិលេសស្ងប់រម្ងាប់ហើយ គឺ អ្នកវៀរចាកកិលេសបានហើយ ។ បទថា **ឯកោទិភាវាធិគតោ** (បាននូវឯកគ្គតារម្មណ៍) ព្រោះសម្រេចដោយភាពជាធម៌ឯកកើតឡើង ឬសម្រេចដោយមានធម៌ឯកកើតឡើង ។ បទថា **ន ច សសង្ខារនិគ្គយ្ហវារិតប្បត្តោ** (តែមិនទាន់បានដល់នូវការសង្កត់សង្កិន ឬហាមឃាត់កិលេសដោយសេចក្ដីព្យាយាម) ព្រោះមិនមានចិត្ត ពោលគឺ

សេចក្តីព្យាយាម គឺ ដែលមានសម្បយោគៈ ហាមឃាត់ធម៌ដែលជាសឹកសត្រូវ ហាមកិលេសហើយ ដូចសមាធិដែលមិនជំនាញរបស់បុគ្គលដែលនៅមានអាសវៈ ភិក្ខុកាលចូលសមាធិនោះ ឬចេញចាកសមាធិនោះ រមែងចូលមានសតិ ចេញមានសតិ ព្រោះជាអ្នកបរិបូណ៌ដោយសមាធិ ឬមានសតិពេលចូល ពេលចេញ ដោយតាមកាលដែលកំណត់ទុក ព្រោះដូច្នោះ បច្ចយប្បច្ចវេក្ខណញ្ញាណ (ការពិចារណាឃើញបច្ច័យ) នេះណា រមែងកើតឡើងចំពោះខ្លួនឯង ក៏ដូច្នោះ ដល់ភិក្ខុអ្នកពិចារណាសមាធិយ៉ាងនេះថា សមាធិមានសុខក្នុងបច្ចុប្បន្ន និងមានសុខជាវិបាកតទៅ បច្ចយប្បច្ច-វេក្ខណញ្ញាណនោះ ក៏ជាញាណមួយ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ ញាណ ៥ យ៉ាងនេះ រមែងកើតចំពោះខ្លួន ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា សមាធិសូត្រទី ៧

# អដ្ឋកថា អង្គិកសូត្រទី ៨

## (ការចម្រើនសម្មាសមាធិមានអង្គ ៥)

គប្បីជ្រាបវិនិច្ឆ័យក្នុង អង្គិកសូត្រទី ៨ ដូចតទៅនេះ ៖

[២៨] បទថា **អរិយស្ស (ដែលប្រសើរ)** បានដល់ នៅឆ្ងាយចាកកិលេសដែលលុះហើយដោយវិក្ខម្ភនប្បហាន (ការគ្របសង្កត់ទុក ។ បទថា **ភាវនំ ទេសេស្សាមិ (តថាគតនឹងសម្តែងភាវនា)** សេចក្តីថា តថាគតនឹងប្រកាសការកើតឡើងនៃតណ្ហា ។ បទថា **ឥមមេវ កាយំ (កាយនេះឯង)** បានដល់ ករជកាយនេះ ។ បទថា **អភិសន្ទេតិ (ឲ្យជ្រួតជ្រាប)** បានដល់ ជោគ គឺ ផ្សព្វផ្សាយ គឺ ធ្វើបីតិ និងសុខឲ្យប្រព្រឹត្តទៅទូទាំងករជកាយ ។ បទថា **បរិសន្ទេតិ (ហូរទៅ)** បានដល់ ហូរទៅដោយជុំវិញ ។ បទថា **បរិបូរេតិ (បរិបូណ៌)** បានដល់ ពេញ ដូចថង់ដែលពេញដោយខ្យល់ ។ បទថា **បរិប្ផរតិ (ជ្រួតជ្រាប)** បានដល់ ផ្សាយទៅដោយជុំវិញ ។ បទថា **សព្វាវតោ កាយស្ស (នៃកាយ.... ទាំងអស់)** បានដល់ រាងកាយគ្រប់ចំណែករបស់ភិក្ខុនោះ ។ ទីណាៗ សូម្បីតែតិចតួច ក៏ផ្សាយទៅតាមស្បែក សាច់ និងឈាម ក្នុងទីប្រព្រឹត្តទៅនៃសន្តតិរបស់ឧបាទិន្នកវត្ថុដែល

មានចិត្តគ្រប់គ្រង ឈ្មោះថា សុខដែលកើតពីបឋមឈាន ប៉ះពាល់ សម្ផស្ស មិនមាន ។ បទថា **ទក្ខោ** បានដល់ ថ្លាត គឺ អាចប្រកបផ្សំកម្ទេចផង់ សម្រាប់ងូតទឹក ។ បទថា **កំសថាលេ (ក្នុងភាជនៈសំរឹត)** បានដល់ ភាជនៈ ដែលធ្វើដោយលោហៈណាមួយ ។ តែភាជនៈធ្វើដោយដី មិនជាថាវរៈ កាល ដាក់កម្ទេចផង់ងូតទឹក រមែងបែកបាន ព្រោះដូច្នោះ ព្រះមានព្រះភាគទ្រង់ ទើបមិនសម្ដែងភាជនៈដីនោះ ។ បទថា **បរិប្ផោសកំ បរិប្ផោសកំ (ដែល ប្រោះព្រំដោយទឹក)** បានដល់ ស្រោចទឹកហើយ ។ បទថា **សន្នេយ្យ (សូន្យ ជាដុំ)** បានដល់ កាន់ថាសសំរិតដោយដៃឆ្វេង ទឹកល្មមប្រមាណដោយដៃ ស្ដាំ ហើយកម្ទេចផង់ធ្វើឲ្យជាដុំ ។ បទថា **ស្នេហានុគតា (ក៏ស្អិតចូលគ្នា ស្អិតល្មួត)** បានដល់ ត្រូវជ័រទឹកជ្រួតជ្រាប ។ បទថា **សិនេហបរេតា (ក៏ ស្អិតជាប់ចូលគ្នា)** បានដល់ ត្រូវជ័រទឹកជ្រួតជ្រាបទៅដោយជុំវិញ ។ បទថា **សមន្តរពាហិរា (ទាំងខាងក្នុង និងខាងក្រៅ)** សេចក្ដីថា ត្រូវជ័រទឹកផ្សព្វផ្សាយ ទៅទូទាំងសរព្វាង្គកាយទាំងខាងក្នុង និងខាងក្រៅ ។ បទថា **ន ច បគ្ឃរតិ (មិនបានរាត់រាយខ្ចាត់ខ្ចាយចេញឡើយ)** សេចក្ដីថា តំណក់ទឹកតែមួយតំណក់ នឹងមិនហូរចេញ អាចនឹងជាប់ដៃទាំង ២ ក៏បាន ធ្វើជាជ្រួញក៏បាន ។ គប្បី

ជ្រាបវិនិច្ឆ័យក្នុងឧបមាសេចក្ដីសុខ ក្នុងទុតិយឈានដូចតទៅ ។ បទថា **ឧព្ភិតោទកោ (មានទឹកជោរឡើង)** បានដល់ ទឹក គឺ ទឹកដែលមិនហូរចុះខាងក្រោមតែហូរឡើង អធិប្បាយថា គឺ ទឹកដែលកើតឡើងខាងក្នុងនោះឯង ។ បទថា **អាយមុខំ (ផ្លូវដែលទឹកនឹងហូរមកបាន)** បានដល់ ផ្លូវទឹកហូរមក ។ បទថា **ទេវោ (ភ្លៀង)** បានដល់ មេឃភ្លៀង ។ បទថា **កាលេន កាលំ (តាមកាលវេលា)** បានដល់ រាល់កន្លះខែ ឬគ្រប់ ១០ ថ្ងៃ ។ បទថា **ធារំ (ធារ)** បានដល់ ទឹកភ្លៀង ។ បទថា **នានុប្បវេច្ឆេយ្យ (មិនធ្លាក់ភ្លៀងបរិបូណ៌)** សេចក្ដីថា មិនគប្បីបង្អុរ គឺ មិនគប្បីភ្លៀង ។ បទថា **សីតា វារិធារា ឧព្ភិជ្ជិត្វា (ផ្សព្វផ្សាយដោយទឹកដ៏ត្រជាក់)** សេចក្ដីថា ខ្សែទឹកភ្លៀងធ្វើអន្លង់ទឹកត្រជាក់ឲ្យពេញ ក៏ទឹកដែលជោរឡើងហើយ ហូរចុះខាងក្រោម រមែងធ្វើអន្លង់ទឹកឲ្យបែក ឲ្យរញ្ជួយ ទឹកដែលហូរមកពីទិសទាំង ៤ រមែងធ្វើទឹកឲ្យរញ្ជួយដោយស្លឹកឈើ ស្មៅ ឧស កំណាត់ឈើចាស់ៗ ជាដើម ទឹកភ្លៀង រមែងធ្វើឲ្យទឹករញ្ជួយដោយពពុះទឹក ដែលហូរធ្លាក់ពីខ្សែទឹកភ្លៀង តែទឹកស្ងប់ដូចនិម្មិតដោយឫទ្ធិ ហូរទៅកាន់តំបន់នេះ មិនហូរទៅកាន់តំបន់នេះ ដូច្នេះមិនមាន គឺ ឈ្មោះថា ប្រទេសដែលទឹកនឹងមិនពាល់

ត្រូវមិនមាន ។ ក្នុងឧបមានោះ ករជកាយដូចអន្លង់ទឹក សេចក្តីសុខក្នុងទុតិយឈានដូចទឹក ។ បទដ៏សេស គប្បីជ្រាបដោយន័យមុននុ៎ះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងប្រការឧបមា សេចក្តីសុខក្នុងតតិយឈាន ។ ឈ្មោះថា **ឧប្បលានិ (ផ្កាឧប្បល)** ព្រោះអាទិ៍ថា មានផ្កាឧប្បល ។ សូម្បីក្នុងពីរបទដ៏សេស ក៏ន័យនេះដូចគ្នា ។ ក្នុងឧបមានេះ បណ្តាឈូកសឈូកក្រហម ព្រលិតណាមួយ ឈ្មោះ ឧប្បលទាំងអស់ ឈូកមានត្របក ១០០ សន្លឹក ឈ្មោះបុណ្ឌរិក ឈូកមានត្របក ១០០ សន្លឹក ឈ្មោះបទុម ឈូកដែលកំណត់ត្របក ឬសូម្បីមិនមានត្របកពណ៌ស ឈ្មោះបទុម ពណ៌ក្រហម ឈ្មោះបុណ្ឌរិក នេះជាការវិនិច្ឆ័យក្នុងឧបមានេះ ។ បទថា **ឧទកានុគ្គតានិ (មិនទាន់លូតផុតអំពីទឹក)** បានដល់ ឈូកមិនទាន់ផុតពីទឹក ។ បទថា **អន្តោនិមុគ្គបោសិនី (ចម្រើនក្នុងទឹក)** បានដល់ ឈូកដែលលិចនៅក្នុងទឹក ទឹករក្សា គឺ ញាំងឲ្យចម្រើន ។ បទដ៏សេសគប្បីជ្រាបដោយន័យមុននុ៎ះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងឧបមាសេចក្តីសុខក្នុងចតុត្ថឈាន ។ ក្នុងបទថា **បរិសុទ្ធេន ចេតសា បរិយោទាតេន (ដោយចិត្តដែលបរិសុទ្ធផូរផង់)** នេះ គប្បីជ្រាបថា ឈ្មោះថា បរិសុទ្ធ ព្រោះអត្ថថា មិនមានឧបក្កិលេស

ឈ្មោះថា ផ្សព្វផ្សាយ ព្រោះអត្ថថា ប៉ះផ្សព្វផ្សាយ ។ បទថា **ឧទកេន វិគ្គេន** *(ដោយសំពត់សស្អាត)* នេះ ព្រះមានព្រះភាគ ត្រាស់ដល់ការផ្សាយជ្រួតជ្រាបទៅនៃឧតុ ព្រោះសំពត់ស្មោកគ្រោកនឹងមិនមានការផ្សាយជ្រួតជ្រាបទៅនៃឧតុ ប្រើប្រាស់សំពត់ដែលស្អាតក្នុងខណៈនោះ ការផ្សាយជ្រួតជ្រាបទៅនៃឧតុ រមែងមានកម្លាំង ។ ក៏ព្រោះឧបមានេះ ករជកាយ ដូចសំពត់ សេចក្ដីសុខក្នុងចតុត្ថឈាន ដូចការផ្សាយជ្រួតជ្រាបទៅនៃឧតុ ព្រោះដូច្នោះ គប្បីឃើញចំនុចក្នុងសេចក្ដីឧបមានេះ យ៉ាងនេះថា កាលបុរសងូតទឹកជម្រះកាយល្អហើយ អង្គុយដណ្ដប់សំពត់ស្អាតរហូតដល់សីសៈ ឧណ្ហភូមិរមែងផ្សាយទូទៅដល់សំពត់ចាកពីសរីរៈ មិនមានសល់ចន្លោះណាៗ ផ្ទាំងសំពត់នឹងមិនពាល់ត្រូវរមែងមិនមាន មិនមានចន្លោះទំនេរណាៗ ដែលករជកាយរបស់ភិក្ខុមិនពាល់ត្រូវនូវសុខក្នុងចតុត្ថឈានមិនមាន ដូច្នោះ គប្បីឃើញសេចក្ដីក្នុងឧបមានេះ ដោយប្រការដូច្នេះ ។ម្យ៉ាងទៀត ចិត្តក្នុងចតុត្ថ-ឈានប៉ុណ្ណោះ ប្រៀបដូចសំពត់ រូបដែលមានចិត្តក្នុងចតុត្ថឈាននោះជាសមុដ្ឋាន ដូចការផ្សាយទៅនៃឧណ្ហភូមិ គប្បីឃើញ សេចក្ដីក្នុងឧបមានេះយ៉ាងនេះថា ឧបមាកាលសំពត់ស សូម្បីមិនពាល់ត្រូវកាយក្នុងចំណែកខ្លះៗឧណ្ហភូមិដែលមានកាយជាសមុដ្ឋាន ក៏ឈ្មោះថា ពាល់ត្រូវកាយគ្រប់កន្លែង

នោះឯង យ៉ាងណា សុខុមរូប ដែលមានចតុត្ថឈានជាសមុដ្ឋាន ឈ្មោះថា ពាល់ត្រូវកាយរបស់ភិក្ខុគ្រប់កន្លែង ក៏ដូច្នោះឯង ។

បទថា **បច្ចវេក្ខណនិមិត្តំ** (បច្ចវេក្ខណនិមិត្ត) បានដល់ បច្ចវេក្ខណ-ញាណនុ៎ះឯង ។ បទថា **សុគ្គហិតំ ហោតិ (រមែងរៀនមកដោយល្អ)** សេចក្តីថា ឈាន វិបស្សនា និងមគ្គ ជាធម៌ដែលភិក្ខុនោះរៀនមកហើយដោយល្អ យ៉ាងណា បច្ចវេក្ខណនិមិត្ត ក៏ភិក្ខុនោះកាន់យកហើយដោយល្អ ដោយបច្ចវេក្ខណនិមិត្តជាប់តៗ គ្នា នុ៎ះឯង ដូច្នោះ ។ បទថា **អញ្ញោ វា អញ្ញំ (អ្នកដទៃគប្បីពិចារណាឃើញថាអ្នកដទៃ)** បានដល់ អ្នកដទៃម្នាក់ ពិចារណាមើលអ្នកដទៃម្នាក់ទៀត ។ ព្រោះខ្លួន រមែងមិនប្រាកដដល់ខ្លួនឯង ។ បទថា **ឋិតោ វា និសិន្នំ (អ្នកឈរសំឡឹងមើលអ្នកអង្គុយ)** បានដល់ អ្នកអង្គុយក៏រមែងប្រាកដសូម្បីដល់អ្នកឈរ ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគទើបត្រាស់ទុកយ៉ាងនេះ ។ សូម្បីក្នុងបទដ៏សេសក៏ន័យនេះដូចគ្នា ។

បទថា **ឧទកមណិកោ (ឆ្នាំងទឹក)** បានដល់ ពាងទឹកដែលមានខ្សែរុំចង ។ បទថា **សមតិត្តិកោ (ពេញស្មើនឹងមាត់)** បានដល់ ពេញប្រៀប ។ បទថា **កាកបេយ្យ (ល្មមសត្វក្អែកឱនផឹកបាន)** បានដល់ ក្អែកទំត្រង់មាត់

ស្រះមិនឱន ក៏ជីកបាន ។ បទថា *សុភូមិយំ (មានផែនដីរាបស្មើ)* បានដល់ ផែនដីរាប ។ ក៏ផ្ទៃដីស្អាត ឈ្មោះថា ផ្ទៃដីរាប មកក្នុងបាលីនេះថា បុគ្គល គប្បីដាំពូជទាំងឡាយ លើផ្ទៃដីដែលរាបស្មើ ទីស្រែល្អ ដែលប្រាសចាក ជន្លត់ ។ បទថា *ចាតុម្មហាបថេ (ក្នុងផ្លូវទាំង ៤)* បានដល់ ក្នុងទីផ្លូវធំ ពីរខ្វែងគ្នាកាត់គ្នា ។ បទថា *អាជញ្ញរថោ (រថសេះ)* បានដល់ រថទឹមដោយ សេះដែលទូន្មានហើយ ។ បទថា *ឱសតប្បតោទោ (តែងមានរំពាត់ផ្គងទុក)* សេចក្តីថា ជន្ទួញដែលព្យួរ តាំងទុកខាងស្តាំ ដោយអាការដែលសារថីឡើង ឈរលើរថអាចកាន់យកបាន ។ បទថា *យោគាចរិយោ (អាចារ្យបង្ហាត់ សេះ)* ប្រែថា អាចារ្យទូន្មានសេះ ។ ឈ្មោះថា *អស្សទម្មសារថិ (សារថី អ្នកទូន្មានសេះ)* ព្រោះអាទិ៍ថា អាចារ្យអ្នកទូន្មានសេះនុ៎ះឯង ញ៉ាំងសេះ ដែលទូន្មានឲ្យរត់ទៅ ។ បទថា *យេនិច្ឆកំ (តាមផ្លូវដែលប្រាថ្នា)* បានដល់ ប្រាថ្នានឹងទៅដោយផ្លូវណាៗ ។ បទថា *យទិច្ឆកំ (ទៅកាន់ទីដែលត្រូវការ)* បានដល់ ប្រាថ្នាការទៅ ។ បទថា *សារេយ្យ (គប្បីបររថឲ្យដើរទៅមុខ)* បានដល់ គប្បីបរត្រង់ទៅខាងមុខ ។ បទថា *បច្ចាសារេយ្យ (បរត្រឡប់ មកក្រោយ)* បានដល់ គប្បីដេញត្រឡប់ ។ ព្រះដ៏មានព្រះភាគ ត្រាស់

*សមាបត្តិបរិកម្មដោយអង្គ ៥ ខាងដើមយ៉ាងនេះហើយ ទ្រង់សម្ដែងអានិសង្ស នៃសមាបត្តិដែលជំនាញដោយឧបមា ៣ ទាំងនេះ ឥឡូវនេះ ដើម្បីទ្រង់សម្ដែងលំដាប់នៃអភិញ្ញារបស់ព្រះខីណាស្រព ទើបត្រាស់បទមានជាអាទិ៍ថា **សោ សចេ អាកង្ខតិ** (បើតថាគតប្រាថ្នា) ដូច្នេះ ។ បទទាំងនោះមានសេចក្ដីងាយយល់ហើយ ។*

ចប់អដ្ឋកថា អង្គិកសូត្រទី ៨

# អដ្ឋកថា ចង្កមសូត្រទី ៩

## *(អានិសង្សនៃការចង្រ្កម ៥ ប្រការ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចង្កមសូត្រទី ៩ ដូចតទៅនេះ ៖*

[២៩] *បទថា* **អទ្ធានក្ខមោ ហោតិ** *(គឺជាអ្នកអត់ធន់ក្នុងដំណើរផ្លូវឆ្ងាយ) បានដល់ កាលបុគ្គលដើរផ្លូវឆ្ងាយ គឺ រមែងអត់ធន់បាន ។ បទថា* **បធានក្ខមោ** *(អត់ធន់ក្នុងការព្យាយាម) បានដល់ ជាអ្នកអត់ធន់ក្នុងការព្យាយាម ។ បទថា* **ចង្កមាធិគតោ សមាធិ** *(សមាធិដែលកើតអំពីការចង្រ្កម) បានដល់ សមាធិនៃសមាបត្តិ ៨ ណាមួយ ដែលបុគ្គលអធិដ្ឋានចង្រ្កមបានហើយ ។ បទថា* **ចិរដ្ឋិតិកោ ហោតិ** *(រមែងតាំងនៅអស់កាលយូរ) ប្រែថា តាំងនៅបានយូរ ។ សេចក្តីថា និមិត្តដែលអ្នកឈរកាន់យកកាលអង្គុយក៏វិនាសទៅ និមិត្តដែលអ្នកអង្គុយកាន់យក កាលដេកក៏វិនាសទៅ ចំណែកនិមិត្ត ដែលអ្នកអធិដ្ឋានចង្រ្កមកាន់យកក្នុងអារម្មណ៍ដែលមិនញាប់ញ័រហើយ កាលឈរក្តី អង្គុយក្តី ដេកក្តី រមែងមិនវិនាស ។*

ចប់អដ្ឋកថា ចង្កមសូត្រទី ៩

# អដ្ឋកថា នាគិតសូត្រទី ១០

*(ការមិនជាប់ក្នុងយស និងមិនឲ្យយសជាប់ខ្លួន)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង នាគិតសូត្រទី ១០ ដូចតទៅនេះ ៖*

[៣០] *ឈ្មោះថា* ***ឧច្ចាសទ្ទាមហាសទ្ទា*** *(ឈរស្រែកហៅ និយាយខ្លាំង) ព្រោះឈ្មោះថា ជនទាំងនេះឈ្មោះថា មានសំឡេងឮខ្លាំង ព្រោះឮឡើងទៅខាងលើ ហើយឈ្មោះថា មានសំឡេងច្រើន ព្រោះសំឡេងជាក្រុមពិតណាស់ កាលជនទាំងឡាយ មានក្សត្រិយ៍មហាសាល និងព្រាហ្មណ-មហាសាលជាដើម ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ កាន់យកសក្ការៈជាច្រើននាំគ្នាមក កាលពួកគេនិយាយថា លោកចូរឲ្យឱកាសដល់បុគ្គលឯណោះ ចូរឲ្យកាសដល់បុគ្គលឯណោះដូច្នេះ កាលអ្នកផ្សេងនិយាយគ្នាយ៉ាងនេះថា យើងមិនមានឱកាសមុន សំឡេងក៏ឮខ្លាំង ៗ បទថា* ***កេវដ្ដា មញ្ញេ មច្ឆវិលោបេន្តិ*** *(ហាក់ដូចជាព្រានត្រីដណ្ដើមត្រីគ្នា) បានដល់ ដូចពួកអ្នកនេសាទ ចែកត្រីគ្នា ៗ ពិតហើយ កាលពួកអ្នកនេសាទទាំងនោះ កាន់ជាលដាក់ត្រី ដើរមកក្នុងផ្សារលក់ត្រី រមែងនឹងមានសំឡេងដូច្នេះ របស់ពួកជនអ្នកផ្សេង និយាយគ្នាថា លក់ឲ្យខ្ញុំ លក់ឲ្យខ្ញុំ ដូច្នេះ ៗ*

បទថា **មិឡ្ហសុខំ** (សុខកខ្វក់) បានដល់ សុខមិនស្អាត ។ បទថា **មិទ្ធសុខំ** (សុខក្នុងការដេកលក់) បានដល់ សុខក្នុងការដេក ។ បទថា **លាភសក្ការសិលោកសុខំ** (សុខក្នុងលាភសក្ការៈនិងសេចក្តីសរសើរ) បានដល់ សុខកើតឡើងព្រោះអាស្រ័យលាភសក្ការៈ និងការសរសើរ ។ បទថា **តន្និន្នាវ ភវិស្សន្តិ** (នាំគ្នាតាមទៅក្នុងទីនោះៗ) មានពាក្យអធិប្បាយថា ជនទាំងឡាយនឹងទៅ គឺ នឹងជាប់តាមទៅកាន់ទីកន្លែងដែលព្រះមានព្រះភាគស្តេចទៅហើយនោះឯង ។ បទថា **តថា ហិ ភន្តេ ភគវតោ សីលប្បញ្ញាណំ** (បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះអង្គមានសីល និងប្រាជ្ញា) សេចក្តីថា បានដល់ សីល និងប្រាជ្ញារបស់ព្រះអង្គមានយ៉ាងនេះ ។

បទថា **មា ច មយា យសោ** (សូមកុំឲ្យជួបប្រសព្វនឹងយសបរិវារ) បានដល់ សូម្បីយសក៏កុំរួមទៅជាមួយតថាគតឡើយ ។ បទថា **ឯសោ តស្ស និស្សន្ទោ** (នេះជាអានិសង្សនៃសេចក្តីស្រឡាញ់នោះ) បានដល់ នេះជាផលសម្រេចនៃសេចក្តីមិនស្អាត ។ បទថា **បិយានំ** (សេចក្តីស្រឡាញ់) បានដល់ វត្ថុឲ្យកើតសេចក្តីស្រឡាញ់ ។ បទថា **ឯសោ តស្ស និស្សន្ទោ** (នេះជាអានិសង្សនៃការជ្រោកជ្រាកនោះ) បានដល់ នេះជាផលសម្រេចនៃរបស់គួរស្រឡាញ់ ។ បទថា **អសុភនិមិត្តានុយោគំ** (ការខ្មីឃរអើមក្នុង

*អសុភនិមិត្ត)* បានដល់ ប្រកបរឿយៗ ក្នុងអសុភកម្មដ្ឋាន ។ បទថា *សុភនិមិត្តេ (ក្នុងសុភនិមិត្ត)* បានដល់ ឥដ្ឋារម្មណ៍ដែលជាទីតាំងនៃរាគៈ ។ បទថា *ឯសោ តស្ស និស្សន្ទោ (នេះជាអានិសង្សនៃសេចក្តីព្យាយាមនោះ)* បានដល់ នេះជាផលសម្រេចនៃការប្រកបរឿយៗ ក្នុងអសុភនិមិត្តនោះ ។ ក្នុងសូត្រនេះ ត្រាស់វិបស្សនាក្នុងឋានៈទាំង ៥ នេះ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា នាគិតសូត្រទី ១០

## ចប់បញ្ចង្គិកវគ្គវណ្ណនាទី ៣

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# សុមនវគ្គវណ្ណនាទី ៤

## អដ្ឋកថា សុមនសូត្រទី ១

### (ទេវតាមានការវិនាសផ្សេងគ្នាដោយហេតុ ៥ យ៉ាង)

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុមនសូត្រទី ១ ដូចតទៅនេះ ៖*

[៣១] *បទថា **សុមនារាជកុមារី** បានដល់ ម្ចាស់ស្រីដែលមាននាមយ៉ាងនោះ ព្រោះទ្រង់ធ្វើមហាសក្ការៈហើយ ទ្រង់តាំងសេចក្តីប្រាថ្នាទុក ។ សេចក្តីពិស្តារថា កាលព្រះវិបស្សីសម្មាសម្ពុទ្ធ កាលពួកអ្នកក្រុងគិតគ្នាថា ពួកយើងនឹងធ្វើការសម្រេចហើយ នឹងយាងព្រះសាស្តារបស់ពួកយើងទុកសម្រាប់ពួកយើង អាស្រ័យសេនាបតី បានពួកសង្ឃមានព្រះពុទ្ធជាប្រធានហើយទើបផ្តើមធ្វើបុណ្យតាមលំដាប់ ក្នុងថ្ងៃដំបូង ជាវារៈរបស់សេនាបតី ក្នុងថ្ងៃនោះ សេនាបតីត្រៀមមហាទាន ចាត់ចែងអ្នករក្សាការពារទុកដោយជុំវិញ បង្គាប់ថា ថ្ងៃនេះ ពួកអ្នកចូររក្សាការពារ មិនឲ្យនរណាៗ ដទៃនឹងមកថ្វាយ សូម្បីត្រឹមតែភិក្ខុមួយរូប ។ ថ្ងៃនោះភរិយាសេដ្ឋីស្រែកយំ និយាយចំពោះធីតាដែលលេងនឹងពួកស្រីក្រមុំ ៥០០ នាក់ ត្រឡប់មកហើយថា កូនអើយ ប្រសិនបើបិតារបស់កូននៅមានជីវិត ថ្ងៃនេះម៉ែក៏នឹងអាចនិមន្ត*

ព្រះទសពលឆាន់ជាដំបូង ។ កូនក្រមុំនិយាយចំពោះមាតាថា ម៉ែ ម៉ែកុំគិតឡើយ កូននឹងធ្វើដោយវិធីដែលពួកព្រះសង្ឃមានព្រះពុទ្ធជាប្រធាន នឹងឆាន់កិច្ចារបស់យើងជាដំបូង តពីនោះ ធីតាទើបបញ្ចូនបាយាសដែលមិនមានទឹកដាក់ក្នុងថាសមាសមានតម្លៃមួយសែនដរាបពេញ ហើយផ្សំដោយទឹកដោះថ្លា ទឹកឃ្មុំ និងដុំស្ករគ្នោតជាដើម យកថាសដទៃមួយទៀតមកគ្រប យកក្នុងផ្កាម្លិះលោមព័ទ្ធភាជនៈនោះ ធ្វើស្រដៀងនឹងកម្រងផ្កា ក្នុងវេលាដែលព្រះដ៏មានព្រះភាគស្តេចយាងចូលស្រុក នាងក៏នាំយកទៅដោយខ្លួនឯង មានពួកទាសីហែហម ចេញអំពីផ្ទះទៅ ។ កាលចូលដល់ចន្លោះផ្លូវ ពួកអ្នកបម្រើរបស់សេនាបតី និយាយថា នាងកុំមកផ្លូវនេះ ។ ធម្មតាអ្នកមានបុណ្យច្រើន រមែងមានពាក្យសម្តីត្រូវចិត្តគេ ពាក្យរបស់អ្នកបម្រើសេនាបតីទាំងនោះដែលនិយាយហើយនិយាយទៀត ក៏មិនអាចហាមឃាត់បាន ។ នាងពោលថា លោកតូ លោកអ៊ំ លោកមា ហេតុដូចម្តេច លោកមិនឲ្យពួកយើងចូលទៅហ្ន៎ ។ អ្នកបម្រើពោលថា នាង សេនាបតីតាំងពួកយើងឲ្យការពាររក្សា ដោយបង្គាប់ថា ពួកអ្នកចូរកុំឲ្យនរណាៗ នាំរបស់ដទៃ មានរបស់ទំពារ និងរបស់បរិភោគចូលមកទីនេះជាដាច់ខាត ។ នាងពោលថា ក៏ពួកលោកឃើញរបស់ទំពារ និងរបស់បរិភោគក្នុងដៃរបស់ខ្ញុំឬ ។ អ្នក

បម្រើនិយាយថា ឃើញតែកម្រងផ្កាទេ ។ នាងសួរថា សេនាបតីរបស់ពួកលោក មិនឲ្យធ្វើសួម្បីការបូជាដោយផ្កាឈើមែនទេ ។ អ្នកបម្រើនិយាយឲ្យនាង ។ នាងពោលថា បើដូច្នោះ ពួកលោកចូលចៀសចេញទៅ ហើយចូលទៅគាល់ព្រះមានព្រះភាគ ក្រាបទូលថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គទ្រង់អនុញ្ញាតទទួលកម្រងផ្កាឈើផងចុះ ព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ក្រឡេកមើលអ្នកបម្រើរបស់សេនាបតីម្នាក់ ហើយឲ្យទទួលកម្រងផ្កាទុក នាងថ្វាយបង្គំព្រះមានព្រះភាគ ហើយតាំងសេចក្ដីប្រាថ្នាថា កាលនាងខ្ញុំកើតនៅក្នុងភពតូចភពធំ សូមកុំឲ្យមានជីវិតរស់នៅដោយសេចក្ដីក័យតក់ស្លុតឡើយ ក្នុងភពដែលនាងខ្ញុំកើត សូមឲ្យជាទីស្រឡាញ់ដូចកម្រងផ្កានេះផងចុះ និងសូមឲ្យមានឈ្មោះថា សុមនាចុះ ។ ព្រះមានព្រះភាគត្រាស់ថា នាងចូរមានសេចក្ដីសុខចុះ ដូច្នេះ នាងថ្វាយបង្គំហើយ ធ្វើប្រទក្សិណក្រាបទូលលាត្រឡប់ទៅវិញ ។ ព្រះមានព្រះភាគ ស្ដេចក៏ទៅកាន់ផ្ទះរបស់សេនាបតីប្រថាប់លើអាសនៈដែលគេក្រាលទុក សេនាបតីកាន់យាគូបង្អែមចូលទៅថ្វាយ ។ ព្រះសាស្ដាទ្រង់យកព្រះហស្ដបិទបាត្រ ។ សេនាបតី ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុអង្គុយហើយព្រះអង្គ ។ ព្រះសាស្ដាត្រាស់ថា តថាគតបានបិណ្ឌបាតហើយក្នុងចន្លោះផ្លូវ ។ សេនាបតីនាំមាលា

ចេញ បានឃើញបិណ្ឌបាត ។ ចូឡុបដ្ឋាកដែលនៅបម្រើជិត ពោលថា លោកម្ចាស់ ស្រីនោះនិយាយកុហកខ្ញុំថា ផ្កាឈើ ។ បាយបាយាសត្រឹមតែល្មមដល់ភិក្ខុទាំងអស់ រាប់តាំងពីព្រះមានព្រះភាគជាដើមទៅ សេនាបតីបានថ្វាយទេយ្យធម៌របស់ខ្លួន ។ ព្រះសាស្តាសោយស្រេចហើយ ត្រាស់មង្គលកថា ស្តេចក៏យាងត្រឡប់ ។ សេនាបតីសួរថា ស្រីដែលថ្វាយបិណ្ឌ-បាត ជានរណា ។ ធីតាសេដ្ឋីលោកម្ចាស់ ។ សេនាបតីគិតថា ស្រីនេះមានបញ្ញា កាលមកនៅក្នុងផ្ទះរបស់យើង ឈ្មោះថា សួគ៌សម្បត្តិរបស់បុរសមិនមែនរកបានលំបាកឡើយ ដូច្នេះ ទើបនាំនាងនោះមក តាំងទុកក្នុងតំណែងជាប្រធាន ។ នាងក៏ផ្តើមប្រើប្រាស់ទ្រព្យក្នុងផ្ទះរបស់មាតា និងក្នុងផ្ទះរបស់សេនាបតី ថ្វាយទានចំពោះព្រះតថាគត បំពេញបុណ្យរហូតដល់អស់អាយុលុះចុតិចាកពីនោះ ក៏ទៅកើតក្នុងទេវលោកចំណែកកាមាវចរៈ ។ ក្នុងខណៈដែលនាងកើតនោះឯង ភ្លៀងផ្កាម្ចិះធ្លាក់ចុះទូទៅទេវលោក ប្រមាណត្រឹមក្បាលជង្គង់ ។ ពួកទេវតាគិតថា ទេពធីតានេះ កាន់យកឈ្មោះរបស់ខ្លួនដោយខ្លួនឯងមក ទើបតាំងឈ្មោះទេពធីតានោះថា **សុមនា** ។ ទេពធីតានោះអន្ទោលទៅក្នុងទេវលោក និងមនុស្សលោករហូតដល់អស់ ៨៩ កប្ប ក្នុងទីដែលនាងកើតហើយ ភ្លៀងផ្កាម្ចិះក៏ធ្លាក់ចុះមិនដាច់ ទើបមានឈ្មោះថា សុមនា

ដូចដើម ក៏ក្នុងកាលនាងបដិសន្ធិក្នុងព្រះគភ៌របស់ព្រះអគ្គមហេសីរបស់ព្រះបាទកោសល ក្នុងថ្ងៃនោះឯង កុមារិកា ៥០០ ក៏បដិសន្ធិក្នុងត្រកូលនោះៗ ហើយប្រសូតចាកគភ៌មាតាក្នុងថ្ងៃនោះព្រមគ្នា ។ ក្នុងខណៈនោះឯង ភ្លៀងផ្កាម្លិះក៏ធ្លាក់ចុះប្រមាណត្រឹមក្បាលជង្គង់ ។

ព្រះរាជាទតឃើញធីតានោះ ទ្រង់រីករាយក្នុងព្រះទ័យថា រាជធីតានេះ នឹងជាអ្នកសាងបុណ្យកុសលមកពីមុន ទ្រង់ត្រិះរិះថា ធីតារបស់យើងកាន់យកឈ្មោះរបស់ខ្លួនដោយខ្លួនឯងមក ទើបព្រះរាជទានព្រះនាមរបស់ព្រះធីតានោះថា សុមនា ហើយទ្រង់ឲ្យស្វែងរកទូទាំងព្រះនគរ ដោយទ្រង់ត្រិះរិះថា ធីតារបស់យើងគង់នឹងមិនកើតមកតែម្នាក់ឯងប៉ុណ្ណោះទេ ទ្រង់ជ្រាបថា មានទារិកា ៥០០ កើត ទើបទ្រង់ប្រោសឲ្យចិញ្ចឹមទាំងអស់ដោយព្រះអង្គឯង ត្រាស់បង្គាប់ថា ជារៀងរាល់ខែ ពួកនាងចូរនាំមកសម្តែងដល់ធីតារបស់យើង ដូច្នេះ ។ គប្បីជ្រាបថា ព្រះធីតាទ្រង់ធ្វើមហាសក្ការៈ ហើយតាំងសេចក្តីប្រាថ្នាទុក ទើបបានព្រះនាមយ៉ាងនេះ ។ វេលាព្រះធីតាមានព្រះជន្មាយុ ៧ វស្សា កាលអនាថបិណ្ឌិកសេដ្ឋី ឲ្យសាងវិហារស្រេចហើយ ទើបបញ្ជូនទូតទៅក្រាបទូលព្រះតថាគត ព្រះសាស្តាមានពួកភិក្ខុជាបរិវារស្តេចទៅកាន់ក្រុងសាវត្ថី ។

អនាថបិណ្ឌិកសេដ្ឋី បានទៅក្រាបទូលព្រះរាជាថា បពិត្រមហារាជ ការស្តេចមកក្នុងទីនេះរបស់ព្រះសាស្តា ជាមង្គលទាំងដល់ខ្ញុំព្រះអង្គ ទាំងដល់ព្រះអង្គ សូមព្រះអង្គទ្រង់មេត្តាប្រោសឲ្យសុមនារាជកុមារី ព្រមទាំងទារិកា ៥០០ កាន់ថ្នាំងទឹក និងគ្រឿងក្រអូប និងផ្កាឈើជាដើម ទទួលព្រះទសពលផងចុះ ព្រះអង្គ ។ ព្រះរាជាត្រាស់ថា ល្អហើយសេដ្ឋី ហើយទ្រង់ធ្វើតាមនោះ ។ ធីតាក៏ស្តេចទៅ តាមដែលព្រះរាជាទ្រង់ណែនាំ ថ្វាយបង្គំព្រះសាស្តាហើយ ទ្រង់បូជាដោយគ្រឿងក្រអូប និងផ្កាឈើជាដើម ហើយប្រថាប់នៅក្នុងទីដ៏សមគួរមួយ ។ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់ធីតា ។ ព្រះធីតាព្រមដោយកុមារី ៥០០ ក៏តាំងនៅក្នុងសោតាបត្តិផល ។ ទារិកា ៥០០ ឧបាសិកា ៥០០ និងឧបាសក ៥០០ សូម្បីពួកដទៃ ក៏តាំងនៅក្នុងសោតាបត្តិផលក្នុងខណៈនោះដូចគ្នា ។ ក្នុងថ្ងៃនោះ មានព្រះសោតាបន្ន ២.០០០ នាក់ ក្នុងរវាងផ្លូវនោះឯង ។

បទថា **យេន ភគវា តេនុបសង្កមិ** សួរថា ព្រោះហេតុអ្វី ទើបចូលទៅគាល់ ។ ឆ្លើយថា ព្រោះទ្រង់ត្រូវការសួរបញ្ហា ។ បានឮថា សម័យព្រះកស្សបសម្មាសម្ពុទ្ធ មានភិក្ខុពីររូបជាសម្លាញ់គ្នា ។ ក្នុងភិក្ខុពីររូបនោះ មួយរូបបំពេញសារាណីយធម៌ មួយរូបបំពេញកត្តគ្គវត្ត ។ ភិក្ខុមួយរូបដែល

បំពេញសារាណីយធម៌ ពោលនឹងភិក្ខុមួយរូបដែលបំពេញកត្តគ្គវត្តថា អ្នកមានអាយុ ឈ្មោះថា ទានដែលមិនឲ្យផលរមែងមិនមាន ការឲ្យរបស់ខ្លួនដល់អ្នកដទៃ ហើយបរិភោគទើបគួរ ដូច្នេះ ។ តែភិក្ខុដែលបំពេញកត្តគ្គ-វត្ត ពោលថា អ្នកមានអាយុ លោកមិនដឹងទេឬថា ការឲ្យទេយ្យធម៌ធ្លាក់ទៅមិនគួរ អ្នកដែលកាន់យកត្រឹមតែអាហារ ហើយញ៉ាំងជីវិតរបស់ខ្លួនឲ្យប្រព្រឹត្តទៅបានប៉ុណ្ណោះ បំពេញវត្តក្នុងរោងកត្តទើបគួរ ។ ក្នុងភិក្ខុពីររូបនោះ សូម្បីមួយរូប ក៏មិនអាចនឹងឲ្យមួយរូបទៀតនៅក្នុងឱវាទរបស់ខ្លួនបាន ។ សូម្បីទាំងពីររូបបំពេញវត្តបដិបត្តិរបស់ខ្លួនឲ្យបរិបូណ៌ លុះចុតិចាកភពនោះក៏កើតក្នុងទេវលោកជាកាមាវចរៈ បណ្តាភិក្ខុពីររូបនោះ អង្គដែលបំពេញសារាណីយធម៌ កន្លងភិក្ខុមួយរូបទៀតដោយធម៌ ៥ យ៉ាង ។ ភិក្ខុទាំងនោះវិលវល់នៅក្នុងទេវតា និងមនុស្សអស់ទៅមួយពុទ្ធន្តរ ទើបកើតក្នុងក្រុងសាវត្ថីក្នុងវេលានេះ ។ ភិក្ខុដែលបំពេញសារាណីយធម៌ បដិសន្ធិក្នុងព្រះគភ៌របស់អគ្គមហេសីរបស់ព្រះបាទកោសល ភិក្ខុមួយរូបទៀត បដិសន្ធិក្នុងផ្ទៃរបស់ស្រ្តីបម្រើរបស់ព្រះអគ្គមហេសីនោះដូចគ្នា ។ ភិក្ខុសូម្បីទាំងពីររូបនោះក៏កើតក្នុងថ្ងៃព្រមគ្នាទុំះឯង ។ ក្នុងថ្ងៃដាក់ឈ្មោះ មាតាឲ្យអ្នកទាំងពីរងូតទឹក ហើយឲ្យដេកក្នុងបន្ទប់ប្រកបដោយសិរី ចាត់ចែងគ្រៀមរបស់ខាងក្នុង

ខាងក្រៅទុកឲ្យដល់អ្នកទាំងពីរ ។ បណ្ដាអ្នកទាំងពីរនោះ អ្នកដែលបំពេញសារាណីយធម៌ ពេលបើកភ្នែក ក៏ឃើញស្វេតឆត្រធំ លើទីដេកប្រកបដោយសិរីដែលគេចាត់ចែងទុកយ៉ាងល្អ និងនិវេសន៍ប្រដាប់ដោយគ្រឿងអលង្ការ ទើបបានដឹងថា យើងកើតក្នុងរាជត្រកូលមួយកន្លែង ដូច្នេះ ។ គេនឹកថា យើងធ្វើកម្មអ្វីហ្ន៎ ទើបបានកើតក្នុងទីនេះដូច្នេះ ក៏ដឹងថា ដោយផលនៃការបំពេញសារាណីយធម៌ ទើបគិតថា សម្លាញ់របស់យើងកើតទីណាហ្ន៎ ក៏បានឃើញគេដេកខាងក្រោម គិតថា អ្នកនេះបំពេញវត្តក្នុងភេទបាយ មិនជឿពាក្យរបស់យើង គ្រានេះយើងនឹងសង្កត់សង្កិនគេក្នុងឋានៈដ៏គួរ ទើបបាននិយាយថា សម្លាញ់ អ្នកមិនជឿពាក្យរបស់យើង ។ គេឆ្លើយថា បើដូច្នោះ នឹងជាអ្វី ។ បានឆ្លើយថា អ្នកក្រឡេកមើលសម្បត្តិរបស់យើងចុះ យើងដេកលើទីដែលមានសិរីនៅខាងក្រោមស្វេតឆត្រ អ្នកឯងដេកលើគ្រែក្រោម ខាងលើក្រាលដោយរបស់រឹង សម្លាញ់ពោលថា ក៏លោកអាស្រ័យវត្ថុនោះហើយ នៅធ្វើមានះឲ្យកើតឡើង ។ វត្ថុទាំងនោះគេយកបន្ទះឫស្សីនាំយកសំពត់រុំទុក ត្រឹមតែជាបឋវីធាតុប៉ុណ្ណោះ មិនមែនឬ ។

ព្រះរាជធីតាសុមនា បានស្ដាប់ពាក្យរបស់អ្នកទាំងពីរនោះហើយ គិតថា នៅទីជិតៗ ប្អូនប្រុសទាំងពីររបស់យើង មិនមាននរណា ដូច្នេះ ក៏ដើរ

ចូលទៅជិតអ្នកទាំងនោះ ឈរផ្អែកទ្វារ បានឮពាក្យថា ធាតុ ហើយក៏គិតថា ពាក្យថា ធាតុនេះ ចំណែកខាងក្រៅក៏មិនមាន ប្អូនប្រុសទាំងពីររបស់យើងនឹងជាសមណទេវបុត្រ ក៏គិតថា បើយើងនឹងប្រាប់ដល់មាតាបិតាថា អ្នកទាំងនេះ និយាយគ្នាយ៉ាងនេះ លោកក៏នឹងឲ្យនាំចេញទៅ ដោយយល់ថា អ្នកទាំងនោះជាអមនុស្ស ដូច្នេះ ។ យើងមិនប្រាប់ហេតុនេះ ដល់អ្នកដទៃឡើយ នឹងទូលសួរចំពោះព្រះទសពល ទ្រង់ជាមហាគោតម ពុទ្ធបិតារបស់យើង ទ្រង់ជាហិរញ្ញិកបុរសអ្នកកាត់សេចក្តីសង្ស័យបាន ដូច្នេះ ។ សោយព្រះក្រយាហារព្រឹកហើយ ក៏ចូលទៅគាល់ព្រះរាជាទូលសូមអនុញ្ញាតទៅគាល់ព្រះទសពល ។ ព្រះរាជាត្រាស់បង្គាប់ឲ្យចាត់រថ ៥០០ ។ ពិតណាស់ ក្នុងភាគផែនដីជម្ពូទ្វីប កុមារីប៉ីនាក់ប៉ុណ្ណោះ មានរថ ៥០០ ក្នុងសម្នាក់របស់បិតាទាំងឡាយ គឺ **ព្រះនាងចន្ទី** ជារាជធីតារបស់ព្រះបាទពិម្ពិសារ , **នាងវិសាខា** ធីតារបស់ធនញ្ជ័យសេដ្ឋី និង **ព្រះនាងសុមនា** នេះឯង ។ នាងកាន់យកគ្រឿងក្រអូប និងផ្កាឈើ ហើយឈរក្នុងរថ ដែលមានរថ ៥០០ ជាបរិវារ ទើបបានចូលទៅគាល់ព្រះមានព្រះភាគ ដោយគិតថា យើងនឹងទូលសួរបញ្ហានេះ ដូច្នេះ ។

បទថា **ឥធស្សុ** កាត់បទថា **ឥធ** **ភយ្យុំ** ប្រែថា គប្បីមានក្នុងធម្ម-

វិន័យនេះ ។ បទថា **ឯកោ ទាយកោ (មួយអង្គជាទាយក)** សេចក្តីថា ម្នាក់ជាអ្នកបែងចែកលាភ ដែលខ្លួនបានហើយឲ្យដល់អ្នកដទៃបរិភោគ ជាការបំពេញសារាណីយធម៌ ។ បទថា **ឯកោ អទាយកោ (មួយអង្គមិនមែនជាទាយក)** សេចក្តីថា ម្នាក់ជាអ្នកមិនបែងចែកវត្ថុដែលខ្លួនបានហើយ ឲ្យដល់អ្នកដទៃបរិភោគ ជាអ្នកបំពេញវត្តក្នុងភោជនបាយ ។ បទថា **ទេវភូតានំ បន នេសំ (សាវកទាំងពីរដែលកើតជាទេវតានោះ)** បានដល់ អ្នកទាំងពីរនោះ ក៏ជាទេវតា ។ បទថា **អាធិបតេយ្យេន (អធិបតេយ្យទិព្វ)** បានដល់ដោយហេតុជាប្រធាន ។ បទថា **ឥមេហិ បញ្ចហិ ឋានេហិ (ដែលមិនមែនជាទាយកដោយហេតុទាំង ៥ នេះ)** សេចក្តីថា អ្នកមិនជាទាយកដោយហេតុទាំង ៥ នេះ ដូចជាសក្កទេវរាជ ជាប្រធានរបស់ពួកទេវតាដ៏សេសដូច្នោះ ។

ក្នុងបទជាដើមថា **មានុសកេន (របស់មនុស្ស)** គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ជាប្រធានដោយហេតុ ៥ យ៉ាង គឺ ដោយអាយុ ដូចព្រះមហាកស្សបត្ថេរៈ ព្រះមហាពាកុលត្ថេរៈ និងព្រះអានន្ទត្ថេរៈ ។ ដោយពណ៌នា ដូចព្រះមហាគតិម្ពអភយត្ថេរៈ និងអាមាត្រដែលជាកណ្ឌាគារិក អ្នករក្សាឃ្លាំង , **ដោយសុខ** ដូចរដ្ឋបាលកុលបុត្រ សោភណសេដ្ឋីបុត្រ និង យស-

កុលបុត្រ ។ ដោយយស និងដោយកាពជាធំ ដូចព្រះបាទធម្មាសោកកាជ ។ បទថា យាចិតោវ ពហុលំ (កាលហាមាត់សុំរមែងបាន... ច្រើន) សេចក្ដីថា ជាប្រធាន ជាបុគ្គលចម្រើនជាទីបំផុត ដោយហេតុនេះថា ជាបុគ្គលដែលគេអង្វរ ទើបបរិភោគចីវរជាដើម ចំណែកច្រើន ដូចព្រះពាកុលត្ថេរៈ ព្រះសីវលីលត្ថេរៈ និងព្រះអានន្ទត្ថេរៈជាដើម ។ បទថា យទិទំ វិមុត្តិយា វិមុត្តំ (ត្រង់ចិត្តដែលរួចស្រឡះ ដោយវិមុត្តិនេះឯង) សេចក្ដីថា ហេតុផ្សេងគ្នាយ៉ាងណា ដែលនឹងគប្បីពោលប្រារព្ធវិមុត្តិរបស់បុគ្គលម្នាក់ ជាមួយនឹងវិមុត្តិរបស់បុគ្គលម្នាក់ទៀត តថាគតមិនពោលហេតុដែលផ្សេងគ្នានោះទេ ។ ពិតណាស់ ក្មេងអាយុ ៧ ខួបក្ដី ព្រះថេរៈអាយុ ១០០ ឆ្នាំក្ដី មិនថា នឹងជាភិក្ខុ ឬភិក្ខុនី ឧបាសក ឬឧបាសិកា ទេវតា ឬមារ ឬព្រហ្ម ក៏ត្រាស់ដឹងវិមុត្តិ ក្នុងលោកុត្តរមគ្គដែលត្រាស់ដឹងហើយ ឈ្មោះថា សេចក្ដីផ្សេងគ្នា មិនមានឡើយ ។ បទថា អលមេវ ប្រែថា គួរ ។ បទថា យត្រ ហិ នាម ស្មើនឹង យានិ នាម ប្រែថា ឈ្មោះពួកណា ។

បទថា គច្ឆំ អាកាសធាតុយា (កាលចរទៅតាមអាកាស) គឺ គោចរទៅផ្លូវអាកាស ។ បទថា សទ្ធោ (សទ្ធា) បានដល់ អ្នកជឿគុណរបស់ព្រះរតនត្រ័យ ។ បទថា ថនយំ (ដែលចរទៅតាមអាកាស) ប្រែថា អណ្ដែត

ទៅ ។ បទថា *វិជ្ជមាលី* (ផ្ទេកបន្ទោរដ៏ធ្លៀលធ្វាត់) បានដល់ ប្រកបដោយខ្សែផ្ទេកបន្ទោរនៅមុខពពកដូចជាមាលា ។ បទថា *សតក្កកុ* (ដោយកំពូលដ៏ច្រើន) គឺ មានកំពូលទាំងរយ អធិប្បាយថា ប្រកបដោយពពកច្រើនរយកំពូល តាំងឡើងជាជរាបទៅ ។ បទថា *ទស្សនសម្បន្នោ* (អ្នកបរិបូណ៌ដោយទស្សនៈ) គឺ ព្រះសោតាបន្ន ។ បទថា *ភោគបរិព្យូឡ្ហោ* (បរិបូណ៌ដោយភោគៈ) បានដល់ ជាអ្នក ប្រកបដោយភោគៈដែលត្រូវនាំមក ដោយអំណាចទាន ប្រៀបដូចអន្លង់ទឹក ។ អធិប្បាយថា ឲ្យដល់ទេវលោក ។ បទថា *បេច្ច* (លោកខាងមុខ) គឺ ក្នុងបរលោក ។ បទថា *សគ្គេ បមោទតិ* (រមែងរីករាយក្នុងឋានសួគ៌) សេចក្តីថា រមែងត្រេកអររីករាយ បាមោជ្ជៈក្នុងឋានសួគ៌ដែលគេកើតហើយនោះឯង ។

ចប់អដ្ឋកថា សុមនសូត្រទី ១

# អដ្ឋកថា ចុន្ទិសូត្រទី ២

## (វត្ថុដែលឲ្យផលដ៏លើស)

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចុន្ទិសូត្រទី ២ ដូចតទៅនេះ ៖*

[៣២] *បទថា* ***បញ្ចហិ រថសតេហិ (មានរថ ៥០០)*** *សេចក្តីថា នាងចុន្ទីរាជកុមារី សោយព្រះក្រយាហារព្រឹកហើយ ព្រះនាងចូលគាល់ព្រះជនក ឲ្យចាត់ចែងរថ ៥០០ មានរថទាំងនោះហែហមហើយ ។ បទថា* ***ឧបសង្កមិ (ចូលទៅគាល់)*** *សេចក្តីថា នាងចុន្ទីរាជកុមារី ត្រិះរិះថា យើងនឹងទូលសួរការសន្ទនា ដែលយើងឲ្យប្រព្រឹត្តទៅនឹងព្រះជេដ្ឋភាតា* ***(បងប្រុសនាងចុន្ទីរាជកុមារី)*** *ដូច្នេះ កាន់គ្រឿងក្រអូប ផ្កាឈើ និងលំអិតជាដើម ហើយទើបចូលទៅគាល់ ។ បទថា* ***យទេវ សោ ហោតិ (តាមតែបុគ្គលណាក៏ដោយ)*** *បានដល់ បុគ្គលណាមួយ ។ម្យ៉ាងទៀត គឺ បុគ្គលនោះ ។ បទថា* ***សីលានិ អរិយកន្តានិ (សីលដែលព្រះអរិយៈសរសើរ)*** *បានដល់ សីលដែលសម្បយុត្តជាមួយមគ្គ និងផល ។ ក៏សីលទាំងនោះ ជាសីលដែលគួរប្រាថ្នារបស់ព្រះអរិយៈទាំងឡាយ ព្រោះដូច្នោះ ទើបមិនលះបង់សូម្បីក្នុងភពដទៃ ។*

*បទដ៏សេស គប្បីជ្រាបសូម្បីដោយន័យដែលលោកពោលទុកហើយ*

ក្នុងអគ្គប្បសាទសូត្រ ក្នុងចតុក្កនិបាតនោះឯង ។

ចប់អដ្ឋកថា ចុន្ទិសូត្រទី ២

# អដ្ឋកថា ឧគ្គហសូត្រទី ៣

## (មុខនាទីរបស់ករិយាល្អ)

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧគ្គហសូត្រទី ៣ ដូចតទៅនេះ ៖*

*[៣៣] បទថា **ភទ្ទិយេ (ទៀបក្រុងភទ្ទិយ:)** បានដល់ ជិតភទ្ទិយ-នគរ ។ បទថា **ជាតិយាវនេ (ជាតិយាវន)** បានដល់ ក្នុងព្រៃដែលកើតឯង ព្រោះគេមិនបានដាំ ជាព្រៃដូចគ្នានឹងព្រៃហិមពាន្ត ។ អធិប្បាយថា ព្រះមាន-ព្រះភាគទ្រង់ចូលទៅអាស្រ័យនគរនោះ ប្រថាប់នៅក្នុងព្រៃនោះ ។ បទថា **អត្តចតុត្ថោ (មានភិក្ខុជាគម្រប់ ៤ នឹងព្រះអង្គ)** មានព្រះអង្គជាគម្រប់ ៤ ។*

*សួរថា ក៏ព្រោះហេតុអ្វី ឧគ្គហសេដ្ឋីក្មួយប្រុសមេណ្ឌកសេដ្ឋីនោះ ទើបនិមន្តព្រះមានព្រះភាគ មានព្រះអង្គជាគម្រប់ ៤ មានភិក្ខុទៅជាមួយ ៣ រូប ។ ឆ្លើយថា បានឮថា ក្នុងផ្ទះរបស់លោកសេដ្ឋីនោះ មានមង្គលធំ ព្រោះមានការចាត់ចែងការរៀបការធំ មនុស្សទាំងឡាយបានមកប្រជុំគ្នាក្នុងផ្ទះនោះ លោកគិតថា មនុស្សទាំងឡាយ កាលអង្គៀសដល់ពួកភិក្ខុ នឹងយកចិត្តមនុស្ស ទាំងនោះបានលំបាក ទើបនិមន្តព្រះមានព្រះភាគជាគម្រប់ ៤ ប៉ុណ្ណោះ ។ ម្យ៉ាងទៀត លោកសេដ្ឋីមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលព្រះសាស្តាទ្រង់*

ឲ្យឱវាទនៅកណ្តាលភិក្ខុពួកធំ កំលោះក្រមុំទាំងឡាយរវល់តែសម្លឹងមើលគ្នា ក៏មិនអាចនឹងទទួលយកឱវាទបានឡើយ ។ ព្រោះហេតុដូចពោលមកនេះ ទើបនិមន្តព្រះមានព្រះភាគ មានព្រះអង្គជាគម្រប់ ៤ ប៉ុណ្ណោះ ។

បទថា **ឱវទតុ តេសំ ភន្តេ** (សូមព្រះមានព្រះភាគទូន្មានកុមារទាំងនោះ) សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគមេត្តាឲ្យឱវាទ គឺ ប្រៀនប្រដៅកំលោះក្រមុំទាំងនោះ ។ ការពិត ពាក្យថា **តាសំ** ជាឆដ្ឋីវិភត្តិប្រើក្នុងអត្ថនៃទុតិយាវិភត្តិ ។ បទថា **យំ តាសំ** (ដោយឱវាទានុសាសនីណា) បានដល់ ឱវាទានុសាសន៍សម្រាប់កំលោះក្រមុំទាំងនោះ ។ ឯលោកសេដ្ឋីនោះ លុះក្រាបទូលហើយយ៉ាងនេះ គិតថា កំលោះក្រមុំទាំងនេះ កាលបានទទួលឱវាទក្នុងសំណាក់របស់យើង នឹងគប្បីឲ្យនាំទៅកាន់ត្រកូលស្វាមី ដូច្នេះ ទើបថ្វាយបង្គំព្រះមានព្រះភាគហើយ ក៏ចៀសចេញទៅ ។

បទថា **ភត្តុ** (ប្តី) គឺ ដល់ស្វាមី ។ បទថា **អនុកម្បំ ឧបាទាយ** (អាស្រ័យសេចក្តីអនុគ្រោះហើយ) បានដល់ អាស្រ័យសេចក្តីអាណិត ។ បទថា **បុព្វុដ្ឋាយិនិយោ** (ជាស្រីភ្ញាក់ឡើងមុនគេ) បានដល់ ជាប្រក្រតីភ្ញាក់មុនគេទាំងអស់ ។ បទថា **បច្ឆានិបាតិនិយោ** (ដេកក្រោយគេ) បានដល់ ជា

ប្រក្រតីដេកក្រោយគេ ។ ក៏ស្ត្រីបរិភោគហើយឡើងទីដេក ដេកមុន មិនគួរ ។ តែឲ្យអ្នកក្នុងផ្ទះទាំងអស់បរិភោគហើយ ចាត់ចែងរបស់របរដែលជាឧបករណ៍ ដឹងថា គោជាដើមដែលមកហើយ និងមិនទាន់មក រៀបចំការងារដែលនឹងគប្បីធ្វើក្នុងថ្ងៃស្អែក កាន់កូនសោរទុកក្នុងដៃ បើអាហារមានក៏បរិភោគ បើមិនមានក៏ឲ្យអ្នកដទៃដាំស្ល ហើយឲ្យអ្នកទាំងនោះបរិភោគឲ្យឆ្អែត ហើយដេកតាមក្រោយ ទើបគួរ ។ សូម្បីដេកហើយ នឹងដេកដរាបថ្ងៃរះឡើងក៏មិនគួរ តែគួរក្រោកមុនគេ ហើយឲ្យហៅទាសៈ និងកម្មករមកប្រាប់អំពីការងារថា អ្នកចូរធ្វើការងារយ៉ាងនេះៗ ឲ្យប្រចបាច់ទឹកដោះមេគោ ធ្វើកិច្ចដែលគួរធ្វើទាំងអស់ ក្នុងផ្ទះទុកជាភារៈរបស់ខ្លួនទើបគួរ ។ ព្រះមានព្រះភាគទ្រង់សំដៅដល់សេចក្តីនោះ ទើបត្រាស់ថា **បុព្វុដ្ឋាយិនិយោ បច្ឆានិបាតិនិយោ** ជាស្ត្រីភ្ញាក់ឡើងមុន ដេកជាខាងក្រោយ ដូច្នេះ ។

បទថា **កឹការប្បដិស្សាវិនិយោ (ប្រុងខ្លួននឹងទទួលកិច្ចការអ្វី)** សេចក្តីថា មានប្រក្រតីមើលមុខគ្នាហើយ ពិនិត្យមើលថា យើងនឹងធ្វើអ្វី យើងនឹងធ្វើអ្វី ដូច្នេះ ។ បទថា **មនាបចារិនិយោ (និយាយពាក្យផ្អែមល្ហែម)** បានដល់ មានប្រក្រតីធ្វើកិរិយាដែលគួរពេញចិត្ត ។ បទថា **បិយវាទិនិយោ (និយាយពាក្យជាទីស្រឡាញ់)** បានដល់ និយាយតែពាក្យដែលគួរស្រឡាញ់ ។

បទថា **បូជេស្សាម** (បូជា) បានដល់ បូជាដោយបច្ច័យទាំងឡាយ ៤ ។ បទថា **អព្ភាគតេ** (ដែលមកដល់ហើយ) បានដល់ លោកមកដល់ហើយក្នុងសម្នាក់របស់ខ្លួន ។ បទថា **អាសនោទកេន បដិបូជេស្សាម** (គួរទទួលដោយអាសនៈ និងទឹកលាងជើង) បានដល់ គួរទទួលដោយអាសនៈ និងទឹកលាងជើង ។ តែក្នុងសេចក្ដីនេះ គួរធ្វើសក្ការៈរាល់ថ្ងៃដល់មាតាបិតា ។ ចំណែកសមណព្រាហ្មណ៍ដែលមកដល់ហើយ គួរប្រគេនអាសនៈ ទឹកលាងជើង ហើយធ្វើសក្ការៈទើបគួរ ។

បទថា **ឧណ្ណា** (ការធ្វើរោមសត្វចៀម) គឺ រោមកែះ ។ បទថា **តត្ថ ទក្ខា ភវិស្សាម** (ពួកយើងនឹងជាស្រីឈ្លាសវៃក្នុងការងារទាំងនោះ) សេចក្ដីថា យើងនឹងជាអ្នកច្លាតក្នុងការងារបោកគក់ នឹងការជ្រលក់ពណ៌ និងរៀបចំជាបាច់ជាដើមសម្រាប់រោមកែះទាំងឡាយ និងក្នុងការត្បាញរវៃលាត ញី និងខាអំបោះជាដើមសម្រាប់កប្បាស ។ បទថា **តត្រុបាយាយ** (ដែលជាឧបាយក្នុងការងារទាំងនោះ) បានដល់ ជាអ្នកប្រកបដោយបញ្ញាដែលជាឧបាយក្នុងការធ្វើរោមចៀម និងកប្បាសនោះ ដែលប្រព្រឹត្តទៅហើយយ៉ាងនេះថា យើងគួរធ្វើការងារនេះ ក្នុងវេលានេះ ដូច្នេះ ។ បទថា **អលំ កាតុំ អលំ សំវិធាតុំ** (គួរធ្វើ គួរចាត់ចែង) បានដល់ ធ្វើដោយខ្លួនឯងក្ដី

ប្រើឲ្យអ្នកដទៃធ្វើក្តី ក៏គួរទាំងអស់ អធិប្បាយថា ពួកយើងនឹងជាអ្នកអាច ។ បទថា **កតញ្ច កតតោ** ជានិសប្ញាម **អកតញ្ច អកតតោ** (**យើងទាំងឡាយនឹងដឹងការងារដែល... ធ្វើហើយ ពោលថា ធ្វើហើយ ដែលនៅមិនទាន់បានធ្វើថា នៅមិនទាន់បានធ្វើ**) សេចក្តីថា យើងនឹងដឹងយ៉ាងនេះថា យើងគួរឲ្យវត្ថុនេះ និងធ្វើកិច្ចនេះដល់អ្នកមកធ្វើការងារឈ្មោះនេះអស់មួយថ្ងៃ អ្នកមកធ្វើការងារឈ្មោះនេះកន្លះថ្ងៃ ដល់អ្នកធ្វើការងារហើយ ដល់អ្នកអន្តរាយនៅក្នុងផ្ទះ ដូច្នេះ ។ ដោយបទថា **គិលានកានញ្ច ពលាពលំ** (**ដឹងថាឈឺធ្ងន់ផង ឈឺស្រាលផង**) លោកសម្តែងថា ប្រសិនបើគេឲ្យថ្នាំ និងអាហារជាដើម ដល់មនុស្សទាំងនោះក្នុងវេលាដែលមានជំងឺ មិនធ្វើឲ្យទាស់ដល់រោគ ក្នុងវេលាឈឺ ក៏មិនដឹងថាយើងមានហើយ ដូច្នោះ គេជាអ្នកនឿយណាយ មិនធ្វើកិច្ចការទាំងឡាយក្នុងខាងក្រោយ ឬធ្វើកិច្ចការដែលគួរធ្វើ ព្រោះដូច្នោះ អ្នកទាំងឡាយគប្បីហៅយ៉ាងនេះថា យើងនឹងដឹងការមានកម្លាំង និងមិនមានកម្លាំងរបស់មនុស្សទាំងនោះ និងដឹងវត្ថុដែលគប្បីឲ្យ និងកិច្ចដែលគួរធ្វើ ។

បទថា **ខាទនីយំ ភោជនីយំ ចស្ស** (**ហើយចែករំលែកខាទនិយៈភោជនិយាហារដល់ជនទាំងនោះ**) បានដល់ នឹងចែកចាយរបស់ទំពារ និង

របស់បរិភោគដល់ជនអ្នកនៅខាងក្នុង ។ បទថា **បច្ចយំសេន** (តាមហេតុដែលគួរ) គឺ តាមចំណែកដែលគេគួរនឹងបាន អធិប្បាយថា តាមសមគួរដល់ចំណែកដែលខ្លួនគប្បីបាន ។ បទថា **សំវិភជិស្សាម** (ចែករំលែក) គឺ នឹងឲ្យ ។ បទថា **សម្បាទេស្សាម** (ឲ្យសម្រេចដោយការរក្សា និងការគ្រប់គ្រង) គឺ នឹងឲ្យដល់ព្រម ។ បទថា **អធុត្តី** (មិនជាស្រីអ្នកលេង) បានដល់ មិនមែនជាស្រីអ្នកលេង គឺ ជាអ្នកលេងប្រុស និងស្រីអ្នកសេពសុរា ។ បទថា **អត្ថេនី** (មិនជាស្រីអ្នកលួច) គឺ មិនជាស្រីចោរ ។ បទថា **អសោ-ណ្ឌី** (មិនជាស្រីអ្នកផឹកសុរា) គឺ មិនជាស្រីអ្នកស្រវឹង មានអ្នកលេងសុរាជាដើម ។

ព្រះមានព្រះភាគ បញ្ចប់ព្រះសូត្រនេះហើយ ឥឡូវនេះ កាលទ្រង់សរុបដោយគាថាទាំងឡាយ ទើបត្រាស់បទជាដើមថា **យោ នំ ភរតិ សព្វទា** (អ្នករក្សាខ្លួនគ្រប់កាល) ។ បណ្ដាបទទាំងនោះ បទថា **ភរតិ** (រក្សា) បានដល់ ការចិញ្ចឹម ការទំនុកបម្រុង ។ បទថា **សព្វកាមហរំ** (អ្នកបំពេញសេចក្ដីប្រាថ្នាទាំងពួង) បានដល់ ឲ្យវត្ថុដែលគួរប្រាថ្នាទាំងពួង ។ បទថា **សោត្ថី** (ស្រីល្អ) បានដល់ ជាស្រីដែលល្អ ។ បទថា **ឯវំ វត្តតី** (រមែង

ប្រព្រឹត្តយ៉ាងនេះ) បានដល់ ប្រព្រឹត្តវត្តប្រមាណប៉ុណ្ណោះឲ្យបរិបូរណ៍ ។ បទថា មនាបា នាម តេ ទេវា (រមែងទៅកើតក្នុងពួកទេវតាទាំងនោះ ដែលមានកាយជាទីពេញចិត្ត) បានដល់ ទេវតាជាន់និម្មានរតី ។ ពិតហើយ ទេវតាទាំងនោះ ហៅថា និម្មានរតី និងមនាបា ព្រោះនិម្មិតរូបដែលខ្លួនប្រាថ្នា ហើយអភិរម្យ ។

ចប់អដ្ឋកថា ឧគ្គហសូត្រទី ៣

# អដ្ឋកថា សីហសូត្រទី ៤

## (ផលនៃទាន ៥ ប្រការ)

គប្បីជ្រាបវិនិច្ឆ័យក្នុង សីហសូត្រទី ៤ ដូចតទៅនេះ ៖

[៣៤] បទថា **សន្ទិដ្ឋិកំ (ដែលឃើញច្បាស់ដោយខ្លួនឯង)** បានដល់ ដែលគប្បីឃើញក្នុងបច្ចុប្បន្ន ។ បទថា **ទាយកោ (ទាយក)** បានដល់ គឺជាអ្នកហ៊ានក្នុងការឲ្យទាន ។ អធិប្បាយថា មិនមែនឈប់ដោយហេតុត្រឹមតែជឿថា ទានជារបស់ល្អប៉ុណ្ណោះទេ ក៏អាចបរិច្ចាគបានផង ។ បទថា **ទានបតិ (ជាម្ចាស់នៃទាន)** បានដល់ ឲ្យទានណា ក៏ជាម្ចាស់នៃការឲ្យទាននោះ ។ មិនមែនទាសៈ និងមិនមែនជាសហាយទាន ។ ក៏បុគ្គលណា ខ្លួនឯងបរិភោគរបស់ឆ្ងាញ់ តែឲ្យរបស់មិនឆ្ងាញ់ដល់បុគ្គលដទៃ បុគ្គលនោះជាទាសៈនៃទេយ្យធម៌ ពោលគឺ ទាសៈនៃទាន ។ បុគ្គលណា ខ្លួនឯងបរិភោគវត្ថុណា ឲ្យវត្ថុនោះឯង បុគ្គលនោះជាសម្លាញ់នៃទាន ។ ចំណែកបុគ្គលណា ខ្លួនឯងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយរបស់ធម្មតាៗ តែឲ្យរបស់ដែលឆ្ងាញ់ដល់អ្នកដទៃ បុគ្គលនោះឈ្មោះថា ជាធំ ជាម្ចាស់នៃការឲ្យ ។ ព្រះមានព្រះភាគត្រាស់សំដៅដល់ទាយក ដែលមានសភាពដូច្នោះថា ជាទានបតី

ដូច្នេះ ។

បទថា **អមង្កុភូតោ** (មិនមានសេចក្ដីអៀនខ្មាស) បានដល់ មិនមែនជាអ្នកគ្មានអំណាច ។ បទថា **សហព្យគតា** (ដល់ភាពជាសំឡាញ់របស់ទេវតា) បានដល់ រួមគ្នាតែមួយ ។ បទថា **កតាវកាសា** (បានឱកាស) សេចក្ដីថា មានឱកាសធ្វើកម្មណាក្នុងទីនោះ ឈ្មោះថា មានឱកាស ព្រោះខ្លួនធ្វើកម្មនោះហើយ តែព្រោះហេតុដែលកម្មនោះជាកុសលតែម្យ៉ាង ព្រោះដូច្នោះ ទើបត្រាស់ថា **កតកុសលា** (មានកុសលធ្វើហើយ) បានដល់ ធ្វើកុសលទុក ។ បទថា **មោទរេ** (ជាទីត្រេកអរ) គឺ រីករាយ ។ បទថា **អសិតស្ស** (អ្នកមិនមានកិលេស) បានដល់ ព្រះតថាគត ដែលកិលេសមិនអាស្រ័យហើយ ។ បទថា **តាទិនោ** (ប្រកដដោយតាទិគុណ) គឺ ជាអ្នកដល់លក្ខណៈប្រមាណមិនបាន ។

ចប់អដ្ឋកថា សុមនវគ្គទី ៤

# អដ្ឋកថា ទានានិសំសសូត្រទី ៥

## (អានិសង្សនៃការឲ្យទាន ៥ យ៉ាង)

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទានានិសង្សសូត្រទី ៥ ដូចតទៅនេះ ៖*

*[៣៥] បទថា **គិហិធម្មា អនបគតោ ហោតិ** (មិនប្រាសចាកធម៌របស់គ្រហស្ថ) បានដល់ ជាអ្នកមានសីល ៥ មិនដាច់ ។ បទថា **សតំ ធម្មំ អនុក្កមំ** (ជាអ្នកអនុកូលទៅតាមធម៌របស់សប្បុរស) បានដល់ ជាអ្នកប្រព្រឹត្តតាមធម៌របស់សប្បុរស គឺ មហាបុរស ។ បទថា **សន្តោ នំ ភជន្តិ**[១] (អ្នកសង្រួមមានចិត្តស្ងប់រម្ងាប់ រមែងរាប់រកបុគ្គលនោះសព្វកាល) បានដល់ សប្បុរសទាំងឡាយ គឺ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវករបស់ព្រះតថាគត រមែងគប់រកគេ ។*

ចប់អដ្ឋកថា ទានានិសង្សសូត្រទី ៥

---

*(១) បិដក = សន្តោ នំ សទា ភជន្តិ ។*

# អដ្ឋកថា កាលទានសូត្រទី ៦

*(កាលទាន ៥)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កាលទានសូត្រទី ៦ ដូចតទៅនេះ ៖*

*[៣៦] បទថា **កាលទានានិ (កាលទាន)** គឺ ទានដែលគួរ ទានដែលមកដល់ហើយ អធិប្បាយថា ទានដែលសមគួរ ។ បទថា **នវសស្សានិ (បានតម្កល់ស្រូវថ្មី)** បានដល់ ស្រូវដែលល្អបំផុត ។ បទថា **នវផលានិ (ផ្លែឈើដំបូង)** បានដល់ ផ្លែឈើល្អបំផុតដែលផ្លែគ្រាដំបូងអំពីចម្ការ ។ បទថា **បឋមំ សីលវន្តេសុ បតិដ្ឋាបេតិ (ដល់បុគ្គលមានសីលទាំងឡាយជាដំបូង)** សេចក្តីថា រមែងថ្វាយដល់លោកអ្នកមានសីលមុនហើយ ខ្លួនទើបបរិភោគជាខាងក្រោយ ។ បទថា **វទញ្ញូ (ដឹងភាសិតរបស់អ្នកប្រាជ្ញ)** បានដល់ ដឹងពាក្យដែលជាសុភាសិត ។ បទថា **កាលេន ទិន្នំ (រមែងឲ្យទានតាមកាលគួរ)** បានដល់ ទានដែលគេឲ្យសមគួរដល់ការនាំចូលមក ។ បទថា **អនុមោទន្តិ (អនុមោទនា)** បានដល់ ឈរអនុមោទនាក្នុងទីដ៏សមគួរមួយ ។ បទថា **វេយ្យាវច្ចំ (ធ្វើសេចក្តីខ្វល់ខ្វាយ)** បានដល់ ធ្វើការខ្វល់ខ្វាយតាមផ្លូវកាយ ។ បទថា **អប្បដិវាសណចិត្តោ (បុគ្គលដែលមានចិត្ត***

មិនរាយមាយ) បានដល់ ជាអ្នកមានចិត្តមិននឿយណាយ ។ បទថា យត្ថ ទិន្នំ មហប្ផលំ (ជាទានមានផលច្រើន) បានដល់ គប្បីឲ្យក្នុងទីដែលឲ្យហើយ មានផលច្រើន ។

ចប់អដ្ឋកថា កាលទានសូត្រទី ៦

# អដ្ឋកថា ភោជនទានសូត្រទី ៧

*(ទាយកឲ្យភោជន ឈ្មោះថា ឲ្យឋានៈ ៥ យ៉ាងដល់បដិគ្គាហកៈ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុងភោជនទានសូត្រទី ៧ ដូចតទៅនេះ៖*

[៣៧] *បទថា* ***អាយុំ ទេតិ*** *(ឲ្យអាយុ) បានដល់ រមែងឲ្យអាយុជាទាន ។ បទថា* ***វណ្ណំ*** *(វណ្ណៈ) គឺ ពណ៌សម្បុរនៃរាងកាយ ។ បទថា* ***សុខំ*** *(សុខ) បានដល់ សុខផ្លូវកាយ និងផ្លូវចិត្ត ។ បទថា* ***ពលំ*** *(កម្លាំង) គឺ កម្លាំងនៃរាងកាយ ។ បទថា* ***បដិភាណំ*** *(បដិភាណ) បានដល់ ឆ្លាតក្នុងការចងបញ្ហា និងដោះស្រាយបញ្ហា ។*

ចប់អដ្ឋកថា ភោជនទានសូត្រទី ៧

# អដ្ឋកថា សទ្ធានិសំសសូត្រទី ៨

*(អានិសង្សរបស់សទ្ធា ៥ ប្រការ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សទ្ធានិសង្សសូត្រទី ៨ ដូចតទៅនេះ ៖*

*[៣៨] បទថា **អនុកម្បន្តិ** (រមែងអនុគ្រោះ) បានដល់ រមែងលើកសរសើរ ។ បទថា **ខន្ធិមាវ មហាទុមោ** (ដើមឈើធំ មានដើមរឹងមាំ) គឺដូចដើមឈើធំសម្បូរដោយមែក ។ បទថា **មនោរមេ អាយតនេ** (ដែលជាទីរីករាយនៃចិត្ត នាំឲ្យកើតសុខ) បានដល់ ក្នុងទីជំនុំដែលគួររីករាយ ។ បទថា **ឆាយំ ឆាយត្ថិកា យន្តិ** (ពួកសត្វដែលត្រូវការម្លប់ ក៏ទៅជ្រកម្លប់) បានដល់ អ្នកត្រូវការម្លប់ ក៏ចូលទៅអាស្រ័យម្លប់ ។ បទថា **និវាតវុត្តី** (ឱនលំទោន) បានដល់ ប្រព្រឹត្តទន់ភ្លន់ ។ បទថា **អត្ថទ្ធំ** (មិនរឹងរូស) បានដល់ លះបង់ចោលភាពជាមនុស្សរឹងរូស ។ បទថា **សុរតំ** (ស្លូតត្រង់) បានដល់ ជាអ្នកប្រកបដោយសេចក្តីស្ងប់ស្ងៀម មានសីលស្អាត ។ បទថា **សខិលំ** (សុភាព) បានដល់ គួររីករាយនៃចិត្ត ។*

ចប់អដ្ឋកថា សទ្ធានិសង្សសូត្រទី ៨

# អដ្ឋកថា បុត្តសូត្រទី ៩

## (មាតាបិតាត្រូវការឋានៈ ៥ យ៉ាងពីបុត្ត)

គប្បីជ្រាបវិនិច្ឆ័យក្នុង បុត្តសូត្រទី ៩ ដូចតទៅនេះ ៖

[៣៩] បទថា **ភតោ វា នោ ភរិស្សតិ (គឺបុត្រដែលយើងចិញ្ចឹមហើយ នឹងចិញ្ចឹមយើងវិញ)** សេចក្តីថា បុត្រដែលយើងចិញ្ចឹមមកហើយ បីបាច់ថែរក្សា ដោយឲ្យផឹកទឹកដោះ និងញ៉ាំងដៃ និងជើងឲ្យចម្រើនធំធាត់ជាដើម ក្នុងវេលាយើងចាស់ គេនឹងចិញ្ចឹមយើងវិញ ដោយការលាងដៃនិងជើង ឲ្យងូតទឹក និងឲ្យបបរបាយជាដើម ។ បទថា **កិច្ចំ វា នោ ករិស្សតិ (នឹងធ្វើកិច្ចដល់យើង)** សេចក្តីថា គេសម្រាកការងាររបស់ខ្លួនហើយ នឹងទៅជួយធ្វើកិច្ចរបស់យើង ដែលកើតឡើងក្នុងរាជត្រកូលជាដើម ។ បទថា **កុលវំសោ ចិរំ ឋស្សតិ (វង្សត្រកូលនឹងស្ថិតនៅយូរ)** សេចក្តីថា កាលបុត្ររក្សា មិនធ្វើសម្បត្តិរបស់យើង មានស្រែ ចម្ការ ប្រាក់ និងមាសជាដើមឲ្យវិនាស វង្សត្រកូលក៏នឹងតាំងនៅយូរបាន ។ មួយទៀត គេមិនធ្វើស្លាកកត្តទានជាដើម ដែលយើងប្រព្រឹត្តមកហើយឲ្យដាច់ខ្សែ រមែងឲ្យប្រព្រឹត្តទៅ វង្សត្រកូលរបស់យើងក៏នឹងតាំងនៅយូរ ។ បទថា **ទាយជ្ជំ បដិបជ្ជតិ (ប្រតិបត្តិគួរដើម្បីទទួលមត៌ក)** សេចក្តីថា បុត្រកាលប្រព្រឹត្តខ្លួន

សមគួរដល់មតិក ដោយការបដិបត្តិដ៏សមគួរដល់វង្សត្រកូល ក៏នឹងគ្រប់គ្រងមតិក ដែលជាសម្បត្តិរបស់យើងបាន ។ បទថា **ទក្ខិណំ អនុប្បទស្សតិ (នឹងឧទ្ទិសទក្ខិណាទានឲ្យដល់យើង)** សេចក្តីថា បុត្រនឹងធ្វើទានឧទ្ទិសចំណែកបុណ្យឲ្យ តាំងពីថ្ងៃទីបីរាប់តាំងពីថ្ងៃស្លាប់ ។ បទថា **សន្តោ សប្បុរិសា** សេចក្តីថា គប្បីជ្រាបថា បុត្រទាំងនោះជាសប្បុរស មនុស្សល្អ ដោយការបដិបត្តិប្រពៃក្នុងមាតាបិតាក្នុងឋានៈនេះ ។ បទថា **បុព្វេ កតមនុស្សរំ (កាលរលឹកឃើញនូវឧបការៈគុណដែលលោកធ្វើហើយក្នុងកាលមុន)** សេចក្តីថា កាលរលឹកដល់គុណ ដែលមាតាបិតាធ្វើទុកក្នុងកាលមុនហើយ ។ បទថា **ឱវាទការី (បុត្រដែលធ្វើតាមឱវាទ)** បានដល់ ជាអ្នកធ្វើតាមឱវាទ ដែលមាតាបិតាទុកឲ្យហើយ ។ បទថា **ភតបោសី (អ្នកចិញ្ចឹមមាតាបិតា)** បានដល់ បុត្រនឹងចិញ្ចឹមថែរក្សាមាតាបិតា ដែលលោកចិញ្ចឹមខ្លួនមក ។ បទថា **បសំសិយោ (ដែលអ្នកផងគប្បីសរសើរ)** សេចក្តីថា ជាអ្នកដែលមហាជនគប្បីសរសើរក្នុងបច្ចុប្បន្នទុំះឯង ។

ចប់អដ្ឋកថា បុត្តសូត្រទី ៩

# អដ្ឋកថា សាលសូត្រទី ១០

## (សេចក្ដីចម្រើន ៥ ប្រការ)

គប្បីជ្រាបវិនិច្ឆ័យក្នុង សាលសូត្រទី ១០ ដូចតទៅនេះ ៖

[៤០] បទថា *មហាសាលា* (ដើមសាលៈធំ) គឺ ដើមឈើធំ ។ បទថា *សាខាបត្តបលាសេន វឌ្ឍន្តិ* (គឺចម្រើនដោយមែក ស្លឹក ត្រួយ) ចម្រើនដោយមែកតូច និងស្លឹក ដែលហៅថា បត្តៈ ។ បទថា *អរញ្ញស្មឹ* (ក្នុងព្រៃ) គឺ ក្នុងទីមិនមែនស្រុក ។ បទថា *ព្រហាវនេ* (ដងព្រៃធំ) បាន ដល់ ក្នុងព្រៃធំ គឺ ព្រៃក្រាស់ បទដ៏សេសក្នុងទីគ្រប់កន្លែងងាយហើយ នោះឯង ។

ចប់អដ្ឋកថា សាលសូត្រទី ១០

## ចប់សុមនវគ្គវណ្ណនាទី ៤

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# មុណ្ឌរាជវគ្គវណ្ណនាទី ៥

## អដ្ឋកថា អាទិយសូត្រទី ១

*(ការប្រើភោគទ្រព្យឲ្យជាប្រយោជន៍ ៥ យ៉ាង)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាទិយសូត្រទី ១ ដូចតទៅនេះ ៖*

[៤១] *បទថា* ***ភោគានំ អាទិយា*** *(ការកាន់យកនូវភោគៈ) បានដល់ហេតុនៃភោគៈទាំងឡាយដែលគប្បីកាន់យកប្រយោជន៍ ។ បទថា* ***ឧដ្ឋានវិរិយាធិគតេហិ*** *(ដែលខ្លួនបានមកដោយសេចក្ដីប្រឹងប្រែង) បានដល់ ដែលបានមកដោយសេចក្ដីប្រឹងប្រែង ពោលគឺ សេចក្ដីព្យាយាម ។ បទថា* ***ពាហាពលបរិចិតេហិ*** *(ដែលខ្លួនសន្សំមកដោយកម្លាំងដៃ) បានដល់ ដែលសន្សំទុកដោយកម្លាំងដៃ ។ បទថា* ***សេទាវក្ខិត្តេហិ*** *(មានញើសហូរចេញ) បានដល់ ដែលបានមកដោយញើសហូរចេញ ។ បទថា* ***ធម្មិកេហិ*** *(ប្រកបដោយធម៌) គឺ បានសេពគប់នឹងធម៌ ។ បទថា* ***ធម្មលទ្ធេហិ*** *(បានមកដោយធម៌) បានដល់ មិនលះបង់កុសលកម្មបថ ១០ ។ បទថា* ***បីណេតិ*** *(ឲ្យឆ្អែត) បានដល់ ធ្វើឲ្យឆ្អែតស្កប់ស្កល់ ។ បទដ៏សេសក្នុងសូត្រនេះ គប្បីជ្រាបដោយន័យដែលពោលទុកហើយក្នុងចតុក្កនិបាតនោះឯង ។*

ចប់អដ្ឋកថា អាទិយសូត្រទី ១

# អដ្ឋកថា សប្បុរិសសូត្រទី ២

[៤២] *សប្បុរិសសូត្រទី ២ មានសេចក្ដីងាយយល់ហើយ ។*

ចប់អដ្ឋកថា សប្បុរិសសូត្រទី ២

# អដ្ឋកថា ឥដ្ឋសូត្រទី ៣

*(ធម៌ដែលគួរប្រាថ្នារកបានលំបាក ៥ យ៉ាង)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឥដ្ឋសូត្រទី ៣ ដូចតទៅនេះ ៖*

[៤៣] *បទថា* ***អាយុសំវត្តនិកា បដិបទា*** *(ដើម្បីបានទូវអាយុ) បដិបទា គឺ បុណ្យ មានទាន និងសីលជាដើម ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។ បទថា* ***អត្ថាភិសមយា*** ***(រមែងបានសម្រេចប្រយោជន៍ទាំងពីរ)*** *បានដល់ សម្រេចប្រយោជន៍ អធិប្បាយថា ព្រោះបានប្រយោជន៍ ។*

ចប់អដ្ឋកថា ឥដ្ឋសូត្រទី ៣

# អដ្ឋកថា មនាបទាយីសូត្រទី ៤

## (បុគ្គលឲ្យរបស់ដែលពេញចិត្តរមែងបានរបស់ដែលពេញចិត្ត)

គប្បីជ្រាបវិនិច្ឆ័យក្នុង មនាបទាយីសូត្រទី ៤ ដូចតទៅនេះ ៖

[៤៤] បទថា **ឧគ្គោ** (ឧគ្គ) បានដល់ បុគ្គលបានឈ្មោះយ៉ាងនេះ ព្រោះជាបុគ្គលខ្ពស់ដោយគុណទាំងឡាយ ។ បទថា **សាលបុប្ផកំ ខាទនីយំ (ខាទនីយាហារប្រាកដស្មើដោយផ្កាសាលព្រឹក្ស)** បានដល់ របស់ទំពាស្រដៀងនឹងផ្កាសាលព្រឹក្ស ធ្វើដោយម្សៅស្រូវសាលី ផ្សំដោយរបស់ឆ្ងាញ់ទាំង ៤ ប្រភេទ ពិតហើយ របស់ទំពាមួយប្រភេទ គេធ្វើឲ្យមានពណ៌ដូចទឹកដោះគោ ចៀនក្នុងខ្លាញ់ ដែលផ្សំដោយគ្រឿងទេសគ្រប់មុខជាដើម ឆ្អិនហើយហាលឲ្យស្ងួតខ្លាញ់ ដាក់ក្នុងកាជនៈដែលមានគំរប អប់ក្លិនឲ្យក្រអូបរក្សាទុក ។ ឧគ្គគហបតីបំណងនឹងថ្វាយក្នុងចន្លោះអាហារ ទើបក្រាបទូលយ៉ាងនេះ ចំពោះព្រះមានព្រះភាគព្រះអង្គនោះ ដែលកំពង់អង្គៀសព្រះមានព្រះ-ភាគ ។ បទថា **បដិគ្គហេសិ ភគវា (ព្រះមានព្រះភាគទ្រង់ទទួលដោយសេចក្តីអនុគ្រោះ)** នោះ មានត្រឹមតែទេសនា ។ ក៏ឧបាសកបានថ្វាយខាទ-និយៈនោះ ចំពោះព្រះមានព្រះភាគ និងភិក្ខុសង្ឃ ៥០០ រូប ឧបាសកបានថ្វាយសូម្បីសូករមំសៈ (សាច់ជ្រូក) ជាដើម ក៏ដូចជាថ្វាយខាទនីយៈនោះ

ដូច្នោះ ។ ក្នុងបទទាំងនោះ បទថា **សម្បន្នវរសូករមំសំ** (សូករមំសៈដ៏ប្រសើរ) សេចក្ដីថា សូករមំសៈដែលផ្សំដោយគ្រឿងទេសគ្រប់មុខជាដើម និងផ្លែពុទ្រាដែលមានរសឆ្ងាញ់ ធ្វើឲ្យឆ្អិនហើយ រក្សាទុកមួយឆ្នាំ ទើបបរិភោគ ។ បទថា **និព្វត្តតេលកំ** (ដែលច្រឡំដោយប្រេង) គឺ បង់ក្នុងខ្លាញ់ពុះហើយ ។ បទថា **នាលិយសាកំ** (នាលិយសាកៈ) បានដល់កូរនាឡិយៈ ដែលច្របាច់ជាមួយម្សៅស្រូវសាលី ហើយចៀននឹងប្រេងផ្សំដោយរសផ្អែម ៤ ប្រភេទ ហើយអប់ទុក ។ ក្នុងបទថា **នេតំ ភគវតោ កប្បតិ** (របស់នុ៎ះមិនគួរដល់ព្រះមានព្រះភាគ) នេះ លោកសំដៅដល់របស់ដែលជាកប្បិយៈថា ដែលរួមចូលជាមួយរបស់ដែលជាអកប្បិយៈ រមែងមិនគួរ ។

សេដ្ឋីឲ្យនាំរបស់ទាំងអស់នោះមក ហើយធ្វើឲ្យជាដុំ វត្ថុណាដែលជាអកប្បិយៈក៏បញ្ជូនវត្ថុនោះៗ ឲ្យទៅកាន់រានផ្សារ ទើបថ្វាយគ្រឿងឧបភោគនិងបរិភោគដែលជាកប្បិយៈ បន្ទះក្ដារចន្ទន៍មិនធំពេក ប្រវែងប្រមាណ ២ ហត្ថ ១ ចំអាម ទទឹងប្រមាណ ១ ហត្ថ ១ ចំអាម ដែលជារបស់មានតម្លៃច្រើន ព្រោះជាឈើដែលមានខ្លឹមល្អ ព្រះមានព្រះភាគទ្រង់ទទួលបន្ទះឈើចន្ទន៍នោះហើយ ទ្រង់ប្រោសឲ្យច្រៀកជាចំរៀកតូចៗ ត្រាស់ឲ្យប្រគេនដល់

ភិក្ខុទាំងឡាយ ដើម្បីបុកធ្វើជាថ្នាំបន្តក់ភ្នែក ។

បទថា **ឧជុភូតេសុ (អ្នកមានកាយវាចាចិត្តត្រង់)** បានដល់ អ្នកបដិបត្តិត្រង់ដោយកាយ វាចា ចិត្ត ។ បទថា **ឆន្ទសា (ជាទីគាប់ចិត្ត)** បានដល់ សេចក្ដីស្រឡាញ់ ។ ក្នុងបទថា **ចត្តំ (បរិច្ចាគហើយ)** ជាដើម ឈ្មោះថា លះបង់ហើយដោយអំណាចការបរិច្ចាគ បទថា **មុត្តំ (លះបង់ហើយ)** បានដល់ ការលះបង់ដោយមិនមានសេចក្ដីស្ដាយក្រោយឡើយ ។ ឈ្មោះថា **អនុគ្គហីតំ (មិនកាន់យក)** ព្រោះចិត្តមិនគិតនឹងកាន់យក ព្រោះមានចិត្តមិនស្ដាយក្រោយ ។ បទថា **ខេត្តូបមេ (របស់ជាទីគាប់ចិត្ត)** បានដល់ ដូចជាស្រែ ព្រោះជាទីដុះឡើង ។ បទថា **អញ្ញតរំ មនោមយំ (ក៏ទៅកើតក្នុងពួកទេវតា ដែលសម្រេចដោយចិត្តណាមួយ)** បានដល់ ពួកទេវតាដែលសម្រេចដោយចិត្ត នៅក្នុងឈានណាមួយ ក្នុងជាន់សុទ្ធាវាស ។ បទថា **យថាធិប្បាយោ (សេចក្ដីសមប្រកបតាមបំណង)** គឺ តាមវត្ថុដែលពេញចិត្ត ។ ហេតុអ្វីបានព្រះមានព្រះភាគទ្រង់សួរពាក្យនេះ ។ បានឮថា លោកមានអធ្យាស្រ័យសម្គាល់ព្រះអរហត្តក្នុងកាលកើតជាមនុស្ស ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់សួរថា តថាគតនឹងសួរប្រការនោះ ។ សូម្បីទេវបុត្របានក្រាបទូលថា **តគ្ឃ មេ ភគវា យថាធិប្បាយោ (សេចក្ដី**

សម្រេចតាមបំណងរបស់ខ្ញុំព្រះអង្គមានដែរ) ក៏ព្រោះលោកបានសម្រេចជាព្រះអរហន្តហើយ ។ បទថា យត្ថ យត្ថូបបជ្ជតិ (មានយសសក្តិក្នុងទីនោះៗ ) សេចក្តីថា គេរមែងកើតក្នុងទីណាៗ គឺ ក្នុងកុលសម្បត្តិ ៣ ឬក្នុងកាមាវចរសួគ៌ ៦ ជាន់ ក៏ជាអ្នកមានអាយុវែង មានយសក្នុងភពនោះៗ ឯង ។

ចប់អដ្ឋកថា មនាបទាយីសូត្រទី ៤

# អដ្ឋកថា អភិសន្ទសូត្រទី ៥

*(អន្លង់បុណ្យ អន្លង់កុសល ៥ ប្រការ)*

[៤៥] *អភិសន្ទសូត្រទី ៥ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងចតុក្កនិបាតនោះឯង ។*

ចប់អដ្ឋកថា មុណ្ឌរាជវគ្គទី ៥

# អដ្ឋកថា សម្បទាសូត្រទី ៦

*(សម្បទា ៥ ប្រការ)*

[៤៦] *សម្បទាសូត្រ មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា សម្បទាសូត្រទី ៦

# អដ្ឋកថា ធនសូត្រទី ៧

*(ទ្រព្យ ៥ ប្រការ)*

[៤៧] *ធនសូត្រ មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា ធនសូត្រទី ៧

# អដ្ឋកថា ឋានសូត្រទី ៨

## *(ឋានៈ ៥ ប្រការ ដែលនរណាៗ មិនគប្បីបាន)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឋានៈសូត្រទី ៨ ដូចតទៅនេះ ៖*

*[៤៨] បទថា **អលព្ភនីយានិ** (ហេតុដែលមិនគប្បីបាន) បានដល់ក្នុងឋានៈណាៗ មិនគប្បីបាន គឺ មិនអាចនឹងបាន ។ បទថា **ឋានានិ** (ឋានៈ) គឺ ហេតុ ។ បទថា **ជរាធម្មំ មា ជីរតិ** (របស់ដែលមានជរាជាធម្មតា) សេចក្តីថា វត្ថុណាជារបស់យើង វត្ថុទាំងអស់នោះ មានសភាពចាស់ទ្រុឌទ្រោមទៅជាធម្មតា សូមវត្ថុនោះចូរកុំចាស់ ។ សូម្បីក្នុងបទដ៏សេសក៏ន័យនេះដូចគ្នា ។ បទថា **នច្ចាទេយ្យ** (មិនគប្បីឃ្លានភត្តផង) បានដល់មិនពេញចិត្ត ។ បទថា **អព្ពុហិ** (ដក) គឺ នាំចេញទៅ ។*

*បទថា **យតោ** (ក្នុងទីណា) គឺ កាលណា ។ បទថា **អាបទាសុ** (ក្នុងឧបទ្រវៈ) គឺ ក្នុងឧបទ្រវៈទាំងឡាយ ។ បទថា **ន វេធតិ** (ទើបមិនញាប់ញ័រ) បានដល់ មិនរញ្ជួយចិត្ត មិនសោកសៅ ។ បទថា **អត្ថវិនិច្ឆយញ្ញូ** (ក្នុងការវិនិច្ឆ័យនូវហេតុនិងផល) គឺ ជាអ្នកឈ្លាសក្នុងការវិនិច្ឆ័យហេតុផល ។ បទថា **បុរាណំ** (នូវដដែល) បានដល់ នូវដូចដើមនុ៎ះឯង ព្រោះមិនមានការប្រែប្រួលទៅ ។ បទថា **ជប្បេន** (គឺការនិយាយសរសើរ) គឺ*

ព្រោះការពោលសរសើរ ។ បទថា **មន្តេន** (ការរាយមន្ត) គឺ ព្រោះការរាយមន្តដែលមានអានុភាពច្រើន ។ បទថា **សុភាសិតេន** (ការនិយាយជាសុភាសិត) គឺ ដោយការពោលពាក្យជាសុភាសិត ។ បទថា **អនុប្បទានេន** (ព្រោះការបំពេញទាន) បានដល់ ព្រោះការឲ្យទ្រព្យ ១ រយ ឬ ១ ពាន់ ។ បទថា **បវេណិយា វា** (បវេណីក្តី) បានដល់ វង្សត្រកូល អធិប្បាយថា ព្រោះការពោលដល់ប្រពៃណីយ៉ាងនេះថា ប្រពៃណីនេះរបស់យើងប្រព្រឹត្តតាមគ្នាមកហើយ វត្ថុនេះមិនបានប្រព្រឹត្តមកហើយទេ ។ បទថា **យថា យថា យត្ថ លភេថ អត្ថំ** (បុគ្គលគប្បីបានប្រយោជន៍ក្នុងទីណា ដោយប្រការណាៗ) សេចក្តីថា នឹងគប្បីបានប្រយោជន៍ មានការមិនចាស់ជាដើម នៃវត្ថុទាំងឡាយ ដែលមានការចាស់ជាធម្មតាជាដើម ក្នុងទីណាៗ ដោយប្រការណាៗ ព្រោះការសរសើរជាដើមទាំងនោះ ។ បទថា **តថា តថា តត្ថ បរក្កមេយ្យ** (គប្បីព្យាយាមក្នុងទីនោះ ដោយប្រការនោះៗ) បានដល់ គប្បីធ្វើសេចក្តីតស៊ូពុះពារក្នុងទីនោះៗ ដោយប្រការនោះៗ ។ បទថា **កម្មំ ទឡ្ហំ** (កម្មដ៏មាំ) បានដល់ កម្មដែលញុំាងសត្វឲ្យវិលវល់នៅក្នុងវដ្តៈ យើងសន្សំទុកមុតមាំហើយ ។ គួរពិចារណាយ៉ាងនេះថា ឥឡូវនេះ យើងនឹងធ្វើអ្វីតទៅទៀត ។

ចប់អដ្ឋកថា ឋានសូត្រទី ៨

# អដ្ឋកថា កោសលសូត្រទី ៩

## (ឋានៈរកមិនបាន ៥ ប្រការ)

*គប្បីជ្រាបវិនិច្ឆ័យក្នុង កោសលសូត្រទី ៩ ដូចតទៅនេះ ៖*

*[៤៩] បទថា **ឧបកណ្ណកេ** (ក្រាបទូលជិតព្រះកាណ៌) បានដល់ ទីជិតព្រះកាណ៌ ។ បទថា **ទុម្មនោ** (មានទុក្ខទោមនុស្ស) បានដល់ ទាស់ព្រះទ័យ ។ បទថា **បត្តក្ខន្ធោ** (មានព្រះស្មុរឆ័ឱនចុះ) បានដល់ មានក្បាលឱនចុះ ។ បទថា **បជ្ឈាយន្តោ** (គង់សញ្ជប់សញ្ជឹង) បានដល់ ទ្រង់មិនហ៊ានគិត ។ បទថា **អប្បដិភាណោ** (មិនមានបដិភាណ) បានដល់ ទ្រង់គិតមិនចេញ ។ ពាក្យដ៏សេសមានន័យដូចពោលហើយក្នុងខាងក្រោយនោះឯង ។*

ចប់អដ្ឋកថា កោសលសូត្រទី ៩

# អដ្ឋកថា នារទសូត្រទី ១០

## *(ឋានៈ ៥ ដែលនរណាៗ ក្នុងលោកមិនគប្បីបាន)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង នារទសូត្រទី ១០ ដូចតទៅនេះ ៖*

[៥០] *បទថា* ***អជ្ឈាមុច្ឆិតោ (ទ្រង់ពេញព្រះទ័យ)*** *បានដល់ ទ្រង់ពេញចិត្តយ៉ាងក្រៃលែង គឺ ទ្រង់ប្រកបដោយសេចក្ដីស្រឡាញ់ ជាប់ចិត្តដ៏ក្រៃលែង ដែលមានសភាពអត់ធន់បានដោយលំបាក ។ បទថា* ***មហច្ចរាជានុភាវេន (ដោយអនុភាពធំ)*** *មានសេចក្ដីថា ទ្រង់មានមេទ័ព ១៨ នាក់ហែហមហើយដោយព្រះរាជានុភាពដ៏ធំក្រៃលែង ស្ដេចចេញទៅដោយឫទ្ធិដ៏ធំ ។ ស័ព្ទថា* ***តគ្ឃ*** *ជានិបាតចុះក្នុងអត្ថថា ពិតដោយចំណែកមួយ ។ អធិប្បាយថា ធម៌ជាគ្រឿងនាំចេញនូវសេចក្ដីសោក ដោយចំណែកមួយ ព្រះរាជាទ្រង់ស្ដាប់ឱវាទនេះហើយ ទ្រង់តាំងនៅក្នុងឱវាទនោះ ទ្រង់គ្រប់គ្រងរាជសម្បត្តិដោយធម៌ដោយប្រពៃហើយ ជាអ្នកមានមុខឆ្ពោះទៅកាន់ស្ថានសួគ៌ហើយ ដោយប្រការដូច្នេះ ។*

ចប់អដ្ឋកថា នារទសូត្រទី ១០

**ចប់មុណ្ឌរាជវគ្គវណ្ណនាទី ៥**

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៧ សូត្រ

**ចប់បឋមបណ្ណាសកៈ**

# ទុតិយបណ្ណាសកៈ

## នីវរណវគ្គវណ្ណនាទី ១

## អដ្ឋកថា អាវរណសូត្រទី ១

*(នីវរណៈ ៥ យ៉ាង)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាវរណសូត្រទី ១ ដូចតទៅនេះ ៖*

[៥១] *កិលេសទាំងឡាយ ឈ្មោះថា* ***អាវរណា*** *(គ្រឿងទប់) ព្រោះអំណាចបិទបាំង ។ ឈ្មោះថា* ***នីវរណា*** *(រាំង) ព្រោះមានអំណាចការពារ ។ បទថា* ***ចេតសោ អជ្ឈារុហា*** *(គ្របសង្កត់នូវចិត្ត) បានដល់ ពេលគ្របសង្កត់ចិត្តបានហើយ ។ ដែលឈ្មោះថា* ***បញ្ញាយ ទុព្វលីករណា*** *(ធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ) ព្រោះអត្ថថា ធ្វើវិបស្សនាបញ្ញា និងមគ្គឲ្យវិនាស ដោយអត្ថថា ហាមការកើតឡើង ។ ន័យម្យ៉ាងទៀត ដែលឈ្មោះថា* ***ធ្វើបញ្ញាថយកម្លាំង*** *ព្រោះអត្ថថា ព្រោះបញ្ញាដែលច្របូលច្របល់ដោយកិលេសទាំងនេះកើតឡើង កិលេសទាំងនោះ ធ្វើបញ្ញានោះឲ្យវិនាស ដូច្នេះក៏មាន ។ បទថា* ***អពលាយ*** ***(មិនមានកម្លាំង)*** *បានដល់ ឈ្មោះថា ប្រាសចាកកម្លាំង ព្រោះត្រូវនីវរណៈ ៥ រួបរឹតទុក ។ បទថា* ***ឧត្តរឹ វា មនុស្សធម្មា អលម-***

រិយញ្ញាណទស្សនវិសេសំ (នូវញាណទស្សនវិសេសល្មមឲ្យបាននូវអរិយ-ភាពដ៏លើសលុបជាមនុស្សធម៌តទៅ) បានដល់ នូវញាណទស្សនវិសេស ដែលអាចធ្វើភាពជាព្រះអរិយៈឲ្យក្រៃលែងជាងមនុស្សធម៌ ពោលគឺ កុសល-កម្មបថ ១០ យ៉ាង ។

បទថា ហារហារនី (ហូរនាំយកទាំងសំណាត់ទៅ) គឺ អាចនឹងនាំយកវត្ថុដែលល្មមអាចយកទៅបាន ។ បទថា នង្គលមុខានិ (បើកមាត់ប្រឡាយ) គឺ មុខផ្លូវទឹក ពិតណាស់ ជនទាំងឡាយហៅមុខផ្លូវទឹកទាំងនោះថា មាត់ប្រឡាយ ព្រោះហេតុដែលគេយកនង្គ័លកួរ ធ្វើឲ្យជាស្នាមគន្លងទុក ។ ក្នុងបទថា ឯវមេវ ខោ (យ៉ាងណាមិញ) នេះ វិបស្សនាញាណគប្បីឃើញដូចជាក្រសែទឹក វេលាដែលភិក្ខុប្រមាទមិនសង្រួមក្នុងទ្វារទាំង ៦ គប្បីឃើញដូចវេលាបើកមាត់ប្រឡាយទាំងសងខាង កាលភិក្ខុត្រូវនីវរណៈទាំង ៥ រួបរឹត គប្បីឃើញដូចវេលាដែលគេបោះបង្គោលដើមឈើទុកកណ្ដាលទន្លេ ហើយធ្វើទំនប់ការពារដោយស្លឹកឈើស្ងួត ស្មៅ និងដីស្អិត ទឹកក៏ហូរហៀរសាយទៅហូរខុសផ្លូវ វេលាដែលភិក្ខុមិនអាចនឹងកម្ចាត់អកុសលទាំងឡាយដោយវិបស្សនាញាណ ហើយសម្រេចដល់សាគរ គឺ ព្រះនិព្វានបាន គប្បីជ្រាបដូចវេលាដែលគេធ្វើទំនប់ការពារទុកយ៉ាងនេះ ទឹកដែលមានកម្លាំង

*ខ្សោយ គឺ មិនអាចនាំយកស្លឹកឈើជាដើមទៅដល់សាគរបាន ក្នុងធម៌ដែលជាចំណែកល្អ គប្បីជ្រាបសេចក្តីដែលផ្ទុយគ្នា ដូចដែលពោលមកហើយ ក្នុងសូត្រនេះព្រះមានព្រះភាគត្រាស់ទុកទាំងវដ្តៈ និងវិវដ្តៈ។*

ចប់អដ្ឋកថា អាវរណាសូត្រទី ១

# អដ្ឋកថា រាសិសូត្រទី ២

*(គំនរនៃអកុសល)*

[៥២] *សូត្រទី ២ មានសេចក្តីងាយយល់ហើយ ។*

ចប់អដ្ឋកថា រាសិសូត្រទី ២

# អដ្ឋកថា អង្គសូត្រទី ៣

## (អង្គរបស់ភិក្ខុអ្នកមានសេចក្តីព្យាយាម ៥ យ៉ាង)

គប្បីជ្រាបវិនិច្ឆ័យក្នុង អង្គសូត្រទី ៣ ដូចតទៅនេះ ៖

[៥៣] ក្នុងបទថា **បធានិយង្គានិ** (អង្គនៃសេចក្តីព្យាយាម) ការៈ គឺ ការតាំងសេចក្តីព្យាយាម លោកហៅថា **បធានៈ** ។ សេចក្តីព្យាយាមរបស់ភិក្ខុនោះមាន ព្រោះហេតុនោះ ភិក្ខុនោះឈ្មោះថា អ្នកមានសេចក្តីព្យាយាម ព្រោះហេតុនោះ ទើបឈ្មោះថា អង្គរបស់ភិក្ខុដែលមានសេចក្តីព្យាយាម ។

បទថា **សទ្ធោ** (សទ្ធា) បានដល់ បុគ្គលប្រកបដោយសទ្ធា ក៏សទ្ធានោះមាន ៤ យ៉ាងគឺ **អាគមសទ្ធា ១ អធិគមសទ្ធា ១ ឱកប្បនសទ្ធា ១ បសាទសទ្ធា ១** ។ បណ្តាសទ្ធាទាំង ៤ នោះ សទ្ធារបស់ព្រះសព្វញ្ញូពោធិសត្វ ឈ្មោះថា **អាគមសទ្ធា** ព្រោះផ្តើមការតាំងចិត្តបំពេញបារមី , សទ្ធារបស់អរិយសាវកទាំងឡាយ ឈ្មោះ **អធិគមសទ្ធា** ព្រោះសម្រេចដោយការត្រាស់ដឹងតាមរបស់ព្រះអរិយសាវកទាំងឡាយ ។ សេចក្តីជឿយ៉ាងមុតមាំ ព្រោះមិនញាប់ញ័រ កាលពោលថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ឈ្មោះថា **ឱកប្បនសទ្ធា** , ការកើតឡើងនៃសេចក្តីជ្រះថ្លា ឈ្មោះថា

បសាទសទ្ធា ។ ក្នុងព្រះសូត្រនេះលោកប្រាថ្នាយក **ឱកប្បនសទ្ធា** ។ បទថា **ពោធី** (ញាណជាគ្រឿងត្រាស់ដឹង) បានដល់ មគ្គញាណ ៤ ។ ភិក្ខុរមែងជឿថា មគ្គញាណ ៤ នោះ ដែលព្រះតថាគតត្រាស់ដឹងដោយល្អហើយ ។ ក៏ពាក្យនោះត្រឹមតែបទទេសនាប៉ុណ្ណោះ ។ ក៏សទ្ធាក្នុងរតនៈទាំង ៣ លោកបំណងយកដោយអង្គនេះ ព្រោះថា ភិក្ខុណាមានសេចក្តីជ្រះថ្លាខ្លាំងក្លាក្នុងព្រះពុទ្ធជាដើម សេចក្តីព្យាយាម គឺ បធានៈ រមែងបានសម្រេចដល់ភិក្ខុនោះ ។

បទថា **អប្បាពាធោ** (មិនមានអាពាធ) គឺ អ្នកមិនមានរោគ ។ បទថា **អប្បាតង្កោ** (មិនមានទុក្ខ) គឺ មានទុក្ខតិចតួច ។ បទថា **សម-វេបាកិនិយា** (ជាគ្រឿងដុតកំដៅយ៉ាងល្មម) បានដល់ មានការដុតស្មើល្អ ។ បទថា **គហណិយា** (ប្រកបដោយភ្លើងធាតុ) បានដល់ ភ្លើងធាតុដែលកើតអំពីកម្ម ។ បទថា **នាតិសីតាយ នាច្ចុណ្ហាយ** (មិនត្រជាក់ពេក មិនក្តៅពេក) សេចក្តីថា ពិតណាស់ ភិក្ខុដែលមានភ្លើងធាតុត្រជាក់ពេក រមែងខ្លាចត្រជាក់ អ្នកមានភ្លើងធាតុក្តៅពេក រមែងខ្លាចក្តៅ សេចក្តីព្យាយាមរមែងមិនសម្រេចផលដល់ភិក្ខុទាំងនោះ (តែ) រមែងសម្រេចផលដល់ភិក្ខុដែលមានភ្លើងធាតុមិនក្តៅពេកមិនត្រជាក់ពេក ។ ព្រោះហេតុនោះ ព្រះមាន

ព្រះភាគទើបត្រាស់ថា **មជ្ឈិមាយ បធានក្ខមាយ** (ជាកណ្ដាល សមគួរនឹងធ្វើសេចក្ដីព្យាយាម) ។ បទថា **យថាភូតំ អត្តានំ អាវិកត្តា** (ជាអ្នកធ្វើខ្លួនឲ្យប្រាកដតាមពិត) គឺ ប្រកាសគុណរបស់ខ្លួនតាមសេចក្ដីពិត ។ បទថា **ឧទយត្ថគាមិនិយា** (អាចកំណត់នូវការកើតឡើង និងការរលត់) គឺដែលអាចចូលដល់ គឺ កំណត់ដឹងការកើត និងការរលត់ ព្រះមានព្រះភាគត្រាស់ឧទយព្វយញ្ញាណ ដែលកំណត់ដឹងលក្ខណៈ ៥០ ប្រការ ដោយបទនេះ ។ បទថា **អរិយាយ** (អរិយៈ) គឺ បរិសុទ្ធ ។ បទថា **និព្វេធិកាយ** (ជាគ្រឿងទំលុះទម្លាយកិលេស) គឺ ដែលអាចទំលុះទម្លាយកងកិលេសមានលោភៈជាដើម ដែលមិនធ្លាប់កម្ចាត់បង់អំពីមុនមក ។ បទថា **សម្មាទុក្ខក្ខយគាមិនិយា** (អាចកំណត់នូវធម៌ជាគ្រឿងអស់ទៅនៃទុក្ខដោយប្រពៃបាន) គឺ ដែលឲ្យដល់នូវការអស់ទៅនៃទុក្ខ ដែលអស់ទៅ ព្រោះការលះកិលេសទាំងឡាយបានដោយអំណាច **តទង្គប្បហាន** (លះបានដោយអង្គនោះៗ) ដោយបទទាំងអស់នេះឯង ព្រះមានព្រះភាគត្រាស់ចំពោះវិបស្សនាបញ្ញាប៉ុណ្ណោះ ដោយប្រការដូច្នេះ ព្រោះសេចក្ដីព្យាយាម រមែងមិនសម្រេចផលដល់បុគ្គលគ្មានបញ្ញា ។

ចប់អដ្ឋកថា អង្គសូត្រទី ៣

# អដ្ឋកថា សមយសូត្រទី ៤

## (សម័យដែលមិនគួរបំពេញសេចក្តីព្យាយាម)

*គប្បីជ្រាបវិនិច្ឆ័យក្នុង សមយសូត្រទី ៤ ដូចតទៅនេះ ៖*

*[៥៤] បទថា បធានាយ (ដើម្បីព្យាយាម) គឺ ដើម្បីប្រយោជន៍ដល់ការធ្វើសេចក្តីព្យាយាម ។ បទថា ន សុករំ ឧញ្ឆេន បគ្គហេន យាបេតុំ (បុគ្គលមិនងាយព្យាយាមស្វែងរកអាហារបានឡើយ) សេចក្តីថា ភិក្ខុទាំងឡាយមិនអាចនឹងញ៉ាំងជីវិតឲ្យរស់នៅបាន ដោយអំណាចការកាន់យកបាត្រស្វែងរកអាហារ ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ទាំងវគ្គ: និងវិវគ្គ: (គឺ ចំណែកចម្រើន និងចំណែកសាបសូន្យ) ។*

ចប់អដ្ឋកថា សមយសូត្រទី ៤

# អដ្ឋកថា មាតុបុត្តិកសូត្រទី ៥

## (អន្ទាក់មារ ៥ ប្រការ)

*គប្បីជ្រាបវិនិច្ឆ័យក្នុង មាតុបុត្តិកសូត្រទី ៥ ដូចតទៅនេះ ៖*

*[៥៥] បទថា **បរិយាទាយ តិដ្ឋតិ (រមែងគ្របសង្កត់)** សេចក្តីថា រមែងគ្របសង្កត់ គឺ ប្រកាន់យក បានដល់ ផ្សាយទៅហើយតាំងនៅ ។ បទថា **ឧគ្ឃាជិតា**[១] **(ហើមប៉ោង)** បានដល់ ប៉ោងឡើង ។*

*បទថា **អសិហត្ថេន (ដែលមានដាវក្នុងដៃ)** សេចក្តីថា សូម្បីអ្នកកាន់យកដាវមកកាត់សីសៈ ។ បទថា **បិសាចេន (ចរចាជាមួយបិសាច)** បានដល់ សូម្បីជាមួយយក្ខដែលមកបំណងនឹងចាប់ស៊ី ។ បទថា **អាសទេ (ប៉ះពាល់)** បានដល់ គប្បីចាប់ប៉ះ ។ បទថា **មញ្ជុនា (ដោយសម្តីដ៏ពីរោះ)** បានដល់ សម្តីទន់ភ្លន់ ។ បទថា **កាមោឃវូឡ្ហានំ (ជំនន់ គឺ កាមក្ដួចនាំទៅ)** បានដល់ ដែលឱឃៈ គឺ កាមនាំយកទៅ ។ បទថា **កាលំ គតំ ភវាភវំ (រមែងធ្វើនៅគតិ និងការកើតរឿយៗ)** បានដល់ គឺ រមែងចូលទៅកាន់កពតូច និងកពធំក្នុងសង្សារវដ្ត ។ ។ បទថា **បុរក្ខតា (រមែងទៅ)** គឺ ត្រាច់ទៅក្នុងកាលខាងមុខ ។ បទថា **យេ ច កាមេ បរិញ្ញាយ (ចំណែកជនពួក***

---

*(១) អដ្ឋកថា = ឧគ្ឃានិតា ។*

*ណាកំណត់ដឹងនូវកាមទាំងឡាយបាន)* សេចក្តីថា ជនពួកណាជាបណ្ឌិត កំណត់ដឹងកាមសុខ្យទាំងពីរយ៉ាង ដោយបរិញ្ញា ៣ ។ បទថា **ចរន្តិ អកុ-តោភយា** *(មិនមានភ័យអំពីទីណាឡើយ)* សេចក្តីថា ដែលឈ្មោះថា មានភ័យអំពីទីណាៗ មួយ មិនមាន មិនមានដល់ព្រះខីណាស្រពទាំងឡាយ ព្រោះដូច្នោះ ព្រះខីណាស្រពទាំងនោះ ទើបឈ្មោះថា ជាអ្នកមិនមានភ័យអំពីទីណាៗ ហើយត្រាច់ទៅ ។ បទថា **បារគតា** *(បានដល់ត្រើយ)* និព្វានលោកហៅថា ត្រើយ ។ អធិប្បាយថា ចូលដល់និព្វាននោះ គឺ ធ្វើឲ្យជាក់ច្បាស់ហើយតាំងនៅ ។ បទថា **អាសវក្ខយំ** *(ការអស់ទៅនៃអាសវៈ)* បានដល់ ព្រះអរហត្ត ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់វដ្តៈប៉ុណ្ណោះ ក្នុងគាថាទាំងឡាយត្រាស់ទាំងវដ្តៈ និងវិវដ្តៈ ។

ចប់អដ្ឋកថា មាតុបុត្តិកសូត្រទី ៥

# អដ្ឋកថា ឧបជ្ឈាយសូត្រទី ៦

## (បុគ្គលដែលនីវរណៈគ្របសង្កត់ចិត្តមិនបាន)

គប្បីជ្រាបវិនិច្ឆ័យក្នុង ឧបជ្ឈាយសូត្រទី ៦ ដូចតទៅនេះ ៖

[៥៦] បទថា **មធុរកជាតោ** (មានសភាពធ្ងន់) បានដល់ មានសេចក្តីធ្ងន់កើតឡើង ។ បទថា **ទិសា ច មេ ន បក្ខាយន្តិ** (ទាំងទិសក៏មិនប្រាកដដល់ខ្ញុំ) សេចក្តីថា ភិក្ខុពោលថា ទិសធំ ៤ និងទិសតូច ៤ មិនប្រាកដដល់ខ្ញុំ ។ បទថា **ធម្មា ច មំ នប្បដិភន្តិ** (ធម៌ទាំងឡាយ ក៏មិនជាក់ច្បាស់ដល់ខ្ញុំ) សេចក្តីថា សូម្បីធម៌ គឺ សមថៈ និងវិបស្សនា ក៏មិនប្រាកដដល់ខ្ញុំ ។ បទថា **អនភិរតោ ច ព្រហ្មចរិយំ ចរាមិ** (ខ្ញុំប្រព្រឹត្តព្រហ្មចរិយៈទាំងសេចក្តីអផ្សុក) សេចក្តីថា ខ្ញុំជាអ្នកអផ្សុកហើយនៅប្រព្រឹត្តព្រហ្មចរិយៈ ។

បទថា **យេន ភគវា តេនុបសង្កមិ** (ចូលទៅគាល់ព្រះមានព្រះភាគហើយអង្គុយក្នុងទីដ៏សមគួរ) សេចក្តីថា ឧបជ្ឈាយ៍ស្តាប់ពាក្យទូន្មានរបស់ភិក្ខុនោះហើយ គិតថា ភិក្ខុនេះជាបុគ្គលឧទ្ទិសចំពោះព្រះពុទ្ធ គួរនឹងណែនាំបាន ទើបចូលទៅគាល់ ក្រាបទូលហេតុការណ៍នោះដល់ព្រះមានព្រះភាគ ។ បទថា **អវិបស្សកស្ស កុសលានំ ធម្មានំ** (មិនពិចារណាភាវនានូវពួកធម៌ជាកុសល) សេចក្តីថា អ្នកមិនឃើញនូវធម៌ដែលជាកុសល គឺ មិនស្វែង

*រក មិនរិះរកនៅធម៌ដែលជាកុសល ។ បទថា ពោធិបក្ខិកានំ (ជាចំណែកនៃពោធិញ្ញាណ) បានដល់ ពោធិបក្ខិយធម៌ ៣៧ ប្រការ មានសតិបដ្ឋាន ៤ ជាដើម ។*

ចប់អដ្ឋកថា ឧបឌ្ឍាយសូត្រទី ៦

# អដ្ឋកថា ឋានសូត្រទី ៧

## (ឋានៈដែលគួរពិចារណារឿយៗ ៥ ប្រការ)

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឋានៈសូត្រទី ៧ ដូចតទៅនេះ ៖*

[៥៧] *បទថា* ***ជរាធម្មោម្ហិ (មានជរាជាធម្មតា)*** *បានដល់ យើងជាអ្នកមានសេចក្ដីចាស់ជាធម្មតា ។ បទថា* ***ជរំ អនតីតោ (មិនកន្លងជរាទៅបានឡើយ)*** *បានដល់ យើងមិនកន្លងផុតសេចក្ដីចាស់ទៅបានឡើយ គឺ រមែងត្រាច់ទៅក្នុងសភាពចាស់ទុំះឯង ។ បទថា* ***កម្មស្សកោម្ហិ (មានកម្មជារបស់ខ្លួន)*** *ជាដើម គប្បីជ្រាបសេចក្ដីអធិប្បាយដូចតទៅនេះ កម្មជារបស់យើង គឺ ជារបស់មានក្នុងខ្លួន ព្រោះដូច្នោះ ទើបឈ្មោះថា មានកម្មជារបស់ខ្លួន ។ បទថា* ***កម្មទាយាទោ (មានកម្មជាមត៌ក)*** *បានដល់ យើងជាទាយាទរបស់កម្ម អធិប្បាយថា កម្មជាមត៌ក គឺ ជាសម្បត្តិរបស់យើង កម្មជាកំណើត គឺ ជាហេតុនៃការកើតរបស់យើង ។ ព្រោះដូច្នោះ ទើបឈ្មោះថា* ***កម្មយោនិ (មានកម្មជាកំណើត)*** *។ មានកម្មជារបស់យើង ព្រោះហេតុនោះ ទើបឈ្មោះថា* ***កម្មពន្ធុ (មានកម្មជាផៅពង្ស)*** *។ បទថា* ***កម្មប្បដិសរណោ (មានកម្មជាទីរលឹក)*** *អធិប្បាយថា មានកម្មជាញាតិ មានកម្មជាទីអាស្រ័យ និងមានកម្មជាទីពឹងរបស់យើង ព្រោះដូច្នោះ ទើបឈ្មោះថា មានកម្មជាជាទីរលឹក ។*

បទថា តស្ស ទាយាទោ ភវិស្សាមិ (អាត្មាអញនឹងទទួលនូវផលកម្មនោះ) បានដល់ យើងជាទាយាទរបស់កម្មនោះ អធិប្បាយថា យើងនឹងជាអ្នកទទួលផលនៃកម្មនោះ ។

បទថា យោពូនមគ្គោ (ពួកសត្វតែងមានសេចក្តីស្រវឹងក្នុងវ័យដ៏ចម្រើន) បានដល់ សេចក្តីស្រវឹងកើតឡើង ប្រាថ្នាភាពជាកំលោះក្រមុំ ។ សូម្បីក្នុងបទទាំងឡាយដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា មគ្គោ សញ្ជាយតិ (លោកុត្តរមគ្គក៏កើតឡើងព្រម) បានដល់ លោកុត្តរមគ្គរមែងកើតឡើងព្រម ។ បទថា សំយោជនានិ បហីយន្តិ (សញ្ញោជនៈទាំងឡាយក៏រមែងសាបសូន្យទៅ) បានដល់ រមែងលះសញ្ញោជនៈ ១០ យ៉ាង ដោយប្រការទាំងពួង ។ បទថា អនុសយា ព្យន្តី ហោន្តិ (អនុសយកិលេសទាំងឡាយក៏វិនាសទៅ) សេចក្តីថា អនុស័យ ៧ ប្រការ គឺ ដល់ទីបំផុតហើយ ដែលមានផ្លូវកាត់ផ្តាច់ហើយ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់វិបស្សនាក្នុងឋានៈទាំង ៥ ក្នុងខាងក្រោយដោយប្រការដូច្នេះ ទ្រង់ត្រាស់លោកុត្តរមគ្គ ក្នុងឋានៈទាំង ៥ ប៉ុណ្ណោះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សរុបគាថាទាំងឡាយ ទើបត្រាស់ថា ព្យាធិធម្មា (មានព្យាធិជាធម្មតា) ជាដើម ។ បណ្តាបទទាំងនោះ

បណ្ដាបទទាំងនោះ បទថា **ញត្វា ធម្មំ និរូបធឹ** (**ការដឹងនូវធម៌ដែលប្រាសចាកឧបធិ**) បានដល់ ដឹងធម៌ គឺ ព្រះអរហត្តដែលប្រាសចាកឧបធិហើយ ។ បទថា **សព្វេ មទេ អភិភោស្មិ** (**គ្របសង្កត់នូវសេចក្ដីស្រវឹងទាំងពួង**) សេចក្ដីថា តថាគតគ្របសង្កត់សេចក្ដីស្រវឹងសូម្បីទាំង ៣ យ៉ាងបានទាំងអស់ អធិប្បាយថា តថាគតឈានកន្លងហើយ ស្ថិតនៅ ។ បទថា **នេក្ខម្មំ ទដ្ឋុ ខេមតោ** (**បានឃើញបព្វជ្ជាថាជាការក្សេម**) បានដល់ ឃើញការបព្វជ្ជាដោយភាពជារបស់ក្សេម ។ បទថា **តស្ស មេ អហុ ឧស្សាហោ និព្វានំ អភិបស្សតោ** (**សេចក្ដីព្យាយាមក៏កើតមានដល់តថាគត**) សេចក្ដីថា សេចក្ដីព្យាយាមបានមានហើយដល់តថាគតនោះ ដែលឃើញជាក់ច្បាស់នូវព្រះនិព្វាន ។ បទថា **អនិវត្តិ ភវិស្សាមិ** (**តថាគតមិនបានត្រឡប់វិញឡើយ**) សេចក្ដីថា តថាគតនឹងជាបុគ្គលមិនត្រឡប់ទៅពីភេទបព្វជ្ជា និងមិនត្រឡប់ពីការប្រព្រឹត្តព្រហ្មចរិយៈឡើយ និងមិនត្រឡប់ចេញពីព្រះសព្វញ្ញុតញ្ញាណ ។ បទថា **ព្រហ្មចរិយបរាយនោ** (**តថាគតនឹងជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌តទៅ**) គឺ ជាអ្នកមានមគ្គព្រហ្មចរិយៈទៅខាងមុខ ។ ដោយបទនេះ ព្រះមានព្រះភាគត្រាស់ដល់មគ្គមានអង្គ ៨ ដែលជាលោកុត្តរៈទុក ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា ឋានសូត្រទី ៧

---

ឋានៈ ៥ ប្រការ = ចាស់ ១, ឈឺ ១, ស្លាប់ ១, ព្រាត់ពីវត្ថុជាទីស្រឡាញ់ ១, កម្មជារបស់ខ្លួន ១។

# អដ្ឋកថា កុមារលិច្ឆវីសូត្រទី ៨

## (ធម៌ដែលឲ្យនូវសេចក្ដីចម្រើនតែម្យ៉ាង)

គប្បីជ្រាបវិនិច្ឆ័យក្នុង កុមារលិច្ឆវីសូត្រទី ៨ ដូចតទៅនេះ ៖

[៥៨] បទថា **សជ្ជានិ ធនូនិ (ធ្នូដែលខ្វនដំឡើងហើយ)** បានដល់ កាន់យកធ្នូដែលដំឡើងហើយ ។ បទថា **ភវិស្សន្តិ វជ្ជី (ពួកស្ដេចវជ្ជីនឹងចម្រើន)** បានដល់ ពួកស្ដេចវជ្ជីនឹងចម្រើន ។ បទថា **អបាជុកា (រឹងរូស)** បានដល់ អាស្រ័យសេចក្ដីមិនចម្រើន ជាអ្នករឹងរូស ព្រោះមានះ ។ បទថា **បច្ឆាលិយំ ខិបន្តិ (ធ្លាប់តែកាចអាក្រក់)** បានដល់ ដើរទៅពីខាងក្រោយហើយទាត់ជាក់ ។ ក្នុងបទទាំងឡាយ មានបទថា **រដ្ឋិកស្ស (ជាអ្នកគ្រប់គ្រងរដ្ឋ)** បានដល់ ព្រោះជាអ្នកបរិភោគតាមតំបន់ ។ បទថា **បេត្តនិកស្ស (នូវសម្បត្តិដែលបិតាឲ្យ)** បានដល់ ជាអ្នកបរិភោគទ្រព្យដែលបិតាទុកឲ្យ ។ បទថា **សេនាបតិកស្ស (ជាសេនាបតីនៃសេនា)** ព្រោះជាអ្នកគ្រប់គ្រងកងទ័ព ។ បទថា **គាមគ្គាមិកស្ស (ជាម្ចាស់នៃស្រុក)** បានដល់ ជាអ្នកដឹកនាំពួកអ្នកស្រុកទាំងឡាយ អធិប្បាយថា ជាអ្នកគ្រប់គ្រងពួកអ្នកស្រុក ។ បទថា **បូគគ្គាមណិកស្ស (ទោះជាធំជាងពួក)** បានដល់ ជាប្រធាននៃពួកគណៈ ។ បទថា **កុលេសុ (ក្នុងត្រកូល)** បានដល់ ក្នុងត្រកូលនោះៗ ។

បទថា បច្ចេកាធិបច្ចំ ការេន្តិ (ធ្វើនូវភាពនៃខ្លួនជាធំដោយឡែក) បានដល់ គឺ ជាអ្នកគ្រប់គ្រងតំណាងជាធំក្នុងស្រុកតែមួយគត់ ។

បទថា កល្យាណេន មនសា អនុកម្បន្តិ (រមែងអនុគ្រោះកុលបុត្តនោះ ដោយចិត្តដ៏ល្អ) បានដល់ អ្នកធ្វើកិច្ចដែលកើតឡើងហើយ ។ បទថា ខេត្តកម្មន្តសាមន្តសព្យោហារេ (បូជានូវពួកជនជិតខាងស្រែនឹងការងាររបស់ខ្លួន) បានដល់ ជនជាម្ចាស់របស់ស្រែជាប់នឹងស្រែរបស់ខ្លួន និងធ្វើការងាររបស់ខ្លួន និងក្អាក់ងារវាស់ដី ដែលកាន់យកខ្សែ និងឈើវាស់ផ្ទៃដី ។ បទថា ពលិប្បដិគ្គាហិកា ទេវតា (ពួកទេវតាដែលជាអ្នកទទួលគ្រឿងបូជា) បានដល់ អារក្ខទេវតាដែលជឿតាមគ្នាមក តាមប្រពៃណីរបស់ត្រកូល ។ បទថា តំ សក្ករោតិ (បានធ្វើសក្ការៈ) បានដល់ រមែងធ្វើសក្ការៈដល់ទេវតាទាំងនោះ ដោយបបរ និងបាយដ៏ល្អ ។

បទថា កិច្ចករោ (ធ្វើការងារ) បានដល់ អ្នកធ្វើកិច្ចដែលកើតឡើងហើយ ។ បទថា យេ ចស្ស អនុជីវិនោ (ជាមួយជនដែលចូលមកជ្រកអាស្រ័យចិញ្ចឹមជីវិត) បានដល់ ជនដែលចូលទៅអាស្រ័យកុលបុត្រនោះចិញ្ចឹមជីវិត ។ បទថា ឧភិន្នញ្ចេវ អត្ថាយ (កាលប្រតិបត្តិជាប្រយោជន៍ដល់ជនទាំង ២ ពួក) សេចក្តីថា រមែងបដិបត្តិដើម្បីប្រយោជន៍ដល់ជនទាំង

២ ពួក ។ បទថា **បុព្វេបេតានំ** (ទៅកាន់បរលោក) បានដល់ អ្នកដែលទៅកាន់បរលោកហើយ ។ បទថា **ទិដ្ឋេ ធម្មេ ច ជីវិតំ** (ជាបណ្ឌិតគ្រប់គ្រងផ្ទះប្រកបដោយធម៌) បានដល់ អ្នកមានជីវិតរស់នៅក្នុងបច្ចុប្បន្ន ។ ព្រះ-មានព្រះភាគទ្រង់សម្តែងញាតិទាំងឡាយក្នុងអតីត និងបច្ចុប្បន្ន សូម្បីដោយបទទាំងពីរនេះ ដោយប្រការដូច្នេះ ។ បទថា **បីតិសញ្ជននោ**[១] (ញុំាងសេចក្តីរីករាយឲ្យកើតឡើង) ។ បទថា **ឃរមាវសំ** (អ្នកនៅគ្រប់គ្រងផ្ទះ) បានដល់ អ្នកនៅគ្រប់គ្រងផ្ទះប្រកបដោយធម៌ ។ បទថា **បុជ្ជោ ហោតិ បសំសិយោ** (ជាបុគ្គលគួរបូជា គួរសរសើរ) បានដល់ រមែងជាអ្នកដែលគេគប្បីបូជា និងគប្បីសរសើរ ។

ចប់អដ្ឋកថា កុមារលិច្ឆវីសូត្រទី ៨

---

(១) បិដក = វិត្តិសញ្ជននោ ។

# អដ្ឋកថា បឋមទុល្លភសូត្រទី ៩

## *(ធម៌រកបានលំបាកសម្រាប់អ្នកបួសចាស់)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមទុល្លភសូត្រទី ៩ ដូចតទៅនេះ ៖*

*[៥៩] បទថា **និបុណោ** (មានប្រាជ្ញាល្អិតល្អ) បានដល់ ជាអ្នកមានប្រាជ្ញាល្អិតល្អ គឺ អ្នកដឹងហេតុការណ៍ដ៏ល្អិតសុខុម ។ បទថា **អាកប្បសម្បន្នោ** (ជាអ្នកបរិបូណ៌ដោយមារយាទល្អ) បានដល់ ជាអ្នកដល់ព្រមដោយមារយាទរបស់សមណៈ ។*

ចប់អដ្ឋកថា បឋមទុល្លភសូត្រទី ៩

# អដ្ឋកថា ទុតិយទុល្លភសូត្រទី ១០

## (ធម៌រកបានលំបាកសម្រាប់អ្នកបួសចាស់)

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយទុល្លភសូត្រទី ១០ ដូចតទៅនេះ ៖*

*[៦០] បទថា **បទក្ខិណគ្គាហី** (ជាអ្នកទទួលយកឱវាទដោយល្អ) (**ខាងស្តាំ**) បានដល់ អ្នកទទួលឱវាទដែលលោកឲ្យដោយខាងស្តាំ (ដោយសេចក្តីគោរព) ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានសេចក្តីងាយយល់ហើយ ។*

ចប់អដ្ឋកថា ទុតិយទុល្លភសូត្រទី ១០

## ចប់និវរណវគ្គវណ្ណនាទី ១

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៩ សូត្រ

# សញ្ញាវគ្គវណ្ណនាទី ២

## អដ្ឋកថា បឋមសញ្ញាវរៈសូត្រទី ១

*(សញ្ញាដែលមានផលច្រើន ៥ ប្រការ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសញ្ញាវរៈសូត្រទី ១ ដូចតទៅនេះ ៖*

[៦១] *បទថា* ***មហប្ផលា*** *(មានផលច្រើន) គឺ មានផលច្រើនដោយផលដែលជាវិបាក ។ បទថា* ***មហានិសំសា*** *(មានអានិសង្សច្រើន) បានដល់ មានអានិសង្សច្រើនដែលជាវិបាក ។ បទថា* ***អមតោគធា*** *(មាននិព្វានជាទីតាំង) បានដល់ មាននិព្វានជាទីពឹង ។ បទថា* ***សព្វលោកេ អនភិរតសញ្ញា*** *(សេចក្តីសំគាល់ថាមិនគួរត្រេកត្រអាលក្នុងលោកទាំងពួង) បានដល់ សញ្ញាកើតឡើងដល់បុគ្គលដែលធុញទ្រាន់ក្នុងលោក ដែលជាទីអាស្រ័យនៃធាតុទាំង ៣ ។*

ចប់អដ្ឋកថា បឋមសញ្ញាសូត្រទី ១

# អដ្ឋកថា ទុតិយសញ្ញាវរៈសូត្រទី ១

*(សញ្ញាមានផលច្រើន ៥ ប្រការ)*

[៦២] *សូត្រទី ២ នេះ មានសេចក្តីងាយយល់ហើយ ។*

ចប់អដ្ឋកថា ទុតិយសញ្ញាសូត្រទី ២

# អដ្ឋកថា បឋមវឌ្ឍិសូត្រទី ៣

*(ធម៌ជាហេតុចម្រើន ៥ ប្រការ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមវឌ្ឍិសូត្រទី ៣ ដូចតទៅនេះ ៖*

[៦៣] *បទថា វរាទាយី (កាន់យកនូវប្រយោជន៍ដែលមានខ្លឹម) គឺជាអ្នកកាន់យកនូវសារៈប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ។ ពាក្យដ៏សេសក្នុងសូត្រនេះ មានសេចក្ដីងាយយល់ហើយ ។*

ចប់អដ្ឋកថា បឋមវឌ្ឍិសូត្រទី ៣

# អដ្ឋកថា ទុតិយវឌ្ឍិសូត្រទី ៤

## (ធម៌ជាហេតុចម្រើន ៥ ប្រការ)

គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយវឌ្ឍិសូត្រទី ៤ ដូចតទៅនេះ ៖

[៦៤] ក្នុងសូត្រនេះ មានសេចក្ដីងាយហើយ ។

ចប់អដ្ឋកថា ទុតិយវឌ្ឍិសូត្រទី ៤

# អដ្ឋកថា សាកច្ឆសូត្រទី ៥

*(គុណសម្បត្តិអ្នកគួរសន្ទនា ៥ ប្រការ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សាកច្ឆសូត្រទី ៥ ដូចតទៅនេះ ៖*

[៦៥] *បទថា* ***អលំសាកច្ឆោ*** *(គួរដល់ការសាកសួរ) បានដល់ ជាអ្នកដែលគួរសន្ទនាផង ។ បទថា* ***អាគតំ បញ្ហំ*** *(នូវប្រស្នាដែលមកហើយ) គឺ បញ្ហាដែលត្រូវសួរហើយ ។ បទថា* ***ព្យាកត្តា ហោតិ*** *(ទាំងបានព្យាករណ៍នូវប្រស្នាដែលមកហើយ) គឺ ជាអ្នកដោះស្រាយបញ្ហាបាន ។*

ចប់អដ្ឋកថា សាកច្ឆាសូត្រទី ៥

# អដ្ឋកថា សាជីវសូត្រទី ៦

*(គុណសម្បត្តិរបស់ភិក្ខុដែលគួរនៅរួមគ្នា ៥ ប្រការ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សាជីវសូត្រទី ៦ ដូចតទៅនេះ ៖*

[៦៦] *បទថា* ***អលំសាជីវោ*** *(ទើបគួរដល់សាជីវៈ) បានដល់ ជាអ្នកគួរដល់ការមានអាជីវៈរួមគ្នា ។ បទថា* ***សាជីវៈ*** *បានដល់ ការសួរបញ្ហា និងការដោះស្រាយបញ្ហា ។ ពិតណាស់ សព្រហ្មចារីសូម្បីទាំងអស់ រមែងចិញ្ចឹមជីវិតរួមគ្នា ដោះស្រាយបញ្ហាជីវិតរួមគ្នា ព្រោះហេតុនោះ ការសួរ និងការឆ្លើយបញ្ហានោះ ព្រះមានព្រះភាគត្រាស់ថា* ***សាជីវៈ*** *ព្រោះមានការចិញ្ចឹមជីវិតរួមគ្នា ។ បទថា* ***កតំ បញ្ហំ*** *(បញ្ហាដែលតាំងឡើង) គឺ សួរបញ្ហាដែលតាំងឡើងហើយ ។*

ចប់អដ្ឋកថា សាជីវសូត្រទី ៦

# អដ្ឋកថា បឋមឥទ្ធិប្បាទសូត្រទី ៧

*(ធម៌ដែលឲ្យផលជាព្រះអរិយបុគ្គល)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឥទ្ធិប្បាទសូត្រទី ៧ ដូចតទៅនេះ ៖*

[៦៧] *បទថា* **ឧស្សោឡ្ហី** *(ប្រកបដោយវិរិយៈ) បានដល់ សេចក្តីព្យាយាមមានប្រមាណក្រៃលែង ។*

ចប់អដ្ឋកថា បឋមឥទ្ធិប្បាទសូត្រទី ៧

# អដ្ឋកថា ទុតិយឥទ្ធិប្បាទសូត្រទី ៨

*(ធម៌ដែលឲ្យផលជាព្រះអរិយបុគ្គល)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយឥទ្ធិប្បាទសូត្រទី ៨ ដូចតទៅនេះ ៖*

[៦៨] *ព្រះដ៏មានព្រះភាគត្រាស់* ***អាគមនិបាត (ផលសម្រេចនៃការបដិបត្តិ)*** *របស់ព្រះអង្គ ដែលព្រះអង្គត្រាស់ដឹងហើយក្រោមដើមពោធិព្រឹក្ស ទើបត្រាស់អភិញ្ញា ៦ របស់ព្រះអង្គទុំះឯងទុកក្នុងទីបំផុតតទៅ ដោយប្រការដូច្នេះ ។*

ចប់អដ្ឋកថា សញ្ញាវរគ្គទី ៨

# អដ្ឋកថា និព្វិទាសូត្រទី ៩

*(ធម៌ដែលឲ្យផលសម្រេចព្រះនិព្វាន)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង និព្វិទាសូត្រទី ៩ ដូចតទៅនេះ ៖*

[៦៩] *ព្រះដ៏មានព្រះភាគត្រាស់វិបស្សនាទុក ។ បទដ៏សេសក្នុងទីទាំងពួង មានសេចក្តីងាយយល់ទាំងអស់នុ៎ះឯង ។*

ចប់អដ្ឋកថា និព្វិទាសូត្រទី ៩

# អដ្ឋកថា អាសវក្ខយសូត្រទី ១០

*(ធម៌ដែលឲ្យផលឲ្យអស់អាសវៈ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាសវក្ខយសូត្រទី ១០ ដូចតទៅនេះ ៖*

[៧០] *ព្រះដ៏មានព្រះភាគត្រាស់វិបស្សនាទុក ។ បទដ៏សេសក្នុងទីទាំងពួង មានសេចក្ដីងាយយល់ទាំងអស់នុ៎ះឯង ។*

ចប់អដ្ឋកថា អាសវក្ខយសូត្រទី ១០

## ចប់សញ្ញាវគ្គវណ្ណនាទី ២

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៨ សូត្រ

# យោធាជីវវគ្គវណ្ណនាទី ៣

## អដ្ឋកថា បឋមចេតោវិមុត្តិសូត្រទី ១

*(ធម៌ដែលឲ្យផលសម្រេចវិមុត្តិ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមចេតោវិមុត្តិសូត្រទី ១ ដូចតទៅនេះ ៖*

[៧១] *បទថា* ***យតោ ខោ ភិក្ខវេ*** *(ម្នាលភិក្ខុទាំងឡាយ កាលណា) ឥឡូវនេះ ព្រះដ៏មានព្រះភាគទ្រង់ប្រារព្ធ ដើម្បីទ្រង់សរសើរភិក្ខុដែលចម្រើនវិបស្សនា ហើយសម្រេចព្រះអរហត្ត តាមន័យដែលត្រាស់ទុកហើយក្នុងខាងក្រោយ ។ បណ្តាបទទាំងនោះ បទថា* ***យតោ ខោ*** *(កាលណា) បានដល់ កាលណាភិក្ខុមានចេតោវិមុត្តិ ។ បទថា* ***ឧក្ខិត្តបលិឃោ*** *(លើកឡើងនូវជើងគុល គឺ អវិជ្ជា) បានដល់ លើកឡើងនូវជើងគុល គឺ អវិជ្ជាចេញហើយ ។ បទថា* ***សង្កិណ្ណបរិក្ខោ*** *( ជាអ្នកបំផ្លិចបំផ្លាញនូវគូគឺសង្សារវដ្ត) បានដល់ ឫសគល់ គឺ សង្សារវដ្ត ហើយធ្វើឲ្យសាបសូន្យទៅ ។ បទថា* ***និរគ្គឡោ*** *(បើកនូវសន្ទះទ្វារគឺនីវរណៈ) បានដល់ បើកនូវសន្ទះ គឺ តណ្ហាចេញហើយ ។ បទថា* ***បន្នទ្ធជោ បន្នភារោ*** *(ដាក់ចុះនូវទង់ គឺ ទម្លាក់ចោលនូវភារៈ) បានដល់ ត្រូវដាក់ចុះនូវទង់ គឺ មានះ និងភារៈ គឺ ខន្ធ អភិសង្ខារ*

និងកិលេស ដាក់ចុះហើយ ។ បទថា **វិសំយុត្តោ** (ប្រាសចាកវដ្ដៈ) បានដល់ រួចផុតពីវដ្ដៈ ។ ពាក្យដ៏សេសគប្បីជ្រាបតាមន័យនៃព្រះបាលីនុ៎ះឯង ។ ព្រះមានព្រះភាគទ្រង់សម្ដែងវេលារបស់ព្រះខីណាស្រព អ្នកធ្វើកិលេសឲ្យអស់ទៅដោយមគ្គហើយ ទៅកាន់ទីដេកដ៏ល្អ គឺ និរោធ ចូលផលសមាបត្តិមានព្រះនិព្វានជាអារម្មណ៍ ដោយព្រះតម្រាស់មានប្រមាណប៉ុណ្ណេះ ។ ប្រៀបដូចនគរ ២ នគរមួយ គឺ ចោរ នគរមួយ គឺ មិនមានចោរ គ្រានោះអ្នកចម្បាំងធំមួយគិតថា ដរាបណាចោរនគរតាំងនៅ ដរាបនោះនគរមិនមានចោរ ក៏រមែងមិនផុតពីអន្តរាយឡើយ ចាំបាច់ត្រូវធ្វើនគរចោរមិនឲ្យជានគរហើយទើបស្លៀកពាក់អាវក្រោះ ហើយកាន់យកអាវុធមុខ ២ ចូលទៅកម្ចាត់ចោរនគរ យកអាវុធកាត់សសរដែលគេតាំងទុកក្នុងទីជិតទ្វារនគរ ហើយទម្លាយទ្វារ ព្រមទាំងក្រប ហើយបំផ្លាញកំពែងទាំងឡាយ រុះរើបន្ទាយ ដាក់ទង់ចុះដែលគេលើកឡើង ដើម្បីប្រកាសភាពល្អនៃនគរ យកភ្លើងដុតបំផ្លាញនគរចោរ ហើយចូលទៅកាន់នគរមិនមានចោរ ឡើងកាន់ប្រាសាទ មានពួកញាតិហែហម បរិភោគអាហារដែលឆ្ងាញ់ៗ សេចក្ដីឧបមានោះ យ៉ាងណា ការឧបមេយ្យក៏យ៉ាងនោះដែរ សក្កាយៈ ដូចនគរចោរ ព្រះនិព្វានដូចនគរមិនមានចោរ ព្រះយោគាវចរដូចជាអ្នកចម្បាំងធំ លោកមានការគិតយ៉ាង

នោះថា ជរាបណាសក្កាយៈនូវប្រព្រឹត្តទៅ ជរាបនោះ ក៏មិនរួចផុតពីកម្ម-
ករណ៍ ៣២ រោគ ៩៨ និងមហាភ័យ ២៥ លោកទើបដូចជាអ្នកចម្បាំងធំ
ពាក់អាវក្រោះ គឺ សីល កាន់ព្រះខាន់ គឺ បញ្ញា យកអរហត្តមគ្គកាត់សសរ
ខឿន គឺ តណ្ហា ដូចយកព្រះខាន់កាត់សសរខឿន ដកគន្លឹះ គឺ សញ្ញោជនៈ
ខាងក្រោម ៥ ដូចអ្នកចម្បាំងរុះរើទ្វារនគរ ព្រមទាំងក្រប លើកស្នៀត
គន្លឹះ គឺ អវិជ្ជា ដូចអ្នកចម្បាំងលើកស្នៀតគន្លឹះ ទម្លាយអភិសង្ខារ គឺ កម្ម
ឬសគូ គឺ ជាតិសង្សារ ដូចអ្នកទម្លាយកំពែងបន្ទាយ ដាក់ទង់ គឺ មានះ
ដូចអ្នកចម្បាំងដាក់ទង់ដែលគេលើកឡើងឲ្យនគរចោរដ៏ស្រស់ល្អចេញ ផុត
នគរចោរ គឺ សក្កាយៈ ហើយចូលកាន់នគរ គឺ កិលេសបរិនិព្វាន ជាទី
រលត់កិលេស សោយសុខកើតពីផលសមាបត្តិ ដែលមានអមតនិព្វានជា
អារម្មណ៍ ញុំាងវេលាឲ្យកន្លងទៅ ដូចអ្នកចម្បាំងចូលទៅក្នុងនគរដ៏ក្សេម
ឡើងកាន់ប្រាសាទជាន់លើ បរិភោគអាហារដែលឆ្ងាញ់ ដូច្នោះ ។

ចប់អដ្ឋកថា បឋមចេតោវិមុត្តិសូត្រទី ១

# អដ្ឋកថា ទុតិយចេតោវិមុត្តិសូត្រទី ២

*(ធម៌មានវិមុត្តិជាផល)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយចេតោវិមុត្តិសូត្រទី ២ ដូចតទៅនេះ ៖*

*[៧២] បទថា **អនិច្ចសញ្ញា** (ជារបស់មិនទៀង) បានដល់ សញ្ញាដែលកើតឡើងថា បញ្ចក្ខន្ធមិនទៀងដោយអាការ គឺ មានហើយ ក៏ត្រឡប់ជាមិនមាន ។ បទថា **អនិច្ចេ ទុក្ខសញ្ញា** (សេចក្តីសំគាល់ថាជាទុក្ខ ក្នុងរបស់ដែលមិនទៀង) បានដល់ សញ្ញាដែលកើតឡើងថា វត្ថុណាមិនទៀង វត្ថុនោះក៏ជាទុក្ខ ដោយអាការ គឺ បៀតបៀន ។ បទថា **ទុក្ខេ អនត្តសញ្ញា** (សេចក្តីសំគាល់ថាមិនមែនខ្លួន ក្នុងរបស់ដែលជាទុក្ខ) បានដល់ សញ្ញាដែលកើតឡើងថា វត្ថុណាជាទុក្ខ វត្ថុនោះក៏ជាអនត្តា ដោយអាការ គឺ មិននៅក្នុងអំណាច ។ ពាក្យដ៏សេស ក៏មានន័យដូចដែលបានពោលទុកហើយក្នុងខាងក្រោយនុ៎ះឯង តែក្នុងព្រះសូត្រសូម្បីទាំងពីរនេះ ក៏ត្រាស់ដល់ផលនៃវិបស្សនាផងដែរ ។*

ចប់អដ្ឋកថា ទុតិយចេតោវិមុត្តិសូត្រទី ២

# អដ្ឋកថា បឋមធម្មវិហារិកសូត្រទី ៣

## (បុគ្គលអ្នករស់នៅក្នុងធម៌)

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមធម្មវិហារិកសូត្រទី ៣ ដូចតទៅនេះ ៖

[៧៣] បទថា **ទិវសំ អតិនាមេតិ (ញ៉ាំងថ្ងៃឲ្យកន្លងទៅ)** បានដល់ ធ្វើពេលវេលាឲ្យកន្លងទៅមួយថ្ងៃ ។ បទថា **រិញ្ចតិ បដិសល្លានំ (លះបង់នូវការសម្ងំក្នុងទីស្ងាត់)** បានដល់ គឺ បេញចាកពួកគណៈនៅតែម្នាក់ឯង ។ បទថា **ទេសេតិ (សម្តែង)** បានដល់ ពោល គឺ ប្រកាស ។ បទថា **ធម្មប្បញ្ញត្តិយា (ដោយការបញ្ញត្តិនូវធម៌)** បានដល់ ព្រោះការសម្តែងធម៌ ។ បទថា **ធម្មំ បរិយាបុណាតិ (ជាអ្នកច្រើនដោយសេចក្តីត្រិះរិះនូវធម៌)** បានដល់ រៀនសូត្រ សិក្សា ពោលធម៌ គឺ សច្ចៈ ៤ ដោយនវង្គសត្ថុសាសន៍ (ពាក្យទូន្មានរបស់ព្រះសាស្តាប្រកបដោយអង្គ ៩) ។ បទថា **ន រិញ្ចតិ បដិសល្លានំ (មិនលះបង់ការនៅសម្ងំក្នុងទីស្ងាត់)** បានដល់ មិនលះបង់ការនៅម្នាក់ឯង ។ បទថា **អនុយុញ្ចតិ អជ្ឈត្តំ ចេតោសមថំ (ប្រកបរឿយៗ នូវធម៌ជាគ្រឿងរម្ងាប់ចិត្តខាងក្នុង)** បានដល់ ចូលទៅសេព ចូលទៅចម្រើនសមាធិខាងក្នុងខ្លួនឯង គឺ ប្រកបសេចក្តីខ្វល់ខ្វាយក្នុងសមថកម្មដ្ឋាន ។ បទថា **ហិតេសិនា (ជាអ្នកប្រាថ្នាប្រយោជន៍ដល់ត្រកូល)** បានដល់ ជាអ្នកស្វែងរក

ប្រយោជន៍ដើម្បីត្រកូល ។ បទថា **អនុកម្បកេន (ជាអ្នកអនុគ្រោះ)** បានដល់ បុគ្គលគួរឲ្យអាណិត ។ បទថា **អនុកម្បំ ឧបាទាយ (អាស្រ័យសេចក្តីអនុ-គ្រោះ)** បានដល់ កំណត់ សេចក្តីករុណាដោយចិត្ត អធិប្បាយថា អាស្រ័យ សេចក្តីអាណិតដោយចិត្តក៏មាន ។ បទថា **កតំ វោ តំ មយា (គួរដល់សាវក ទាំងឡាយ អំពើនោះ តថាគតក៏ធ្វើហើយដល់អ្នកទាំងឡាយ)** សេចក្តីថា តថាគតសម្តែងបុគ្គល ៥ ប្រភេទនេះ ក៏ធ្វើករណីយកិច្ចនោះដល់អ្នកទាំង ឡាយហើយ ។ ពិតហើយ ព្រះសាស្តាមានការអាណិត ក៏មានកិច្ចនាទី គឺ ការសម្តែងធម៌ដែលមិនវិបរិត ត្រឹមតែប៉ុណ្ណេះឯង ។ តអំពីនេះទៅ ឈ្មោះ ថា ការបដិបត្តិ ជាតួនាទីរបស់សាវកទាំងឡាយ ។ ព្រោះហេតុនោះ ព្រះ-មានព្រះភាគទើបត្រាស់ថា ម្នាលភិក្ខុ នេះគល់ឈើ ។ល។ ជាអនុសាសនី ពាក្យទូន្មានរបស់តថាគត ដើម្បីប្រយោជន៍ដល់អ្នកទាំងឡាយ ។ ក៏ក្នុង ព្រះតម្រាស់នោះ ទ្រង់សម្តែងសេនាសនៈ គឺ គល់ឈើ ដោយបទថា **រុក្ខមូលានិ (គល់ឈើ)** ។ ទ្រង់សម្តែងទីស្ងាត់ចាកពួកគណៈ ដោយបទថា **សុញ្ញាគារានិ (ផ្ទះស្ងាត់)** មួយវិញទៀត ទ្រង់ប្រាប់សេនាសនៈដែលសមគួរ ដល់ការបំពេញសេចក្តីព្យាយាម សូម្បីដោយបទទាំងពីរ ឈ្មោះថា ទ្រង់ ប្រគល់មត៌កឲ្យ ។

បទថា **ឈាយថ** (អ្នកទាំងឡាយចូរចម្រើននូវសមថៈ និងវិបស្សនា) បាន ដល់ អ្នកទាំងឡាយចូរសម្លឹងពិនិត្យអារម្មណ៍ ៣៨ ដោយ **អារម្មណូបនិ-ជ្ឈាន** (ការសម្លឹងពិចារណាអារម្មណ៍) និងការពិចារណាខន្ធ អាយតនៈជាអាទិ៍ថា ជារបស់មិនទៀងជាដើម ដោយលក្ខណូបនិជ្ឈាន (ការសម្លឹងពិចា-រណាលក្ខណៈ) អធិប្បាយថា ចូរចម្រើនសមថៈ និងវិបស្សនា ។ បទថា **មា បមាទត្ថ** (អ្នកទាំងឡាយចូរកុំប្រមាទ) បានដល់ កុំប្រមាទឡើយ ។ បទថា **មា បច្ឆា វិប្បដិសារិនោ អហុវត្ថ** (អ្នកទាំងឡាយចូរកុំមានសេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយឡើយ) សេចក្តីថា កាលទ្រង់សម្តែងសេចក្តីប្រការនេះថា ក៏សាវកពួកណា វេលានៅជាកំលោះ វេលាមិនមានរោគ វេលាសម្បូរណ៍ដោយសេចក្តីសប្បាយ មានអាហារជាទីសប្បាយជាដើម កាលនៅចំពោះព្រះភក្ត្រព្រះសាស្តា លើកលែងតែការយកចិត្តទុកដាក់ដោយកាពឈ្លាសវៃ រវល់តែសប្បាយក្នុងការដេកលក់ឲ្យអាហារដល់សត្វសន្សើចទាំងថ្ងៃទាំងយប់ មកពីការប្រមាទអំពីមុន ខាងក្រោយ សាវកទាំងនោះវេលាចាស់ទ្រុឌទ្រោម មានរោគ ជិតនឹងស្លាប់ វេលាមានវិបត្តិ និងវេលាដែលព្រះសាស្តាបរិនិព្វានទៅហើយ កាលរំលឹកដល់ការប្រមាទមកអំពីមុននោះ និងកាលឃើញការធ្វើកិរិយា (ស្លាប់) សត្វដែលមានបដិសន្ធិជា

ភារៈ រមែងក្តៅក្រហាយចិត្ត ចំណែកអ្នកទាំងឡាយចូរកុំមានសភាពដូច្នោះឡើយ ។ ទើបត្រាស់ថា អ្នកទាំងឡាយ កុំជាអ្នកមានសេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយឡើយ ។ បទថា **អយំ វោ អម្ហាកំ អនុសាសនី** (នេះជាពាក្យប្រៀនប្រដៅរបស់តថាគតដល់អ្នកទាំងឡាយ) សេចក្តីថា វាចានេះពោលថា ពួកអ្នកចូរសម្លឹងពិនិត្យ ចូរកុំប្រមាទ នេះជាអនុសាសនី អធិប្បាយថា ជាឱវាទរបស់ព្រះតថាគតសម្រាប់អ្នកទាំងឡាយ ។

ចប់អដ្ឋកថា បឋមធម្មវិហារិកសូត្រទី ៣

# អដ្ឋកថា ទុតិយធម្មវិហារិកសូត្រទី ៤

## (បុគ្គលអ្នកនៅក្នុងធម៌)

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយធម្មវិហារិកសូត្រទី ៤ ដូចតទៅនេះ ៖*

*[៧៤] បទថា ឧត្តរឹ ចស្ស បញ្ញាយ អត្ថំ នប្បជានាតិ (តែភិក្ខុនោះ មិនដឹងច្បាស់នូវអត្ថដ៏លើសលុបរបស់ធម៌ដោយបញ្ញាឡើយ) សេចក្តីថា មិនដឹងសេចក្តីនៃធម៌នោះ ដែលក្រែងលេងជាងព្រះបរិយត្តិនោះ ដោយមគ្គបញ្ញាព្រមទាំងវិបស្សនា ។ អធិប្បាយថា មិនត្រាស់ដឹងអរិយសច្ចៈ ៤ ។ ក្នុងវារៈដ៏សេសក៏មានន័យនេះដូចគ្នា ។ ជន ៦ ពួក គឺ ភិក្ខុពហុស្សូត អ្នកបំពេញវិបស្សនាកម្មដ្ឋាន ព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី ព្រះខីណាស្រព គប្បីជ្រាបថា ជាធម្មវិហារី (អ្នកនៅក្នុងធម៌) ក្នុងព្រះសូត្រសូម្បីទាំងពីរនេះ ដោយប្រការដូច្នេះ ។*

ចប់អដ្ឋកថា ទុតិយធម្មវិហារិកសូត្រទី ៤

# អដ្ឋកថា បឋមយោធាជីវសូត្រទី ៥

## (អ្នករស់នៅដោយមានះជាទាហាន ៥ ជំពូក)

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមយោធាជីវសូត្រទី ៥ ដូចតទៅនេះ ៖

[៧៥] បទថា **យោធាជីវា (យោធាជីវៈ)** បានដល់ អ្នកអាស្រ័យការច្បាំងចិញ្ចឹមជីវិត ។ បទថា **រជគ្គំ (នូវផង់ធូលីដែលហុយឡើង)** បានដល់ ល្អងធូលីដែលហុយឡើងអំពីផែនដី ដែលបែកខ្ទាត់ខ្ទាយ ព្រោះការជាន់ដោយជើងរបស់ដំរី សេះជាដើម ។ បទថា ន **សន្ថម្ភតិ (មិនរឹងប៉ឹង)** បានដល់ មិនអាចឈរតតាំងឡើងបាន ។ បទថា **សហតិ រជគ្គំ (ចេះអត់ទ្រាំនូវផង់ធូលីដែលហុយឡើងបាន)** បានដល់ សូម្បីឃើញល្អងធូលី ក៏អត់ទ្រាំបាន ។ បទថា **ធជគ្គំ (ទង់ជ័យ)** បានដល់ កំពូលទង់ដែលគេលើកឡើងលើខ្នងដំរីសេះជាដើម និងលើរថទាំងឡាយ ។ បទថា **ឧស្សារណំ (ពួកពល)** បានដល់ សំឡេងគឹកកង ឃោកគ្រៀវរបស់ពួកពលដំរី សេះ រថ និងពួកទាហាន ។ បទថា **សម្បហារេ (ក្នុងការប្រយុទ្ធគ្នា)** បានដល់ ការប្រហារសូម្បីខ្នាតតូចៗ ដែលវាយចូលមកក៏ដោយ ។ បទថា **ហញ្ញតិ (រមែងខ្ទាច)** បានដល់ រមែងខ្ទាច ស្ទន់ស្មោ ខ្ទេចចិត្ត ។ បទថា **ព្យាបជ្ជតិ (ភាន់ភាំងស្រឡាំងកាំង)** បានដល់ វិបត្តិខុសប្រក្រតីទៅ ។

បទថា **សហតិ សម្បហារំ** (អត់ទ្រាំនូវការប្រយុទ្ធគ្នាបាន) បានដល់ សូម្បី ប៉ះទង្គិចគ្នា ២-៣ លើក ក៏អាចអត់ធន់បាន អាចអត់ទ្រាំបាន ។

បទថា **តមេវ សង្គាមសីសំ** (ជាប្រធានលើសង្គ្រាមនោះឯង) បានដល់ ទីតាំង ភូមិសាស្ត្រនោះឯង ។ បទថា **អជ្ឈាវសតិ** (តែងបាននូវការគ្រប់គ្រង) បានដល់ គ្រប់គ្រងប្រមាណ ៧ ថ្ងៃ ព្រោះហេតុអ្វី ។ ព្រោះដើម្បីឧបការៈ ទំនុកបម្រុងដល់អ្នកត្រូវបួសដោយសារអាវុធ ដើម្បីដឹងសេចក្តីពេញចិត្តនៃអ្នកបដិបត្តិតួនាទីមកហើយ និងបានជាគុណបំណាច់ និងបានសោយសុខក្នុងភាពជាធំ (ព្រោះបានជ័យជំនះ) ។

ព្រោះហេតុ ដែលព្រះសាស្តាទ្រង់មិនមានកិច្ចនាទី ដោយពួកអ្នកចម្បាំងទាំងឡាយ តែទ្រង់នាំសេចក្តីឧបមានេះមក ដើម្បីទ្រង់សម្តែងបុគ្គល ៥ ពួកនោះ ក្នុងព្រះសាសនានេះ ដូច្នោះ ឥឡូវនេះ កាលនឹងទ្រង់សម្តែងបុគ្គលទាំងនោះ ទើបត្រាស់ថា **ឯវមេវ ខោ** (ក៏យ៉ាងនោះដែរ) ជាដើម ។ ក្នុងបទនោះ បទថា **សំសីទតិ** (ក៏លិចចុះទៅ) បានដល់ ទន់ខ្សោយ ធ្លាក់នៅក្នុងមិច្ឆាវិតក្កៈ ។ បទថា **ន សក្កោតិ ព្រហ្មចរិយំ សន្តានេតុំ** (មិនអាចនឹងគ្រប់គ្រងព្រហ្មចរិយៈបានឡើយ) បានដល់ មិនអាចគ្រប់គ្រងព្រហ្មចរិយវាស (ការនូវប្រព្រឹត្តព្រហ្មចារ្យ) ទុកមិនឲ្យវិនាសទៅបាន ។ បទថា

សិក្ខាទុព្ពល្យំ អាវិកត្វា (ប្រកាសនូវភាពនៃខ្លួនមានកម្លាំងថយចាកសិក្ខា) បានដល់ ប្រកាសភាពទន់ខ្សោយកម្លាំងក្នុងសិក្ខា ។ ដោយបទថា កិមស្ស វជ្ជគ្គស្មឹ (អ្វីជាផង់ធូលីរបស់បុគ្គលនោះ) ត្រាស់សួរថា អ្វីឈ្មោះថា ជាផង់ធូលីរបស់បុគ្គលនោះ ។

បទថា អភិរូបំ (មានរូបល្អ) បានដល់ មានរូបស្រស់ល្អ ។ បទថា ទស្សនីយំ (គួររមិលមើល) បានដល់ គួរដល់ការសរសើរ ។ បទថា បាសាទិកា (គួរជ្រះថ្លា) បានដល់ នាំសេចក្តីជ្រះថ្លាមកឲ្យចិត្ត ដោយការឃើញប៉ុណ្ណោះ ។ បទថា បរមាយ (ល្អក្រៃពេក) បានដល់ មានរាងខ្ពស់ ។ បទថា វណ្ណបោក្ខរតាយ (ប្រកបដោយសម្បុរ) បានដល់ ដោយពណ៌សម្បុរនៃសរីរៈ និងដោយទ្រង់ទ្រាយនៃអវយវៈ ។ បទថា ឱហសតិ (ការញញឹម) បានដល់ រមែងញញឹម ។ បទថា ឧល្លបតិ (និយាយរក) បានដល់ ពោល ។ បទថា ឧជ្ជគ្ឃតិ (សើចក្អាកក្អាយ) បានដល់ ទះដៃសើច ។ បទថា ឧប្ប-ណ្ឌេតិ (ចំអកចំអន់លេង) បានដល់ ចំអកឡកឡឺយ ។ បទថា អភិនិសីទតិ (អង្គុយជិត) បានដល់ បង្អាប់ហើយអង្គុយជិតគ្នា ឬអង្គុយរួមជាមួយគ្នា ។ សូម្បីក្នុងបទទាំងពីរ ក៏ន័យនេះដូចគ្នា ។

បទថា អជ្ឈោត្ថរតិ (ដេកឱបរឹត) បានដល់ ផ្តួលខ្លួនឱបរឹត ។ បទ

*ថា វិនិវេឋេត្វា វិនិមោចេត្វា (ក៏រំលៀកខ្លួនចេញបាន ដោយខ្លួនចេញរួចបាន) បានដល់ ដោះ និងទាញដៃស្រីនោះចេញពីទីដែលចាប់ ។ ពាក្យដ៏សេសក្នុងព្រះសូត្រនេះ មានសេចក្ដីងាយទាំងអស់ហើយ ។ ក្នុងព្រះសូត្រនេះ ត្រាស់ទាំងវដ្ដៈ និងវិវដ្ដៈ ។*

ចប់អដ្ឋកថា បឋមយោធាជីវសូត្រទី ៥

# អដ្ឋកថា ទុតិយយោធាជីវសូត្រទី ៦

## (អ្នកចម្បាំង និងភិក្ខុ ៥ ពួក)

គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយយោធាជីវសូត្រទី ៥ ដូចតទៅនេះ ៖

[៧៦] បទថា **អសិចម្មំ គហេត្វា** (កាន់ដាវនឹងខែល) បានដល់ កាន់ដាវផង ខែលផង ។ បទថា **ធនុកលាបំ សន្នយ្ហិត្វា** (សៀតធ្នូ និងបំពង់ព្រួញហើយ) បានដល់ ស្ពាយធ្នូ និងបំពង់ធ្នូ ។ បទថា **វិយូឡ្ហំ** (ដែលកំពង់ប្រយុទ្ធកៀកគ្នា) បានដល់ តាំងនៅដោយការប្រឈមមុខដាក់គ្នា ។ បទថា **សង្គាមំ ឱតរតិ** (ចុះកាន់សង្គ្រាម) បានដល់ ចូលទៅកាន់ទីប្រយុទ្ធដែលមានមនុស្សច្រើន ។ បទថា **ឧស្សហតិ វាយមតិ** (ខំព្យាយាមខ្នះខ្នែង) បានដល់ ធ្វើសេចក្តីឧស្សាហ៍ព្យាយាម ។ បទថា **ហនន្តិ** (បៀតបៀន) បានដល់ ធ្វើឲ្យស្លាប់ ។ បទថា **បរិយាបាទេន្តិ** (សង្កត់សង្កិន) បានដល់ ធ្វើឲ្យឈឺចុកចាប់យ៉ាងខ្លាំង ។ បទថា **ឧបលិក្ខន្តិ** (រមែងធ្វើបាបគេឲ្យឈឺចុកចាប់) បានដល់ ចាក់ ។ បទថា **អបនេន្តិ** (ក៏នាំយកទៅ) បានដល់ នាំពួកទាហានខ្លួនទៅ ។ បទថា **អបនេត្វា ញាតកានំ នេន្តិ** (ក៏នាំយកទៅឲ្យដល់ពួកញាតិ) បានដល់ នាំទាហានចំណែកខ្លួនដែលសល់ពីសង្គ្រាម

បញ្ជូនទៅឲ្យពួកញាតិ ។ បទថា **នីយមានោ** (នាំយកទៅ) បានដល់ នាំទៅកាន់ផ្ទះខ្លួន ឬសំណាក់ញាតិដទៃ ។ បទថា **ឧបដ្ឋហន្តិ បរិចរន្តិ** (ញាតិទាំងឡាយក៏ទំនុកបម្រុង) បានដល់ ធ្វើការលាងរបួសដំបៅ និងព្យាបាលរបួសជាដើម ហើយថែរក្សាទំនុកបម្រុង ។

បទថា **អរក្ខិតេនេវ កាយេន** (មិនបានរក្សាកាយ) បានដល់ មានកាយទ្វារដែលមិនបានរក្សា ។ បទថា **អរក្ខិតាយ វាចាយ** (មិនបានរក្សាវាចា) បានដល់ មានវចីទ្វារដែលមិនបានរក្សា ។ បទថា **អរក្ខិតេន ចិត្តេន** (មិនបានរក្សាចិត្ត) បានដល់ មានមនោទ្វារដែលមិនបានរក្សា ។ បទថា **អនុបដ្ឋិតាយ សតិយា** (មិនតម្កល់ស្មារតី) បានដល់ មិនធ្វើសតិឲ្យតាំងមាំដោយល្អ ។ បទថា **អសំវុតេហិ ឥន្ទ្រិយេហិ** (មិនបានសង្រួមឥន្ទ្រិយ) បានដល់ មានឥន្ទ្រិយ៍ ដែលមានចិត្តជាទី ៦ ដែលមិនបានប្រុងប្រយ័ត្ន មិនបានគ្រប់គ្រងរក្សាហើយ ។ បទថា **រាគោ ចិត្តំ អនុទ្ធំសេតិ** (រាគៈក៏អុចអាលចិត្តនោះ) បានដល់ រាគៈកាលកើតឡើង រមែងលះបង់ចិត្តចោលក្នុងសមថៈ និងវិបស្សនា គឺ គ្រវែងចេញទៅឆ្ងាយ ។

បទថា **រាគាយិតោម្ហិ អាវុសោ រាគបរេតោ** (ម្នាលអាវុសោ ខ្ញុំត្រូវរាគៈជិះជាន់ហើយ) សេចក្ដីថា អ្នកដ៏មានអាយុ ខ្ញុំត្រូវរាគៈញាំញីហើយ

ត្រូវភគៈគ្របសង្កត់ហើយ ។

ក្នុងបទថា **ប្រៀបដូចរាងឆ្អឹង** ជាដើម កាមទាំងឡាយ លោកហៅថា **អដ្ឋិកង្កលូបមា** (មានឧបមាដូចរាងឆ្អឹង) ដោយអត្ថថា មានសេចក្តីត្រេកអរតិច ។ បទថា **មំសបេសូបមា** (មានឧបមាដូចដុំសាច់) ដោយអត្ថថា ទូទៅដល់មនុស្សចំនួនច្រើន ។ បទថា **តិណុក្កូបមា** (មានឧបមាដូចជាគប់ភ្លើងស្មៅ) ដោយអត្ថថា តាមដុតបំផ្លាញ ។ បទថា **អង្គារកាសូបមា** (មានឧបមាដូចជាគំនររងើកភ្លើង) ដោយអត្ថថា ធ្វើសេចក្តីក្តៅក្រហាយឲ្យកើតឡើង ។ បទថា **សុបិនកូបមា** (មានឧបមាដូចជាយល់សប្តិ) ដោយអត្ថថា ប្រាកដឡើងតិចតួច ។ បទថា **យាចិតកូបមា** (មានឧបមាដូចរបស់ខ្ចីគេ) ដោយអត្ថថា បានមួយគ្រា ។ បទថា **រុក្ខផលូបមា** (មានឧបមាដូចជាផ្លែឈើ) ដោយអត្ថថា ការបាក់អស់ទាំងដើម ។ បទថា **អសិសូនូបមា** (មានឧបមាដូចជាកាំបិត និងជ្រញ់) ដោយអត្ថថា កាប់ចិញ្ច្រាំ ។ បទថា **សត្តិសូលូបមា** (មានឧបមាដូចជាចុងលំពែង) ដោយអត្ថថា ចាក់ដោត ។ បទថា **សប្បសិរូបមា** (មានឧបមាដូចជាក្បាលពស់) ដោយអត្ថថា គួរភ័យខ្លាច ។

បទថា **ឧស្សហិស្សាមិ** (ខ្ញុំព្រះករុណានឹងព្យាយាម) បានដល់ នឹងធ្វើឧស្សាហៈ ។ បទថា **ធារយិស្សាម** (ខ្ញុំព្រះករុណានឹងទ្រទ្រង់) បានដល់

នឹងទ្រទ្រង់នូវសមថៈទុក ។ បទថា **អភិរមិស្សាមិ** (ខ្ញុំព្រះករុណានឹងត្រេកអរ) ក្នុងព្រហ្មចរិយៈឲ្យកើតឡើង អធិប្បាយថា នឹងមិនត្រេកអរក្នុងកាម ។ ពាក្យដ៏សេសក្នុងព្រះសូត្រនេះងាយយល់ហើយ ក្នុងព្រះសូត្រនេះត្រាស់ទាំងវដ្តៈ និងវិវដ្តៈ ។

ចប់អដ្ឋកថា ទុតិយយោធាជីវសូត្រទី ៦

# អដ្ឋកថា បឋមអនាគតសូត្រទី ៧

## (ភ័យក្នុងអនាគត ៥ ប្រការ)

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអនាគតសូត្រទី ៧ ដូចតទៅនេះ ៖

[៧៧] បទថា **អារញ្ញកេន** (ភិក្ខុអ្នកនៅព្រៃ) បានដល់ អ្នកនៅក្នុងព្រៃជាប្រក្រតី ។ បទថា **អប្បត្តស្ស** (ដែលខ្លួនមិនទាន់បានដល់) បានដល់ ដើម្បីដល់គុណវិសេស ដែលមានឈាន វិបស្សនា និងមគ្គផលដែលនៅមិនទាន់បាន ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **សោ មមស្ស អន្តរាយោ** (គប្បីមានដល់អាត្មាអញ ដោយហេតុនោះ អន្តរាយនោះ) សេចក្តីថា អន្តរាយនៃជីវិត និងអន្តរាយនៃព្រហ្មចរិយៈនោះ នឹងគប្បីមានដល់យើង កាលដែលយើងស្លាប់ទាំងនៅជាបុថុជ្ជន អន្តរាយនៃសួគ៌ និងអន្តរាយនៃមគ្គ នឹងគប្បីមាន ។ **ហន្ទ** (បើដូច្នោះ) ជានិបាតចុះក្នុងអត្ថជាស់តឿនខ្លួនឯង ។

បទថា **វីរិយំ អារភាមិ** (អាត្មាអញប្រារព្ធនូវសេចក្តីព្យាយាម) បានដល់ យើងនឹងធ្វើសេចក្តីព្យាយាម ២ យ៉ាង ។ បទថា **សត្ថកា** (ដូចជាកាំបិត) បានដល់ ខ្យល់ដែលកាត់ទីត និងសរសៃពួរដូចសស្ត្រា ។ បទថា **វាឡេហិ** (ម្រឹគសាហាវ) បានដល់ គួរឲ្យខ្លាច ។ បទថា **មាណវេហិ** (ចោរ-

កម្ម) បានដល់ ពួកចោរ ។ ក្នុងពាក្យថា កតកម្មេហិ វា អកតកម្មេហិ វា (ដែលធ្វើចោរកម្មហើយក្តី ដែលមិនទាន់បានធ្វើចោរកម្មក្តី) បានដល់ ចោរទាំងឡាយ ដែលចេញទៅធ្វើចោរកម្មហើយ ឈ្មោះថា អ្នកធ្វើកម្មហើយ អ្នកចេញទៅដើម្បីធ្វើចោរកម្ម (ព្យាយាម) ឈ្មោះថា អ្នកមិនទាន់បានធ្វើចោរកម្ម ។ បណ្តាចោរ ២ ពួកនោះ អ្នកធ្វើកម្មហើយ កាន់យកឈាមក្នុងបំពង់ករបស់សត្វទាំងឡាយ ធ្វើការសែនទេវតា ឈ្មោះថា ព្រោះកម្មសម្រេចហើយ ។ អ្នកមិនទាន់បានធ្វើកម្ម ធ្វើកម្មដូចមុន ដោយគិតថា កម្មរបស់យើងនឹងសម្រេចផល ដោយវិធីយ៉ាងនេះ ទ្រង់សំដៅយកប្រការនេះ ទើបត្រាស់ថា តេ មំ ជីវិតា វោរោបេយ្យុំ (ចោរទាំងនោះ គប្បីផ្តាច់បង់នូវអាត្មាអញចាកជីវិតនោះ) ។ បទថា វាឡាអមនុស្សា បានដល់ ពួកអមនុស្ស មានយក្សជាដើម ដែលកាចឃោរឃៅ ។

ចប់អដ្ឋកថា បឋមអនាគតសូត្រទី ៧

# អដ្ឋកថា ទុតិយអនាគតសូត្រទី ៨

*(ភ័យក្នុងអនាគត ៥ ប្រការ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយអនាគតសូត្រទី ៨ ដូចតទៅនេះ ៖*

*[៧៨] បទថា **បុរា មំ សោ ធម្មោ អាគច្ឆតិ** (រមែងមានដល់អាត្មាអញមុន បើដូច្នោះ អាត្មាអញប្រារព្ធសេចក្តីព្យាយាមឲ្យបានមុន) សេចក្តីថា ធម៌នោះនៅមិនទាន់មកដល់អាត្មាអញអស់កាលត្រឹមណា អាត្មាអញនឹងផ្តើមសេចក្តីព្យាយាមអស់កាលត្រឹមនោះឯង ។ បទថា **ខីរោទកីភូតា** (ដូចជាទឹកដោះលាយដោយទឹក) បានដល់ ដូចទឹកដោះលាយជាមួយទឹក គឺដល់នូវភាពតែមួយ ។ បទថា **បិយចក្ខូហិ** (ដោយចក្ខុជាទីស្រឡាញ់) បានដល់ ដោយចក្ខុដែលពោរពេញទៅដោយមេត្តា ។*

ចប់អដ្ឋកថា ទុតិយអនាគតសូត្រទី ៨

# អដ្ឋកថា តតិយអនាគតសូត្រទី ៩

## (ភ័យក្នុងអនាគត ៥ ប្រការ)

គប្បីជ្រាបវិនិច្ឆ័យក្នុង តតិយអនាគតសូត្រទី ៩ ដូចតទៅនេះ ៖

[៧៩] បទថា **ធម្មសន្ទោសា វិនយសន្ទោសោ** (ការខូចវិន័យ ព្រោះការខូចធម៌ ការខូចធម៌ ព្រោះការខូចវិន័យ) បានដល់ ការសាបសូន្យនៃវិន័យរមែងមាន ព្រោះការសាបសូន្យនៃធម៌ ។ សួរថា ក៏កាលសាបសូន្យវិន័យ រមែងឈ្មោះថា ការសាបសូន្យអ្វី ។ ឆ្លើយថា កាលធម៌ គឺ សមថៈនិងវិបស្សនាមិនប្រព្រឹត្តទៅ វិន័យ ៥ យ៉ាង រមែងមិនមាន ។ កាលធម៌សាបសូន្យ វិន័យក៏ឈ្មោះថា សាបសូន្យដោយប្រការដូច្នេះ ។ ក៏សំវរវិន័យរមែងមិនមានដល់ភិក្ខុអ្នកទ្រុស្តសីល កាលសំវរវិន័យនោះមិនមាន សមថៈនិងវិបស្សនាក៏មិនប្រព្រឹត្តទៅ ។ គប្បីជ្រាបសេចក្តីសាបសូន្យនៃធម៌ សូម្បីដោយការសាបសូន្យនៃវិន័យ ដោយប្រការដូច្នេះ ។

បទថា **អភិធម្មកថំ** (អភិធម្មកថា) បានដល់ កថាពោលដោយធម៌ខ្ពស់បំផុត មានសីលជាដើម ។ បទថា **វេទល្លកថំ** (វេទល្លកថា) បានដល់កថាលាយដោយញាណ ដែលប្រកបដោយការដឹង ។ បទថា **កណ្ហំ ធម្មំ ឱក្កមមានា** (ឈានចុះកាន់ធម៌ខ្មៅ) បានដល់ ឈានចុះកាន់ធម៌ចំណែកខ្មៅ

ដោយការស្វែងរកគុណវិបត្តិ (កំហុស) ព្រោះការស្វែងរកចំណុចដែលគួរឲ្យតិះដៀល ។ មួយទៀត ភិក្ខុទាំងឡាយ កាលប៉ះពាល់បុគ្គលដោយចិត្តគិតអាក្រក់ក្តី កាលកាន់យកធម៌ចំណែកខ្មៅនោះសម្រាប់ខ្លួនឯងក្តី កាលពោលដើម្បីលាភសក្ការៈក្តី ឈ្មោះថា ឈានចុះកាន់ធម៌ចំណែកខ្មៅដូចគ្នា ។

បទថា **គម្ភីរា** (ជ្រាលជ្រៅ) បានដល់ ជ្រាលជ្រៅដោយបទបាលី ។ បទថា **គម្ភីរត្ថា** (ជ្រាលជ្រៅដោយអត្ថ) បានដល់ ជ្រាលជ្រៅដោយអត្ថ ។ បទថា **លោកុត្តរា** (ជាលោកុត្តរធម៌) បានដល់ សម្តែងលោកុត្តរធម៌ ។ បទថា **សុញ្ញតាបដិសំយុត្តា** (ប្រកបដោយសភាពសោះសូន្យ) បានដល់ ប្រកបដោយខន្ធ ធាតុ អាយតនៈ និងបច្ចយាការ ។ បទថា **ន អញ្ញាចិត្តំ ឧបដ្ឋាបេស្សន្តិ** (មិនតាំងចិត្តដើម្បីចង់ដឹងសោះ) បានដល់ មិនតាំងចិត្តទុកដើម្បីដឹង ។ បទថា **ឧគ្គហេតព្វំ បរិយាបុណិតព្វំ** (ទាំងមិនសម្គាល់នូវកិច្ចដែលខ្លួនត្រូវរៀន) បានដល់ គប្បីសិក្សា គប្បីបដិបត្តិ ។ បទថា **កវិកតា** (ដែលកវីតាក់តែង) បានដល់ ដែលកវីតាក់តែងដោយពាក្យស្លោកជាដើម ។ បទថា **កាវេយ្យា** (ជាពាក្យកាព្យឃ្លោង) ជាវេវចនៈនៃបទថា **កវិកតា** នោះឯង ។ បទថា **ពាហិរកា** (ជាពាក្យខាងក្រៅ) បានដល់ ដែលតាំងនៅខាងក្រៅព្រះសាសនា ។ បទថា **សាវកភាសិតា** (ជាភាសិតរបស់សាវក)

បានដល់ ដែលជាសាវកខាងក្រៅសាសនាពោលទុក ។ បទដ៏សេសក្នុង
សូត្រនេះ មានសេចក្តីងាយយល់ទាំងអស់ ព្រោះមានន័យដូចដែលពោល
ទុកហើយក្នុងខាងក្រោយ និងព្រោះដឹងបានងាយ ។

ចប់អដ្ឋកថា តតិយអនាគតសូត្រទី ៩

# អដ្ឋកថា ចតុត្ថអនាគតសូត្រទី ១០

## (ភ័យក្នុងអនាគត ៥ ប្រការ)

គប្បីជ្រាបវិនិច្ឆ័យក្នុង ចតុត្ថអនាគតសូត្រទី ១០ ដូចតទៅនេះ ៖

[៨០] បទថា **កល្យាណកាមា (ប្រាថ្នាល្អក្នុងចីវរ)** បានដល់ ជាអ្នកត្រូវការរបស់ស្អាតល្អ ។ បទថា **រសគ្គានិ (រសទាំងឡាយដ៏ប្រសើរ)** បានដល់ ដែលមានឱជារសយ៉ាងខ្លាំង ។ បទថា **សំសដ្ឋា វិហរិស្សន្តិ (នឹងមានភិក្ខុនៅច្រឡូកច្រឡំគ្នា)** បានដល់ នឹងនៅដោយការច្រឡូកច្រឡំ ៥ យ៉ាង ។ បទថា **សន្និធិការបរិភោគំ (ការបរិភោគនូវវត្ថុដែលខ្លួនសន្សំទុក)** បានដល់ ការបរិភោគរបស់ដែលធ្វើការសន្សំទុកហើយ មិនត្រូវតាមវិន័យ ។ ក្នុងបទថា **ឱឡារិកំបិ និមិត្តំ (ទាំងធ្វើនូវនិមិត្តដ៏ជ្រោកជ្រាក)** នេះ អធិប្បាយថា ភិក្ខុជីកដីខ្លួនឯងក្តី ប្រើគេឲ្យជីកក្តី ឈ្មោះថា ធ្វើនិមិត្តយ៉ាងជ្រោកជ្រាកនូវក្នុងផែនដី ។ ភិក្ខុកាត់ខ្លួនឯងក្តី ប្រើឲ្យគេកាត់ក្តី នូវស្មៅ ឈើ មែកឈើ ស្លឹកឈើ ឈ្មោះថា ធ្វើនិមិត្តយ៉ាងជ្រោកជ្រាក ដែលបំផ្លាញរបស់ខៀវ មានស្មៅជាដើម ។ ភិក្ខុឲ្យគេកាន់យកស្លឹកឈើ និងបន្លែជាដើម រក្សាទុកខ្លួនឯងក្តី ប្រើគេឲ្យរក្សាទុកក្តី នូវផ្លែឈើដើម្បីប្រយោជន៍ដល់ការចិញ្ចឹមជីវិត ក៏មិនបានពោលដល់ការលះ ។ ក្នុងព្រះសូត្រទាំង ៤

*នេះ ព្រះសាស្តាទ្រង់សម្តែងសេចក្តីចម្រើន និងសេចក្តីជ្រះថ្លាក្នុងព្រះសាសនា ទុក ៗ*

ចប់អដ្ឋកថា ចតុត្ថអនាគតសូត្រទី ១០

## ចប់យោធាជីវវគ្គវណ្ណនាទី ៣

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# ថេរវគ្គវណ្ណនាទី ៤

## អដ្ឋកថា វេជនីយសូត្រទី ១

*(ធម៌ជាហេតុឲ្យព្រះថេរៈគួរគោរព និងមិនគួរគោរព)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វេជនីយសូត្រទី ១ ដូចតទៅនេះ ៖*

[៨១] *បទថា វេជនីយេ (គឺកិក្កុត្រេកអរក្នុងអារម្មណ៍ជាទីត្រេកអរ) បានដល់ ក្នុងអារម្មណ៍ទាំងឡាយ ដែលជាបច្ច័យដល់រាគៈ ។*

ចប់អដ្ឋកថា វេជនីយសូត្រទី ១

# អដ្ឋកថា វីតរាគសូត្រទី ២

*(ធម៌ជាហេតុឲ្យព្រះថេរៈគួរគោរព និងមិនគួរគោរព)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វីតរាគសូត្រទី ២ ដូចតទៅនេះ ៖*

[៨២] *បទថា* ***មក្ខី*** *(ជាអ្នកលុបគុណគេ) បានដល់ ជាអ្នកមិនធ្វើតបចំពោះលោកអ្នកមានគុណ ។ បទថា* ***បឡាសី*** *(ប្រណាំងប្រជែងវាស្នា) បានដល់ ជាអ្នកប្រកបដោយការវាយឫកស្មើ ដែលមានការប្រណាំងប្រជែងជាលក្ខណៈ ។*

ចប់អដ្ឋកថា វីតរាគសូត្រទី ២

# អដ្ឋកថា កុហកសូត្រទី ៣

*(ធម៌ជាហេតុឲ្យព្រះថេរៈគួរគោរព និងមិនគួរគោរព)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កុហកសូត្រទី ៣ ដូចតទៅនេះ ៖*

*[៨៣] បទថា* ***កុហកោ*** *(ជាអ្នកប្រើកិរិយាបំភ័ន្ត) បានដល់ ជាអ្នកប្រកបដោយកុហនវត្ថុ (រឿងបោកបញ្ឆោត) ។*

*បទថា* ***លបកោ*** *(ជាអ្នករួសរាក់) បានដល់ ជាអ្នកប្រកបដោយពាក្យបញ្ឆោតអាស្រ័យលាភ ។ បទថា* ***និមិត្តិកោ*** *(ជាអ្នកនិយាយឲ្យទំនង) បានដល់ ជាអ្នកធ្វើអាការដែលសម្តែងនៃនិមិត្ត (ពោលបញ្ចិតបញ្ចៀង) ។ បទថា* ***និប្បេសិកោ*** *(ជាអ្នកមានកលល្បិច) បានដល់ ជាអ្នកប្រកបដោយការនិយាយបន្តិតបន្តុំ ។ បទថា* ***លាភេន លាភំ និជិគីសិតា*** *(ជាអ្នកស្វែងរកលាភដោយលាភ) បានដល់ ជាអ្នកស្វែងរកលាភដោយលាភ ។ ធម៌ខាងចំណែកល្អ គប្បីជ្រាបដោយសេចក្តីផ្ទុយគ្នានឹងពាក្យដែលពោលមកហើយ ។*

ចប់អដ្ឋកថា កុហកសូត្រទី ៣

## អដ្ឋកថា អសទ្ធសូត្រទី ៤

*(ធម៌ជាហេតុឲ្យព្រះថេរៈគួរគោរព និងមិនគួរគោរព)*

[៨៤] *សូត្រទី ៤ នេះ មានសេចក្ដីងាយយល់ហើយ ។*

ចប់អដ្ឋកថា អសទ្ធសូត្រទី ៤

# អដ្ឋកថា អក្ខមសូត្រទី ៥

*(ធម៌ជាហេតុឲ្យព្រះថេរៈគួរគោរព និងមិនគួរគោរព)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អក្ខមសូត្រទី ៥ ដូចតទៅនេះ ៖*

*[៨៥] បទថា អក្ខមោ ហោតិ រូបានំ (ជាអ្នកមិនអត់ធន់នឹងរូប) បានដល់ ជាបុគ្គលមិនអត់ធន់ចំពោះរូបារម្មណ៍ គឺ រមែងត្រូវរាគៈជាដើម ដែលមានរូបនោះជាអារម្មណ៍ គ្របសង្កត់ ។ ក្នុងបទទាំងពួង ក៏មានន័យនេះដូចគ្នា ។*

ចប់អដ្ឋកថា អក្ខមសូត្រទី ៥

# អដ្ឋកថា បដិសម្ភិទាសូត្រទី ៦

*(ព្រះថេរៈប្រកបដោយធម៌ ៥ រមែងជាទីគោរព)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បដិសម្ភិទាសូត្រទី ៦ ដូចតទៅនេះ ៖*

[៨៦] *បទថា* ***អត្ថប្បដិសម្ភិទាបត្តោ*** *(គឺជាភិក្ខុបានអត្ថប្បដិសម្ភិទា) បានដល់ ជាអ្នកបានញាណបែកធ្លាយក្នុងអត្ថ ៥ យ៉ាង ។ បទថា* ***ធម្មប្បដិសម្ភិទាបត្តោ*** *(បានទូវធម្មប្បដិសម្ភិទា) បានដល់ ជាអ្នកបានញាណដែលបែកធ្លាយក្នុងធម៌ ៤ យ៉ាង ។ បទថា* ***និរុត្តិប្បដិសម្ភិទាបត្តោ*** *(បាននិរុត្តិប្បដិសម្ភិទា) បានដល់ ជាអ្នកបានញាណដែលបែកធ្លាយក្នុងធម្មនិរុត្តិ ។ បទថា* ***បដិភាណប្បដិសម្ភិទាបត្តោ*** *(បានបដិភាណប្បដិសម្ភិទា) បានដល់ ជាអ្នកបានញាណដែលបែកធ្លាយក្នុងញាណទាំងនោះ ។ តែភិក្ខុដែលបានបដិភាណប្បដិសម្ភិទាទាំងនោះ រមែងដឹងញាណទាំង ៣ ប៉ុណ្ណោះ មិនបានធ្វើកិច្ចរបស់ញាណទាំងនោះទេ ។ បទថា* ***ឧច្ចាវចានិ*** *(ទោះបីតូចធំ) បានដល់ ដែលធំជាង ឬតូចជាង ។ បទថា* ***កឹករណីយានិ*** *(ករណីយកិច្ច) បានដល់ កិច្ចដែលគួរធ្វើយ៉ាងនេះ ។*

ចប់អដ្ឋកថា បដិសម្ភិទាសូត្រទី ៦

# អដ្ឋកថា សីលសូត្រទី ៧

*(ព្រះថេរៈប្រកបដោយធម៌ ៥ រមែងជាទីគោរព)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សីលសូត្រទី ៧ ដូចតទៅនេះ ៖*

[*៨៧*] *សីលសូត្រទី ៧ ងាយយល់ទាំងអស់ ។ ក៏ក្នុងសូត្រនេះ គប្បីជ្រាបថា* ***សីល*** *ត្រាស់ចំពោះសីលរបស់ព្រះខីណាស្រព ។ សូម្បី* ***ពហុសច្ចៈ*** *ក៏ត្រាស់ចំពោះពហុសច្ចៈរបស់ព្រះខីណាស្រព ។ សូម្បី* ***វាចា*** *ក៏ត្រាស់ចំពោះវាចាដ៏ស្ងប់រម្ងាប់របស់ព្រះខីណាស្រព ។ សូម្បី* ***ឈាន*** *ក៏ត្រាស់ចំពោះកិរិយាឈានរបស់ព្រះខីណាស្រពប៉ុណ្ណោះ ដូចគ្នា ។*

ចប់អដ្ឋកថា សីលសូត្រទី ៧

# អដ្ឋកថា ថេរសូត្រទី ៨

## (ធម៌ជាប្រយោជន៍ និងមិនជាប្រយោជន៍ដល់ជនច្រើន)

*គប្បីជ្រាបវិនិច្ឆ័យក្នុង ថេរសូត្រទី ៨ ដូចតទៅនេះ ៖*

*[៨៨] បទថា **ថេរោ** (ភិក្ខុជាថេរៈ) បានដល់ ជាអ្នកដល់នូវភាព រឹងមាំ ។ បទថា **រត្តញ្ញូ** (ដឹងរាត្រី) បានដល់ ជាអ្នកដឹងរាត្រីដ៏ច្រើនដែល កន្លងមកហើយ តាំងពីថ្ងៃបួស ។ បទថា **ញាតោ** (មានឈ្មោះល្បីល្បាញ) បានដល់ ដែលគេស្គាល់ គឺ ប្រាកដហើយ ។ បទថា **យសស្សី** (មានយស បរិវារច្រើន) បានដល់ ជាអ្នកអាស្រ័យយស ។ បទថា **មិច្ឆាទិដ្ឋិកោ** (តែ ជាមិច្ឆាទិដ្ឋិ) បានដល់ ជាអ្នកមិនឃើញតាមសេចក្តីពិត ។ បទថា **សទ្ធម្មា វុដ្ឋាបេត្វា** (ឲ្យឃ្លាតចាកព្រះសទ្ធម្ម) បានដល់ បបួលឲ្យចេញចាកធម៌ គឺ កុសលកម្មបថ ១០ ។ បទថា **អសទ្ធម្មេ បតិដ្ឋាបេតិ** (ឲ្យតម្កល់នៅក្នុង អសទ្ធម្ម) បានដល់ ឲ្យតាំងនៅក្នុងអកុសលកម្មបថ ១០ ។*

ចប់អដ្ឋកថា ថេរសូត្រទី ៨

# អដ្ឋកថា បឋមសេក្ខសូត្រទី ៩

## (ធម៌ប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស និងមិនវិនាសដល់ព្រះសេក្ខៈ)

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសេក្ខសូត្រទី ៩ ដូចតទៅនេះ ៖

[៨៩] បទថា **សេក្ខស្ស** (ដល់ភិក្ខុជាសេក្ខៈ) បានដល់ ភិក្ខុដែលនៅត្រូវការសិក្សា គឺ នៅមានកិច្ចដែលនឹងត្រូវធ្វើ ។ បទថា **បរិហានាយ** (ដើម្បីសេចក្តីវិនាស) បានដល់ ដែលជាបច្ច័យនៃសេចក្តីវិនាសចាកគុណដ៏ខ្ពង់ខ្ពស់ (គឺលោកុត្តរៈ) ។ សេចក្តីត្រេកអរក្នុងការកសាង ឈ្មោះថា **កម្មារាមតា** (គឺជាអ្នកត្រេកអរនឹងការងារ) ។ សេចក្តីត្រេកអរក្នុងការនិយាយគ្នាលេង ឈ្មោះថា **ភស្សារាមតា** (សេចក្តីត្រេកអរនឹងតិរច្ឆានកថា) ។ សេចក្តីត្រេកអរក្នុងការដេក ឈ្មោះថា **និទ្ទារាមតា** (សេចក្តីត្រេកអរនឹងកិរិយាដេកលក់) ។ បទថា **សង្គណិការាមតា** ត្រេកអរនឹងការប្រឡូកប្រឡំដោយពួក ។ បទថា **យថាវិមុត្តំ ចិត្តំ ន បច្ចវេក្ខតិ** (មិនពិចារណាចិត្តដែលផុតចាកកិលេសណា ១) សេចក្តីថា មិនពិចារណាចិត្តតាម ដែលរួចផុតហើយ ពិចារណាដល់ទោសដែលខ្លួនលះបង់បានហើយ និងគុណដែលខ្លួនបានចំពោះហើយ តែមិនធ្វើសេចក្តីព្យាយាម ដើម្បីបានគុណធម៌ខ្ពង់ខ្ពស់ឡើងទៅ (ពោល គឺ មគ្គ ៤ ផល ៤ និងនិព្វាន ១) ។ ក្នុងសូត្រនេះ ទ្រង់ត្រាស់ហេតុនៃសេចក្តី

*វិនាស និងហេតុនៃសេចក្ដីចម្រើនដោយគុណធម៌ខ្ពង់ខ្ពស់របស់ព្រះសេក្ខៈ ៧ ពួក ដោយប្រការដូច្នេះ ។ ក៏ហេតុណា ជាហេតុនៃសេចក្ដីវិនាសរបស់ព្រះសេក្ខៈ ហេតុនោះ ក៏ជាហេតុដែលត្រូវរំលត់ដំបូង សម្រាប់បុថុជ្ជននោះឯង ។*

ចប់អដ្ឋកថា បឋមសេក្ខសូត្រទី ៩

# អដ្ឋកថា ទុតិយសេក្ខសូត្រទី ១០

*(ធម៌ប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស និងមិនវិនាសដល់ព្រះសេក្ខៈ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសេក្ខសូត្រទី ១០ ដូចតទៅនេះ ៖*

*[៩០] បទថា **វិយត្តោ** (ឈ្លាសវៃ) បានដល់ អ្នកអាច គឺ ខ្វាត ។ បទថា **កឹករណីយេសុ** (ក្នុងកិច្ចដែលត្រូវធ្វើអ្វីៗ) បានដល់ ក្នុងកិច្ចដែលគួរធ្វើយ៉ាងនេះ ។ បទថា **ចេតោសមថំ** (សេចក្តីស្ងប់ចិត្ត) បានដល់ សមាធិកម្មដ្ឋាន ។ បទថា **អននុលោមិកេន** (មិនសមគួរ) បានដល់ ដែលមិនសមគួរដល់សាសនា ។ បទថា **អតិកាលេន** (ចូលទៅកាន់ស្រុកពីព្រឹកពេក) បានដល់ ចូលទៅកាន់ស្រុកពីព្រឹកព្រលឹម ។ បទថា **អតិទិវា** (ចេញមកវិញថ្ងៃពេក) បានដល់ វេលាដែលថ្ងៃត្រង់ទៅហើយ ។ បទថា **អភិសល្លេខិកា** (ដែលជាគ្រឿងជុសខាត់កិលេស) បានដល់ ជាវត្តបដិបត្តិជុសខាត់កិលេសយ៉ាងក្រៃលែង ។ បទថា **ចេតោវិវរណសប្បាយា** (ជាទីសប្បាយដល់ធម៌ជាគ្រឿងបើកចិត្ត) បានដល់ ជាទីសប្បាយដល់សមថៈ និងវិបស្សនា ពោលគឺ ធម៌ជាគ្រឿងបើកចិត្ត ។ បទថា **អប្បិច្ឆកថា** (គឺវាចានាំឲ្យកើតសេចក្តីប្រាថ្នាតិច) បានដល់ ពាក្យទូន្មានដែលពោលថា អ្នកទាំងឡាយចូរជាអ្នកប្រាថ្នាតិច ។ បទថា **សន្តុដ្ឋិកថា** (វាចានាំឲ្យកើតសន្តោស) បានដល់*

ពាក្យទូន្មានដែលពោលថា អ្នកទាំងឡាយចូលជាអ្នកសន្ដោសដោយបច្ច័យ ៤ ។

បទថា **បវិវេកកថា** (វាចានាំឲ្យស្ងប់ស្ងាត់) បានដល់ ពាក្យទូន្មានដែលពោលថា អ្នកទាំងឡាយចូរជាអ្នកស្ងាត់ដោយវិវេក ៣ ។

បទថា **អសំសគ្គកថា** (វាចាដែលមិននាំឲ្យច្រឡូកច្រឡំ) បានដល់ពាក្យទូន្មានដែល ពោលថា អ្នកទាំងឡាយ ចូរជាអ្នកមិនច្រឡូកច្រឡំដោយការច្រឡូកច្រឡំ ៥ យ៉ាង ។

បទថា **វីរិយារម្ភកថា** (វាចានាំឲ្យប្រារព្ធសេចក្ដីព្យាយាម) បានដល់ពាក្យដែលពោលថា អ្នកទាំងឡាយចូលប្រារព្ធសេចក្ដីព្យាយាម ២ យ៉ាង ។

ក្នុងបទថា **សីលកថា** ជាដើម អធិប្បាយថា ពាក្យប្រារព្ធសីលឈ្មោះថា **សីលកថា** ។ ពាក្យប្រារព្ធសមាធិ ឈ្មោះថា **សមាធិកថា** ។

ពាក្យប្រារព្ធបញ្ញា ឈ្មោះថា **បញ្ញាកថា** ។ ពាក្យប្រារព្ធវិមុត្តិ ឈ្មោះថា **វិមុត្តិកថា** ។ ពាក្យប្រារព្ធវិមុត្តិញាណទស្សនៈ ពោលគឺ បច្ចវេក្ខណញាណ ១៩ ឈ្មោះថា **វិមុត្តិញាណទស្សនកថា** ។ ក្នុងបទជាដើមថា **ន និកាមលាភី** (មិនជាអ្នកបានតាមប្រាថ្នា) មានសេចក្ដីអធិប្បាយថា មិនបានតាមដែលខ្លួនប្រាថ្នា បានដោយលំបាក មិនបានដោយស្រួល ។

*ពាក្យដ៏សេសក្នុងសូត្រនេះ ងាយយល់ហើយនោះឯង ។*

ចប់អដ្ឋកថា ទុតិយសេក្ខសូត្រទី ១០

## ចប់ជេរវគ្គវណ្ណនាទី ៤

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៩ សូត្រ

# កកុធវគ្គវណ្ណនាទី ៥

## អដ្ឋកថា បឋមសម្បទាសូត្រទី ១

*(ពោលដោយសម្បទា ៥ )*

[៩១] *ក្នុងសូត្រនេះ ទ្រង់ត្រាស់សម្បទា ៥ លាយគ្នា ។*

ចប់អដ្ឋកថា បឋមសម្បទាសូត្រទី ១

# អដ្ឋកថា ទុតិយសម្បទាសូត្រទី ២

*(ពោលដោយសម្បទា ៥ )*

[៩២] *ក្នុងសូត្រទី ២ ទ្រង់ត្រាស់សម្បទា ៤ ខាងដើមលាយលំគ្នា សម្បទាទី ៥ ជាលោកិយៈសុទ្ធ ។*

ចប់អដ្ឋកថា ទុតិយសម្បទាសូត្រទី ២

# អដ្ឋកថា ព្យាករណសូត្រទី ៣

## (ការព្យាករណ៍ព្រះអរហត្ត ៥ ប្រការ)

គប្បីជ្រាបវិនិច្ឆ័យក្នុង ព្យាករណសូត្រទី ៣ ដូចតទៅនេះ ៖

[៩៣] បទថា *អញ្ញាព្យាករណានិ* (ការព្យាករណ៍ (អួត) អរហត្តផល) បានដល់ ការប្រកាសថា ជាព្រះអរហន្ត ។ បទថា *មន្ទត្តា* (ព្រោះតែខ្លួនល្ងង់) បានដល់ ព្រោះសេចក្តីល្ងង់ ព្រោះមិនដឹង ។ បទថា *មោមូហត្តា* (វង្វេង) បានដល់ ព្រោះសេចក្តីវង្វេង ។ បទថា *អញ្ញំ ព្យាករោតិ* (ហើយព្យាករណ៍អរហត្តផល) បានដល់ រមែងពោលថា យើងសម្រេចអរហត្ត ។ បទថា *ឥច្ឆាបកតោ* (លុះក្នុងអំណាចសេចក្តីប្រាថ្នា) បានដល់ កិក្ខុត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ ។ បទថា *អធិមានេន* (ដោយសម្គាល់ថាខ្លួនបាន) បានដល់ ដោយសម្គាល់ថា ខ្លួនបានសម្រេច ។ បទថា *សម្មទេវ* (តាមត្រឹមត្រូវមែន) បានដល់ ដោយហេតុ ដោយន័យ ដោយការណៈប៉ុណ្ណោះ ។

ចប់អដ្ឋកថា ព្យាករណសូត្រទី ៣

# អដ្ឋកថា ផាសុសូត្រទី ៤

## (ធម៌នៅជាសុខ ៥ ប្រការ)

គប្បីជ្រាបវិនិច្ឆ័យក្នុង ផាសុសូត្រទី ៤ ដូចតទៅនេះ ៖

[៩៤] បទថា ផាសុវិហារ (ភិក្ខុមានការនៅសប្បាយនេះ) បានដល់ធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ។

ចប់អដ្ឋកថា ផាសុទី ៤

# អដ្ឋកថា អកុប្បសូត្រទី ៥

*(ធម៌ធ្វើឲ្យសម្រេចមគ្គផលបានរហ័ស)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អកុប្បសូត្រទី ៥ ដូចតទៅនេះ ៖*

[៩៥] *បទថា អកុប្បំ (មិនកម្រើក) បានដល់ ព្រះអរហត្ត ។*

ចប់អដ្ឋកថា អកុប្បសូត្រទី ៥

# អដ្ឋកថា សុតសូត្រទី ៦

*(ធម៌ធ្វើឲ្យសម្រេចមគ្គផលបានរហ័ស)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុតសូត្រទី ៦ ដូចតទៅនេះ ៖*

*[៩៦] បទថា **អប្បដ្ឋោ** (ខ្វល់ខ្វាយតិច) បានដល់ ជាអ្នកប្រារព្ធដល់ការងារតិច ។ បទថា **សុភរោ** (គេចិញ្ចឹមងាយ) បានដល់ ជាអ្នកដែលគេចិញ្ចឹមបានងាយ ។ បទថា **សុសន្តោសោ** (សន្តោសល្អ) បានដល់ជាអ្នកសន្តោសដោយល្អ ដោយការសន្តោស ៣ យ៉ាង ។ បទថា **ជីវិតបរិក្ខារេសុ** (ក្នុងបរិក្ខារជាគ្រឿងចិញ្ចឹមជីវិតទាំងឡាយ) បានដល់ ក្នុងវត្ថុដែលចាំបាច់ដល់ការចិញ្ចឹមជីវិត ។ បទថា **អប្បាហារោ** (ជាអ្នកមានអាហារតិច) បានដល់ ជាអ្នកបរិភោគអាហារតិចតួច ។ បទថា **អនោទរិកត្តំ** (នូវភាពជាអ្នកមានអាហារតិចក្នុងពោះ) បានដល់ ដល់ភាពជាអ្នកមានអាហារតិចក្នុងពោះ គឺ មិនបរិភោគច្រើន ។ បទថា **អប្បមិទ្ធោ** (ជាអ្នកដេកលក់តិច) បានដល់ អ្នកមិនដេកច្រើន ។*

ចប់អដ្ឋកថា សុតសូត្រទី ៦

# អដ្ឋកថា កថាសូត្រទី ៧

*(ធម៌ធ្វើឲ្យសម្រេចមគ្គផលបានរហ័ស)*

[៩៧] *ក្នុងកថាសូត្រទី ៧ មានសេចក្ដីងាយយល់ហើយ ។*

ចប់អដ្ឋកថា កថាសូត្រទី ៧

# អដ្ឋកថា អរញ្ញសូត្រទី ៨

*(ធម៌ធ្វើឲ្យសម្រេចមគ្គផលបានរហ័ស)*

[៩៨] *ក្នុងអរញ្ញសូត្រទី ៨ មានសេចក្តីងាយយល់ហើយ ។*

ចប់អដ្ឋកថា អរញ្ញសូត្រទី ៨

# អដ្ឋកថា សីហសូត្រទី ៩

## (ព្រះពុទ្ធសម្ដែងធម៌ដូចរាជសីហ៍ចាប់សត្វ)

គប្បីជ្រាបវិនិច្ឆ័យក្នុង សីហសូត្រទី ៩ ដូចតទៅនេះ ៖

[៩៩] បទថា **សក្កច្ចញ្ញេវ បហារំ ទេតិ នោ អសក្កច្ចំ** (គឺប្រហារយ៉ាងប្រយ័ត្ន) សេចក្ដីថា ប្រហារដោយមិនខុស ព្រោះមិនមើលងាយ គឺមិនមែនប្រហារខុស ព្រោះការមើលងាយ ។ បទថា **មា មេ យោគ្គបថោ នស្សាតិ** (ព្រោះសីហៈគិតថា ផ្លូវព្យាយាមរបស់អញ ចូរកុំវិនាសឡើយ) សេចក្ដីថា លើកដៃប្រហារសត្វដែលអាត្មាអញជំនាញហើយ ផ្លូវរបស់អញចូរកុំវិនាសឡើយ ។ អធិប្បាយថា ចូរកុំមានអ្នកពោលយ៉ាងនេះថា សីហៈជាស្ដេចម្រឹគខ្លួនតែមួយ កាលក្រោកឡើងលោតសង្គ្រប់ផ្លា ក៏សង្គ្រប់មិនបានដែរ ។ ក្នុងបទថា **អន្នភារនេសាទានំ** (សូម្បីពួកអ្នកនាំបាយ និងពួកអ្នកនេសាទ) នេះ បាយ ហៅថា **អន្ន** បាយនោះឯង ជាវត្ថុចាំបាច់របស់មនុស្សនោះឯង ព្រោះហេតុនោះ មនុស្សទាំងនោះទើបឈ្មោះថា **អន្នភារ** (មានបាយជាភារៈ) ពាក្យនោះ ជាឈ្មោះរបស់មនុស្សអ្នកសូមទាន ។ អ្នកនេសាទ ហៅថា **នេសាទៈ** ព្រះតថាគតទ្រង់សម្ដែងធម៌ដោយគោរព សូម្បីដល់អ្នកសូមទាន និងអ្នកនេសាទទាំងនោះ ដោយហោចចំពោះមនុស្សនៅ

ខាងក្រោយ ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា សីហសូត្រទី ៩

# អដ្ឋកថា កកុធសូត្រទី ១០

## (សាស្តា ៥ ពួក)

*គប្បីជ្រាបវិនិច្ឆ័យក្នុង កកុធសូត្រទី ១០ ដូចតទៅនេះ ៖*

*[១០០] បទថា **អត្តភាវប្បដិលាភោ** (ទេវតានោះបានអត្តភាព) បានដល់ មានទូវរាងកាយ ។ ក្នុងបទថា **ទ្វេ វា តីណិ វា មគធកានិ គាមក្ខេត្តានិ** (មានសភាពយ៉ាងនេះ ប្រហែលប៉ុនគាមខេត្តរបស់អ្នកស្រុកមគធៈពីរ ឬបី) នេះ ខេត្តពួកអ្នកស្រុកមគធៈ មានខ្នាតតូច ១ គាវុត មានខ្នាតកណ្តាល មានខ្នាតធំ ។ ខេត្តពួកអ្នកស្រុកខ្នាតតូច ចាប់ពីត្រង់នេះទៅ ៤០ ឧសភៈ ពីត្រង់ឯណោះមកវិញ ៤០ ឧសភៈ រួមជាមួយគាវុត ។ ខ្នាតកណ្តាល រាប់ចាប់ពីត្រង់នេះទៅមួយគាវុត រាប់ចាប់ពីឯណោះមកវិញមួយគាវុត រួមជាកន្លះយោជន៍ ។ ខ្នាតធំ ចាប់ពីទីនេះទៅ ១ គាវុតកន្លះ តាំងអំពីទីឯណោះមកវិញ ១ គាវុតកន្លះ រួមជាបីគាវុត ។ ក្នុងបណ្តាខេត្តទាំង ៣ នោះ ខេត្តខ្នាតតូច និងខេត្តខ្នាតកណ្តាល ជាខ្នាតអត្តភាពរបស់ទេវបុត្រនោះ ។ ដូច្នោះ ទេវបុត្រនោះទើបមានរាងកាយ ៣ គាវុត ។*

*បទថា **បរិហាយាមិ** (និងបរិវារ) បានដល់ អញនឹងគ្រប់គ្រង ។ បទថា **រក្ខស្សេតំ** កាត់បទជា **រក្ខស្សុ ឯតំ** (ចូរអ្នករក្សាទុកនូវសម្តីនេះ) ។*

បទថា *មោឃបុរិសោ (មោឃបុរសនោះ)* បានដល់ ជាមនុស្សទទេ ។ បទថា *នាស្សស្ស (គង់លោកមិនគាប់ចិត្តទេ)* បានដល់ សេចក្តីពេញចិត្ត មិនគប្បីមានដល់លោក ។ បទថា *សមុទាចរេយ្យាម (យើងនឹងសើរើរឿងនោះ)* បានដល់ គប្បីពោល ។ បទថា *សម្មន្នតិ (ព្រោះលោកកំពុងតែទំនុកបម្រុង)* បានដល់ ធ្វើការលើកសរសើរ ។ បទថា *យំ តុមោ ករិស្សតិ តុមោវ តេន បញ្ញាយិស្សតិ (លោកនឹងធ្វើកម្មណា លោកគង់នឹងឮខ្ចរខ្ចាយ ព្រោះតែកម្មនោះមិនខាន)* សេចក្តីថា សាស្តានេះនឹងធ្វើកម្មណា គេក៏នឹងប្រាកដដោយកម្មនោះ (អ្នកធ្វើនូវកម្មណា អ្នកនឹងទទួលនូវផលកម្មនោះ) ។ បទដ៏សេសក្នុងទីគ្រប់កន្លែង ងាយយល់ហើយនោះឯង ។

ចប់អដ្ឋកថា កកុធសូត្រទី ១០

## ចប់កកុធវគ្គវណ្ណនាទី ៥

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៨ សូត្រ

# ចប់ទុតិយបណ្ណាសក

# រាយនាមសប្បុរសជន

# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 USA |
| -ភិក្ខុ ចៅ សៀប វត្តអូស្ត្រាលី | $ 500 AUS |
| -ភិក្ខុធម្មប្បញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ សហរដ្ឋអាមេរិក ព្រមទាំងពុទ្ធបរិស័ទ | $ 920 USA |
| -ឧបាសក សោម រតនៈ ព្រមទាំងភរិយា និងបុត្ត | $ 200 USA |
| -ឧបាសក តាំង សុផល ឧបាសិកា ឡុង កេង ព្រមទាំងបុត្ត និងចៅ | កុំព្យូទ័របត់មួយគ្រឿង |